

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សារណាបញ្ចប់ការសិក្សា

ដំណើរការចោះផ្សាយលក់មូលបត្រកម្មសិទ្ធិ របស់ធនាគារអេស៊ីលីដា តីអិលស៊ី

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

តាក់តែងដោយ

និស្សិតឈ្មោះ **ផាន់ ចន្ធា**

ស្រ៊ាង គីមមួយ

ថ្នាក់បរិញ្ញាបត្រគណនេយ្យ

ជំនាន់ទី ១៧

សាស្ត្រាចារ្យណែនាំ

លោក **ឈាង ហ៊ុយ**

ឆ្នាំចូលសិក្សា ២០១៨

ឆ្នាំសរសេរសារណា ២០២២

សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំនិស្សិតឈ្មោះ ជាន់ ចន្ធា និងនិស្សិតឈ្មោះ ស្រ៊ាង គីមមួយ ដែលជានិស្សិតកំពុងតែសិក្សាបញ្ចប់ថ្នាក់បរិញ្ញាបត្រគណនេយ្យឆ្នាំទី៤ ក្រុម A4A01 មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានធ្វើរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាស្តីអំពី **ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី**។

ជាបឋមនាងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណ កតញ្ញូតវេទីតាធម៌ យ៉ាងជ្រាលជ្រៅដល់គុណូបការៈគុណលោកឪពុកអ្នកម្តាយ ដែលបានអប់រំទូន្មានប្រៀនប្រដៅ និងចិញ្ចឹមបីបាច់កូនតាំងពីតូចមិនទាន់ដឹងក្តីរហូតដល់កូនធំដឹងក្តីមានចំណេះវិជ្ជាដូចសព្វថ្ងៃដែលកើតចេញពីការលះបង់យ៉ាងធំធេង ទាំងកម្លាំងកាយ ទាំងព្រមទាំងកម្លាំងចិត្តគ្រប់បែបយ៉ាង ពុះពារគ្រប់ឧបសគ្គដើម្បីជំរុញលើកទឹកចិត្ត និងផ្គត់ផ្គង់ថវិការឱ្យកូនបានសិក្សារៀនសូត្ររហូតមកដល់បច្ចុប្បន្ន។ កូនសូមបួងសួងដល់គុណព្រះរតនៈត្រៃ សូមជួយប្រសិទ្ធិពរជ័យជូនដល់លោកអ្នកមានគុណទាំងទ្វេរមានសុខភាពល្អ និងមានជន្មាយុយឺនយូរ ដើម្បីទទួលបានការតបស្នងសងគុណពីកូន។

សូមថ្លែងអំណរគុណដល់ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីប្រធាន អនុប្រធានដេប៉ាតឺម៉ង់ លោក លោកស្រីប្រធានការិយាល័យ អនុប្រធានការិយាល័យ លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិកទាំងអស់ ដែលបានបម្រើការ និងគ្រប់គ្រងសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច បានយ៉ាងល្អតាំងពីការកកើតដំបូងរហូតមកដល់បច្ចុប្បន្ន ដែលបានក្លាយជាសាកលវិទ្យាល័យគំរូជាជំនួយដល់ការសរសេរសារណាបញ្ចប់ការសិក្សានេះឡើង។

សូមថ្លែងអំណរគុណ ដល់មិត្តនិស្សិតទាំងអស់ ជាពិសេសមិត្តនិស្សិតនៅក្នុងថ្នាក់ A4A1 ដែលបានផ្តល់ជាកម្លាំងចិត្ត និងទំនុកចិត្តនៅក្នុងការសរសេរសារណានេះឡើង។

សូមថ្លែងអំណរអរគុណដល់ រៀមច្បងគ្រប់ជំនាន់ដែលបានបន្សល់ទុកនូវស្នាដៃជាច្រើនសម្រាប់ទុកជាទិន្នន័យ និងព័ត៌មានដ៏មានតម្លៃដល់ពួកខ្ញុំ ក៏ដូចជានិស្សិតជំនាន់ក្រោយសម្រាប់ធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀត។

ជាចុងក្រោយនាងខ្ញុំសូមជូនពរ លោកអ្នកមានគុណទាំងអស់ ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ សុខ ពល និងសេចក្តីសុខ សេចក្តីចម្រើន និងជោគជ័យគ្រប់ភារកិច្ចកុំបីឃ្លាងឃ្លាតឡើយ។

សូមអរគុណ

អារម្ភកថា

យើងខ្ញុំជានិស្សិតជំនាន់ទី១៧ ជំនាញគណនេយ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច មហាវិទ្យាល័យវិទ្យាសាស្ត្រសេដ្ឋកិច្ច និងគ្រប់គ្រង កូដថ្នាក់ A4A1 ឆ្នាំសិក្សា ២០១៨-២០២២ បានធ្វើការស្រាវជ្រាវ និងចងក្រង ដោយយកចិត្តទុកដាក់ក្នុងការសរសេរសារណានេះឡើង ដែលធ្វើការសិក្សាទៅលើដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ដែលជាធនាគារដំបូងបំផុតដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅផ្សារមូលត្រកម្ពុជា ដោយផ្អែកលើទិន្នន័យឯកសារ ព្រមទាំងគោលបំណងដែលធនាគារបានធ្វើការចុះផ្សាយ រួមទាំងសារព័ត៌មានចុះផ្សាយនានាក្នុងប្រទេស យ៉ាងទូលំទូលាយផងដែរ។

ក្រុមនាងខ្ញុំសង្ឃឹមថាតាមរយៈស្នាដៃស្រាវជ្រាវមួយនេះ មានសារៈប្រយោជន៍ចំពោះនិស្សិតសាធារណៈជនព្រមទាំងវិនិយោគិនទាំងអស់ដែលមានបំណងចង់សិក្សាឈ្វេងយល់បន្ថែមអំពីចំណេះ ដឹងទ្រឹស្តី ព្រមទាំងការអនុវត្តជាក់ស្តែង ដែលបានឆ្លងកាត់កន្លងមកដែលទាក់ទងនឹងផ្សារមូលបត្រកម្ពុជា ជាពិសេសដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងផ្សារមូលបត្រកម្ពុជា។

ដើម្បីសម្រេចបានជោគជ័យនៅក្នុងការចងក្រងរបាយការណ៍ស្រាវជ្រាវនេះបាន យើងខ្ញុំបានខិតខំស្រាវជ្រាវដោយកចិត្តទុកដាក់ដោយមានការជ្រាមជ្រែង ត្រួតពិនិត្យ ពន្យល់ ព្រមទាំងការណែនាំពីសំណាក់សាស្ត្រាចារ្យដឹកនាំ និងដកស្រង់ចេញពីឯកសារផ្សេងៗដែលទាក់ទងនឹងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី។ ទោះបីជាមានការត្រួតពិនិត្យ និងធ្វើការកែលម្អជាច្រើនលើកច្រើនសារយ៉ាងណាក៏ដោយ ក៏ក្រុមនាងខ្ញុំជឿជាក់ថានៅក្នុងអត្ថបទស្រាវជ្រាវនេះប្រាជកជាកើតមាននូវកំហុសដែលកើតឡើងដោយអចេតនា ដូចជាការខ្វះខាតអត្ថន័យ ឬការប្រើប្រាស់ពាក្យពេចន៍ខុសឆ្គងឬកំហុសអក្ខរាវិរុទ្ធត្រង់ចំណុចណាមួយជាក់ជាពុំខាន។ អាស្រ័យដូចនេះ ក្រុមនាងខ្ញុំសូមរងចាំការរិះគុណ ស្ថាបនា កែលម្អ ព្រមទាំងសូមការអធ្យាស្រ័យទុកជាមុនពីសំណាក់សាស្ត្រាចារ្យ លោកគ្រូអ្នកគ្រូ សិស្សនិស្សិត សាធារណៈជន វិនិយោគិន និងមិត្តអ្នកអានដោយក្តីសោមនស្សរីករាយ។

មាតិការ

អក្សរកាត់ vi
បញ្ជីតារាង vii
បញ្ជីរូបភាព viii

សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ២
៣. គោលបំណងនៃការស្រាវជ្រាវ ២
៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ៣
៥. វិធីសាស្ត្រនៃការស្រាវជ្រាវ ៣
  ៥.១. ការប្រមូលទិន្នន័យ ៣
  ៥.២. ការវិភាគទិន្នន័យ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៤

ជំពូកទី ១
រំលឹកទ្រឹស្តី

១.១. ទីផ្សារមូលបត្រ ៥
  ១.១.១. និយមន័យ ៥
  ១.១.២. ប្រភេទនៃទីផ្សារមូលបត្រ ៥
    ១.១.២.១. ទីផ្សារមូលធន ៥
    ១.១.២.២. ទីផ្សាររូបិយវត្ថុ ៥
    ១.១.២.៣. ទីផ្សារដំបូង ៥
    ១.១.២.៤. ទីផ្សារបន្ទាប់ ៦
    ១.១.២.៥. ទីផ្សារប្រតិស្រុត ៦
    ១.១.២.៦. ទីផ្សាររំលងបញ្ជា ៧
  ១.១.៣. មុខងារនៃទីផ្សារមូលបត្រ ៧
    ១.១.៣.១. មុខងារបង្កើតដើមទុន ៧

១.១.៣.២. មុខងារសន្ទនីយភាព ៨
១.១.៤. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ ៨
១.១.៤.១. ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure) ៨
១.១.៤.២. អន្តរការីផ្សារមូលបត្រ (Intermediary) ៨
១.១.៤.៣. ក្រុមហ៊ុនបោះផ្សាយ (Issuer) ៩
១.១.៤.៤. វិនិយោគិន(Investor) ៩
១.១.៥. គុណសម្បត្តិនិងគុណវិបត្តិនៃផ្សារមូលបត្រ ៩
១.១.៥.១. គុណសម្បត្តិនៃផ្សារមូលបត្រ ៩
១.១.៥.២. គុណវិបត្តិនៃផ្សារមូលបត្រ ៩
១.២. មូលបត្រ ១០
១.២.១. និយមន័យ ១០
១.២.២. ប្រភេទនៃមូលបត្រ ១១
១.២.២.១. មូលបត្រកម្មសិទ្ធិ (ប្រភេទភាគហ៊ុន) ១១
១.២.២.២. មូលបត្របំណុល(ប្រភេទបំណុល) ១២
១.២.២.៣. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរីវេទីវ (Derivative Instrument) ១៥
១.៣. តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រ ១៥
១.៣.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ១៥
១.៣.១.១. សិទ្ធិអំណាចជាអាណាព្យាបាលលើវិស័យមូលបត្រ ១៦
១.៣.១.២. មុខងារជានិយ័តករក្នុងវិស័យមូលបត្រ ១៦
១.៣.១.៣. មុខងារផ្សេងទៀត ១៦
១.៣.២. ក្រុមហ៊ុនមូលបត្រនិងអាជីវកម្មមូលបត្រ ១៧
១.៣.២.១. អាជីវកម្មមូលបត្រ ១៧
១.៣.២.២. ប្រភេទអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនមូលបត្រ ១៨
១.៣.២.៣. លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ ១៨
១.៣.២.៤. ភ្នាក់ងារក្រុមហ៊ុនមូលបត្រ ១៩
១.៣.៣.ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ ១៩
១.៣.៣.១. ប្រតិបត្តិករទីផ្សារមូលបត្រ ១៩

១.៣.៣.២. ប្រតិបត្តិការដាក់ទាត់ និងទូទាត់ ១៩
១.៣.៣.៣. ប្រតិបត្តិការរក្សាទុកមូលបត្រ ២០
១.៣.៣.៤. វិធានប្រតិបត្តិការ ២០
១.៣.៣.៥. ការផ្តល់ការអនុញ្ញាត ២០
១.៣.៤. អ្នកចូលរួមក្នុងទីផ្សារផ្សេងទៀត ២០
១.៣.៤.១. អ្នកវិនិយោគសាធារណៈ ២០
១.៣.៤.២. កត្តាជំរុញឱ្យមានការវិនិយោគលើមូលបត្រ ២១
១.៣.៤.៣. ភ្នាក់ងារបញ្ជីការមូលបត្រ ២១
១.៣.៤.៤. ភ្នាក់ងារចុះបញ្ជីផ្ទេរធ្វើមូលបត្រ ២២
១.៣.៤.៥. ភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស ២២
១.៣.៤.៦. បុគ្គលដែលអាចក្លាយជាភ្នាក់ងារបញ្ជីកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស ២២
១.៣.៤.៧. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ២៣
១.៤. យន្តការចូលទីផ្សារមូលបត្រជាសាធារណៈ ២៣

ជំពូកទី២ ស្ថានភាពទូទៅរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី

២.១. ប្រវត្តិសង្ខេបរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ២៧
២.១.១. ការិយាល័យកណ្តាលរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ២៨
២.១.២. ស្ថាបនិក ២៨
២.១.៣. ដំណើរការនៃការពង្រីកបណ្តាញសាខារបស់ធនាគារអេស៊ី លីដា ភីអិលស៊ី ២៩
២.២. និមិត្តសញ្ញា អត្ថន័យ និងប្រព័ន្ធទំនាក់ទំនងរបស់ធនាគារអេស៊ីលីដា ៣១
២.២.១. និមិត្តសញ្ញា និងការវិវត្តនៃនិមិត្តសញ្ញា ៣១
២.២.២. អត្ថន័យនៃរូបសញ្ញា ៣២
២.២.៣. ប្រព័ន្ធទំនាក់ទំនងរបស់ធនាគារអេស៊ីលីដា ៣២
២.៣. ទស្សនៈនិងបេសកកម្ម ៣២
២.៣.១. ទស្សនៈ ៣២
២.៣.២. បេសកកម្ម ៣២
២.៤. ក្រុមប្រឹក្សាភិបាល ៣៣

២.៥. គណៈកម្មការប្រតិបត្តិ ៣៤
២.៦. សាវនកម្មផ្ទៃក្នុង ៣៥
២.៧. ភាគហ៊ុនិក ៣៥
២.៨. សេវាកម្មនិងផលិតផល ៣៦

ជំពូកទី៣

ដំណើរការចោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា តីអិលស៊ី

៣.១. ការបង្ហាញព័ត៌មានក្រុមហ៊ុនពាក់ព័ន្ធនឹងការចោះផ្សាយ IPO ៤៣
៣.១.១. ព័ត៌មានទូទៅអំពីការចោះផ្សាយ ៤៤
៣.១.២. ព័ត៌មានទូទៅអំពីក្រុមហ៊ុនធានាទិញមូលបត្រ ៤៥
៣.១.៣. ព័ត៌មានទូទៅអំពីក្រុមហ៊ុនសេវាកម្មផ្នែកច្បាប់ ៤៦
៣.១.៤. ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាសវនកម្ម ៤៦
៣.១.៥. កិច្ចព្រមព្រៀងធានាទិញមូលបត្រ ៤៧
៣.១.៦. ចំណាយពាក់ព័ន្ធនឹងការចោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ៤៧
៣.២. ការបង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារ ៤៧
៣.៣. ការពិព័ណនាអំពីមូលបត្រកម្មសិទ្ធិចេញផ្សាយដំបូង (IPO) ៥១
៣.៣.១. ព័ត៌មានអំពីការដាក់សំណើការផ្សាយលក់មូលបត្រកម្មសិទ្ធិ ៥១
៣.៣.២. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ ៥២
៣.៣.៣. តម្លៃមួយឯកតានៃមូលបត្រកម្មសិទ្ធិ ៥៣
៣.៣.៤. សាច់ប្រាក់ដែលបានមកពីការលក់មូលបត្រកម្មសិទ្ធិ ៥៣
៣.៤. សិទ្ធិរបស់ភាគហ៊ុនិក ៥៣
៣.៥. គោលនយោបាយភាគលាភ ៥៨
៣.៦. នីតិវិធីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្ម ៥៩
៣.៦.១. ដំណាក់កាលប៊ុកបៀលឌីង ៥៩
៣.៦.១.១. ព័ត៌មានលម្អិតពីប៊ុកបៀលឌីង ៥៩
៣.៦.១.២. ការចូលរួមធ្វើប៊ុកបៀលឌីង ៦០
៣.៦.១.៣. វិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិ ៦១

៣.៦.១.៤. ការលៃបម្រុងទុកនៃមូលបត្រកម្មសិទ្ធិ ៦១
៣.៦.១.៥. ការផ្ទេរប្រាក់តម្កល់ ៦២
៣.៦.២. នីតិវិធីនៃការធ្វើបរិវិសកម្ម ៦២
៣.៦.២.១. ព័ត៌មានលម្អិតពីការធ្វើបរិវិសកម្ម ៦២
៣.៦.២.២. ការចូលរួមធ្វើបរិវិសកម្ម ៦៣
៣.៦.២.៣. ការដាក់ប្រាក់តម្កល់សម្រាប់ធ្វើបរិវិសកម្ម ៦៤
៣.៦.២.៤. ការបែងចែកមូលបត្រកម្មសិទ្ធិ ៦៤
៣.៦.២.៥. ការផ្ទេរប្រាក់តម្កល់ ៦៦
៣.៧. ដំណើរការនិងលទ្ធផលនៃការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្ម ៦៧
៣.៧.១.ការបង្ហាញព័ត៌មានលម្អិត (Roadshow) ៦៧
៣.៧.២. កាលបរិច្ឆេទប៊ុកបៀលឌីង និងទីតាំង ៦៧
៣.៧.៣. លទ្ធផលនៃការធ្វើប៊ុកបៀលឌីង ៦៨
៣.៧.៤. ដំណើរការនិងលទ្ធផលធ្វើបរិវិសកម្ម (Subscription) ៦៩
៣.៨. ឥទ្ធិពលភាគហ៊ុនអេស៊ីលីដាក្នុងផ្សារមូលបត្រកម្ពុជា ៧០
៣.៨.១. ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅ ផ.ម.ក ៧០
៣.៨.២. ការជួញដូរមូលបត្រកម្មសិទ្ធិ ABC នៅ ផ.ម.ក ៧១

សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ៧៤
២. ការផ្តល់អនុសាសន៍ ៧៥

ឯកសារយោង

ឧបសម្ព័ន្ធ

បញ្ជីអក្សរកាត់

គ.ម.ក ៖ គណៈកម្មការមូលបត្រកម្ពុជា

ផ.ម.ក ៖ ផ្សារមូលបត្រកម្ពុជា

ម.ក ៖ ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត

ឯ.ក ៖ ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត

IPO ៖ Initial Public Offering

ABC ៖ អក្សរសម្គាល់ មូលបត្រកម្មសិទ្ធិធនាគារអេស៊ីលីដា

SECC ៖ Securities and Exchange Commission of Cambodia

CSX ៖ Cambodia Securities Exchange

បញ្ជីតារាង

តារាងទី១ ៖ រចនាសម្ព័ន្ធនៃការស្រាវជ្រាវរបស់ប្រធាន
តារាងទី ២ ៖ បណ្តាញពង្រីកសាខារបស់ អេស៊ីលីដា នៅព្រះរាជាណាចក្រកម្ពុជា
តារាងទី៣ ៖ បណ្តាញពង្រីកសាខារបស់ អេស៊ីលីដា នៅសាធារណរដ្ឋប្រជាធិបតេយ្យមានិតឡាវ
តារាងទី៤ ៖ បណ្តាញពង្រីកសាខារបស់ អេស៊ីលីដា នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា
តារាងទី៥ ៖ រចនាសម្ព័ន្ធក្រុមប្រឹក្សារបស់ធនាគារអេស៊ីលីដា
តារាងទី៦ ៖ រចនាសម្ព័ន្ធគណកម្មាធិការប្រតិបត្តិរបស់ធនាគារអេស៊ីលីដា
តារាងទី៧ ៖ សេវាកម្ម និងផលិតផល (ឯកត្តជន)
តារាងទី៨ ៖ សេវាកម្ម និងផលិតផល (ប័ណ្ណ)
តារាងទី៩ ៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនបោះផ្សាយមូលបត្រ
តារាងទី១០ ៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនធានាទិញមូលបត្រ
តារាងទី១១ ៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់
តារាងទី១២ ៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាសវនកម្ម
តារាងទី១៣ ៖ ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ
តារាងទី១៤ ៖ តារាងតុល្យការការរួមរបស់ធនាគារអេស៊ីលីដា
តារាងទី១៥ ៖ របាយការណ៍លទ្ធផលរួមរបស់ធនាគារអេស៊ីលីដា
តារាងទី១៦ ៖ លក្ខខណ្ឌនៃសំណើមូលបត្រ
តារាងទី១៧ ៖ ផែនការបែងចែកមូលបត្រ
តារាងទី១៨ ៖ ព័ត៌មានលម្អិតអំពីប៊ុកបៀលឌីង
តារាងទី១៩ ៖ គណនីប៊ុកបៀលឌីង
តារាងទី២០ ៖ ព័ត៌មានលម្អិតអំពីការធ្វើបរិវិសកម្ម
តារាងទី២១ ៖គណនីបរិវិសកម្ម
តារាងទី២២ ៖ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅ ផ.ម.ក
តារាងទី២៣ ៖ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី១
តារាងទី២៤ ៖ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី២
តារាងទី២៥ ៖ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី៣
តារាងទី២៦ ៖ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី៤

បញ្ជីរូបតាង

រូបភាពទី១ ៖ ទីស្នាក់ការកណ្តាលរបស់ធនាគារ អេស៊ី លីដា ភីអិលស៊ី

រូបភាពទី២ ៖ និមិត្តសញ្ញារបស់ធនាគារអេស៊ីលីដាបច្ចុប្បន្ន

រូបភាពទី៣ ៖ និមិត្តសញ្ញានៃការវិវត្តរបស់ធនាគារអេស៊ីលីដាមកទល់បច្ចុប្បន្ន

រូបភាពទី៤ ៖ វិញ្ញាបនប័ត្រចុះបញ្ជីមូលបត្រ

សេចក្តីផ្តើម

សេចក្តីផ្តើម

១.ចំណាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសមួយមានការរីកចម្រើនទៅបាន គឺអាស្រ័យទៅលើវិស័យផ្សេងៗជាច្រើន ដែលចូលរួមក្នុងការអភិវឌ្ឍប្រទេសជាតិ ជាពិសេសវិស័យហិរញ្ញវត្ថុដែលជាធាតុមួយយ៉ាងសំខាន់នៅក្នុងខឿនសេដ្ឋកិច្ចរបស់ប្រទេសជាតិខ្លះមិនបាន។ ភាពរីកចម្រើននៃប្រព័ន្ធហិរញ្ញវត្ថុជាកាតាលីករដែលជួយជំរុញឱ្យសេដ្ឋកិច្ចកាន់តែឆ្ពោះទៅមុខបន្ថែមទៀត ចំពោះប្រទេសកម្ពុជាវិញ ឃើញថាប្រព័ន្ធហិរញ្ញវត្ថុ គឺមានភាពរីកចម្រើនគួរឱ្យកត់សម្គាល់ ជាពិសេសទាក់ទងទៅនឹងវិស័យមូលបត្រ។ ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំវិស័យហិរញ្ញវត្ថុមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ម៉្យាងវិញទៀតនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១២ ជាថ្ងៃដែលសោមនស្សរីករាយបំផុតរបស់ប្រទេសកម្ពុជា ដែលត្រូវបានធ្វើពិធីបើកការជួញដូរមូលបត្រនៅក្នុងផ្សារមូលបត្រកម្ពុជាជាផ្លូវការ[1] ដែលទីផ្សារមូលបត្រ គឺជាកន្លែងសម្រាប់ធ្វើការជួញដូរមូលបត្រកម្មសិទ្ធិមូល បត្របំណុល និងឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត[2]។

ចាប់តាំងពីដំណើរការនៃការបើកឱ្យមានការជួញដូរមូលបត្រនៅកម្ពុជាមក សង្កេតឃើញថាមានបណ្តាក្រុមហ៊ុនជាបន្តបន្ទាប់បានមកចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា។ បើសង្កេតមកមើលអំពីក្រុមហ៊ុនដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិវិញ ឃើញថាមានក្រុមហ៊ុនចំនួនប្រាំបួនដែលបានធ្វើការចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្មសិទ្ធិ។ ក្រុមហ៊ុនទាំងនោះរួមមាន (១) រដ្ឋការទឹកស្វ័យយ័តក្រុងភ្នំពេញ (និមិត្តសញ្ញា៖ PWSA) (២) ព្រ្មែនធ្វីន អ៊ិនធើណេសិនណល (ខេមបូឌា) ភីអិលស៊ី (និមិត្តសញ្ញា៖ GTI) (៣) កំពង់ផែស្វ័យត្តភ្នំពេញ (និមិត្តសញ្ញា៖ PPAP) (៤) ភ្នំពេញអេសអ៊ីហ្សិតភីអិលស៊ី (និមិត្តសញ្ញា៖ PPSP) (៥) កំពង់ផែស្វ័យយ័តក្រុង ព្រះសីហនុ (និមិត្តសញ្ញា៖ PAS) (៦) ធនាគារអេស៊ីលីដា ភីអិលស៊ី (និមិត្តសញ្ញា៖ ABC) (៧) ផេសថិក (ខេមបូឌា) ម.ក (និមិត្តសញ្ញា៖ PEPC) (៨) ឌីប៊ីឌីអ៊ិនជីនារីង ម.ក (និមិត្តសញ្ញា៖ DBDE) (៩) ជេ អេស លែន ភីអិលស៊ី (និមិត្តសញ្ញា៖ JSL)[3]។ គួរបញ្ជាក់ផងដែរថា ធនាគារអេស៊ីលីដា ភីអិលស៊ី គឺជាស្ថាប័នហិរញ្ញវត្ថុមួយក្នុងចំណោមក្រុមហ៊ុនចុះបញ្ជីលក់មូលបត្រទាំងអស់ដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅផ្សារមូលបត្រកម្ពុជានៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០២០ កន្លងមកនេះ នឹងបានបន្តបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនិងការជួញដូរបន្តបន្ទាប់មកទល់នឹងបច្ចុប្បន្ន និងជាក្រុមហ៊ុនមួយដែលមានភាពលេចធ្លោផងដែរ។

[1] http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)

[2] http://csx.com.kh/news/faq/listPosts.do?MNCD=7060 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)

[3] http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលទស្សនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)

ដោយយល់ឃើញអំពីដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ក្នុងទីផ្សារមូលបត្រកម្ពុជា និងមានបណ្តាវិនិយោគិនរួមជាមួយនិងដៃគូអាជីវកម្មជាច្រើនរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី មានការរីកចម្រើនគួរឱ្យកត់សម្គាល់។ អាស្រ័យហេតុនេះហើយ ទើបបានជាមានការ លើកយកប្រធានបទនៃកិច្ចការស្រាវជ្រាវសារណាបញ្ចប់ការសិក្សាទាក់ទងទៅនឹង ដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅផ្សារមូលបត្រកម្ពុជា។

២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បើគិតចាប់តាំងពីកាលបរិច្ឆេទនៃការចុះបញ្ជីរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី មកទល់នឹងបច្ចុប្បន្ន ឃើញថាមានអាយុកាលប្រហែលជិត ២ឆ្នាំមកហើយ និងមានដំណើរការនៃការបោះផ្សាយលក់មូលបត្រមានជាបន្តបន្ទាប់។ បើទោះបីជាយ៉ាងណាក៏ដោយក៏ដំណើរការនៃការបោះផ្សាយលក់មូលបត្រ ឬលទ្ធផលនៃដំណើរការមូលបត្ររបស់ធនាគារអេស៊ីលីដា ភីអិល ស៊ីមានការប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំផងដែរ។ អាស្រ័យហេតុនេះហើយបានជាមានការលើកយកប្រធានបទនៃកិច្ចការស្រាវជ្រាវទាក់ទងទៅនឹង ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នេះឡើង។ ដូចនេះដើម្បីឱ្យកិច្ចការស្រាវជ្រាវសារណាបញ្ចប់ការសិក្សានេះសម្រេចទៅបានគប្បីឈ្វេងយល់ឱ្យបានលម្អិតទាក់ទងទៅនឹង៖

- ដើម្បីឱ្យដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងទីផ្សារមូលបត្រកម្ពុជាសម្រេចទៅបាន តើតម្រូវមានលក្ខខណ្ឌក៏ដូចជានីតិវិធីអ្វីខ្លះ?
- តើដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងទីផ្សារមូលបត្រកម្ពុជាសម្រេចបានលទ្ធផលយ៉ាងដូចម្តេចខ្លះ?

៣. គោលបំណងនៃការស្រាវជ្រាវ

ប្រធានបទស្រាវជ្រាវនេះគឺ ផ្តោតសំខាន់ទៅលើដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ដែលគោលបំណងនៃការស្រាវជ្រាវនេះ អាចសង្ខេបបានដូចខាងក្រោម៖

- ឈ្វេងយល់ពីទ្រឹស្តីទូទៅដែលទាក់ទងនឹងវិស័យមូលបត្រ និយ័តករមូលបត្រកម្ពុជា និងគោលការណ៍ណែនាំផ្សេងៗទាក់ទងនឹងការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាដើម
- ឈ្វេងយល់ពីប្រវត្តិ និងស្ថានភាពទូទៅរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី
- ឈ្វេងយល់ឱ្យបានស៊ីជម្រៅទាក់ទងទៅនឹងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងផ្សារមូលបត្រកម្ពុជា
- ឈ្វេងយល់ចំណុចខ្លាំង និងខ្សោយនៃដំណើរការលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី

- ធ្វើការសរុបជារួមអំពីដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងផ្សារមូលបត្រកម្ពុជារួមជាមួយការសន្និដ្ឋាននិងផ្តល់ជាអនុសាសន៍ខ្លះៗដើម្បីឱ្យដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី កាន់តែមានភាពរីកចម្រើនបន្ថែមទៀត។

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

បច្ចុប្បន្ននេះ នៅក្នុងទីផ្សារមូលបត្រកម្ពុជាមានការរីកដុះដាលគួរឱ្យកត់សម្គាល់ដែលទាក់ទងទៅនឹងការជួញដូរមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុលពីសំណាក់វិនិយោគិន។ ហើយបណ្តាក្រុមហ៊ុនជាច្រើនដែលបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជាសុទ្ធតែទទួលបានសិទ្ធិក្នុងការបោះផ្សាយលក់មូលបត្រ។ ដោយឡែកនៅក្នុងការសិក្សាស្រាវជ្រាវនេះ គឺផ្តោតសំខាន់ទៅលើដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងទីផ្សារមូលបត្រកម្ពុជា ជាមួយនឹងទិន្នន័យ២០២០ និងធ្វើការវិភាគលើការជួញដូរខែ មិថុនា ឆ្នាំ ២០២២ តែប៉ុណ្ណោះ។

៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

របាយការណ៍ស្រាវជ្រាវនេះពឹងផ្អែកលើប្រភពទិន្នន័យបន្ទាប់បន្សំ ឬទិន្នន័យដែលមានស្រាប់ទាំងស្រុង។

៥.១. ការប្រមូលទិន្នន័យ

- ទិន្នន័យទទួលបានពីប្រព័ន្ធអ៊ីនធើណេត
- ស្នាដៃចងក្រងសៀវភៅរបស់អ្នកនិពន្ធផ្សេងៗ សៀវភៅមេរៀន ស្លាយមេរៀនជាដើម
- ព័ត៌មានទទួលបានពីគេហទំព័ររបស់ធនាគារអេស៊ីលីដា ភីអីលស៊ី ក្រុមហ៊ុនផ្សារមូលបត្រ និយ័តករមូលបត្រ និងគណៈកម្មការមូលបត្រ
- និក្ខេបបទ របាយការណ៍កម្មសិក្សា ឬសារណាបញ្ចប់ការសិក្សារបស់សិស្សច្បង
- បណ្ណាល័យ E-Book Library របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

៥.២. ការវិភាគទិន្នន័យ

នៅក្នុងរបាយការណ៍ស្រាវជ្រាវលើប្រធានបទទាក់ទងនឹង ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅផ្សារមូលបត្រកម្ពុជា គឺត្រូវបានធ្វើការវិភាគទៅតាមបែបគុណវិស័យ (ពិព័ណ៌នា)។

៦. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវពី ប្រធានបទដែលទាក់ទងទៅនឹង ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា គឺពិតជាមានសារៈសំខាន់ និងផ្តល់ផលប្រយោជន៍ជាច្រើនដូចជា៖

- រំលឹកទ្រឹស្តីដែលបានសិក្សាកន្លងមក
- ទទួលបានចំណេះដឹងបន្ថែមទាក់ទងទៅនឹងវិស័យមូលបត្រនៅកម្ពុជាជាពិសេស ដំណើរការបោះផ្សាយមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី
- ជួយបង្កើនការផ្សព្វផ្សាយអំពីមូលបត្រ
- ជួយធ្វើឱ្យវិស័យមូលបត្រមានការរីកចម្រើនទូលំទូលាយឱ្យមហាជនបានស្គាល់
- ជាប្រភពឯកសារសម្រាប់និស្សិតរួមទាំងសាធារណៈជនទូទៅ ជាពិសេសសម្រាប់វិនិយោគិន
- ជួយដល់ការសម្រេចចិត្តក្នុងការវិនិយោគទៅលើវិស័យមូលបត្រនេះ
- ជាឯកសារជំនួយស្មារតីដល់និស្សិតជំនាន់ក្រោយដែលមានបំណងចង់ឈ្វេងយល់ពី ដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងផ្សារមូលបត្រកម្ពុជាឱ្យកាន់តែច្បាស់បន្ថែមទៀត
- ជាឯកសារយោងសម្រាប់ការសិក្សាស្រាវជ្រាវបន្តទៀត។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវរចនាសម្ព័ន្ធ

ខាងក្រោមនេះគឺជារចនាសម្ព័ន្ធនៃការស្រាវជ្រាវរបស់ប្រធានបទខាងលើ៖



តារាងទី១៖ រចនាសម្ព័ន្ធនៃការស្រាវជ្រាវរបស់ប្រធាន

ជំពូកទី ១
រំលឹកគ្រីស្ដី

ជំពូកទី ១
រំលឹកទ្រឹស្តី

១.១. ទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ គឺជាពាក្យដែលបានបន្សំឡើងមកពីពាក្យទីផ្សារ និងពាក្យមូលបត្រ។ តាមនិយមន័យសេដ្ឋកិច្ចទីផ្សារ សំដៅដល់ទីកន្លែងជួបគ្នារវាងតម្រូវការ និងផ្គត់ផ្គង់អាចជាទំនិញ ឬសេវាកម្ម។ រីឯមូលបត្រ សំដៅដល់គំរូប័ណ្ណដែលរួមមានដូចជាសញ្ញាប័ណ្ណ ឬភាគហ៊ុនជាដើមដែលអាចធ្វើការដោះដូរជាសាធារណៈ ឬនៅលើទីផ្សារមូលបត្រ។ ជារួមទីផ្សារមូលបត្រ គឺជាកន្លែងដែលមូលបត្រមានដូចជាសញ្ញាប័ណ្ណ ឬភាគហ៊ុន ត្រូវបានទិញ និងលក់ដោយវិនិយោគិនរួមទាំងជាតិ និងអន្តរជាតិ។

១.១.១. និយមន័យ

យោងតាមនិយមន័យច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ទីផ្សារមូលបត្រ គឺសំដៅទៅលើទីផ្សារ ទីកន្លែងដែលជួញដូរមូលបត្រ ឬប្រព័ន្ធនៃការផ្តល់មធ្យោបាយនៃការធ្វើសំណើលក់ផ្ទេរឬធ្វើការលក់មូលបត្រឧបករណ៍ហិរញ្ញវត្ថុ ដែលតែងតែត្រូវបានជួញដូរនៅលើទីផ្សារនេះរួមមាន មូលបត្រកម្មសិទ្ធិ មូលបត្របំណុល និងឧបករណ៍និស្សន្ទជាដើម។[4]

១.១.២. ប្រភេទនៃទីផ្សារមូលបត្រ

១.១.២.១. ទីផ្សារមូលធន

ទីផ្សារមូលធន គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរមូលបត្រកម្មសិទ្ធិ និងឧបករណ៍រយៈពេលវែងមួយចំនួនទៀត។ ជាទូទៅ ឧបករណ៍រយៈពេលវែងត្រូវបានគេកំណត់ថាជាឧករណ៍ទាំងឡាយណាដែលមានឥណប្រតិទានរយៈពេលមួយឆ្នាំ ឬរយៈពេលវែងជាងមួយឆ្នាំ។

១.១.២.២. ទីផ្សាររូបិយវត្ថុ

ទីផ្សាររូបិយវត្ថុ គឺជាទីផ្សារហិរញ្ញវត្ថុដែលជួញដូរតែឧបករណ៍បំណុលរយៈពេលខ្លី និងប្រាក់កម្ចី។ ឧបករណ៍រយៈណាពេលខ្លី ត្រូវបានគេកំណត់ថាជាឧបរណ៍ទាំងឡាយណាដែលមានឥណប្រតិទានរយៈពេលតិចជាងមួយឆ្នាំ។

១.១.២.៣. ទីផ្សារដំបូង

ការដាក់មូលបត្រជាលើកដំបូងដោយក្រុមហ៊ុនបោះផ្សាយទៅឱ្យវិនិយោគិនត្រូវបានហៅថា ជាការលក់ចែកចាយជាលើកដំបូង។ ទីផ្សារដំបូង គឺជាទីកន្លែងដែលមូលបត្រត្រូវបានលក់ជាលើកទីមួយទៅឱ្យសាធារណៈ

[4] ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៥, ទំព័រទី ២៧)

ជនហើយអ្នកទិញបានទិញមូលបត្រដោយផ្ទាល់ពីក្រុមហ៊ុនបោះផ្សាយដែលអាចជាក្រុមហ៊ុន សាជីវកម្ម ឬ អង្គភាពរដ្ឋាភិបាលមួយដែលបានបោះផ្សាយលក់មូលបត្រ។ សាច់ប្រាក់សម្រាប់ទូទាត់មូលបត្រត្រូវបង់ទៅក្រុមហ៊ុនបោះផ្សាយ ហើយអ្នកទិញភាគហ៊ុនទាំងនេះក្លាយជាអ្នកកាន់កាប់ (ម្ចាស់) ភាគហ៊ុនដំបូងគេ។ ភាគហ៊ុនិកដំបូងគេអាចកាន់កាប់ភាគហ៊ុនទាំងនេះ ឬក៏លក់ភាគហ៊ុនទាំងអស់ទៅឱ្យអ្នកផ្សេងទៀត។ ដំណើរការលក់ភាគហ៊ុនទៅឱ្យសាធារណៈជនជាលើកដំបូង ត្រូវគេទទួលស្គាល់ថា ជាការនាំក្រុមហ៊ុនទៅកាន់សាធារណៈ។ នេះមានន័យថា ក្រុមហ៊ុនលែងកាន់កាប់ដោយវិនិយោគិនដំបូង ឬស្ថាបនិកទៀតហើយ។ ក្រុមហ៊ុនដែលលក់ភាគហ៊ុនរបស់ខ្លួនទៅកាន់សាធារណៈជន ត្រូវបានគេសន្មតថាជាសំណើលក់មូលបត្រ ជាសាធារណៈកើតមានឡើង។ ចំពោះដំណើរការនៃការលក់ភាគហ៊ុនជាលើកដំបូងរបស់ក្រុមហ៊ុនមួយត្រូវបានគេហៅថា សំណើលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Initial Public Offering) ឬ IPO។

១.១.២.៤. ទីផ្សារបន្ទាប់

ដោយសារវិនិយោគិនមួយចំនួនយល់ថា ការប្រើប្រាស់មូលធនរបស់គេមិនមានការកំណត់ជាក់លាក់ដូចនេះហើយភាគច្រើននៃមូលបត្រអាចចរចារទិញលក់បាន។ នេះមានន័យថា ភាគហ៊ុនអាចផ្លាស់ប្តូរបានដោយសេរីពីអ្នកលក់ម្នាក់ទៅអ្នកទិញម្នាក់ទៀតដោយតម្លៃកំណត់មួយដែលមានការព្រមព្រៀង និងការពេញចិត្តដោយភាគីទាំងពីរតាមរយៈការផ្តល់ភាគហ៊ុនទៅអ្នកទិញ។ ប័ណ្ណកម្មសិទ្ធិស្របច្បាប់របស់ភាគហ៊ុននឹងត្រូវបានផ្ទេរឱ្យអ្នកទិញនៅពេលដែលភាគហ៊ុនផ្តល់មកឱ្យភាគីអ្នកទិញ។ ការកំណត់ថ្លៃ និងការផ្តល់កម្មសិទ្ធិលើមូលបត្រកើតឡើងនៅកន្លែងមួយដែលគេស្គាល់ថាជាទីផ្សារបន្ទាប់។ ទីផ្សារបន្ទាប់ គឺជាទីកន្លែងដែលជួញដូរមូលបត្រត្រូវបានកើតឡើងជាប្រចាំរវាងអ្នកលក់ និងអ្នកទិញមូលបត្រ។ ទឹកប្រាក់ដែលកើតចេញពីសកម្មភាពជួញដូរនេះ ត្រូវបង់ទៅឱ្យភាគហ៊ុនិកដែលលក់ មិនមែនឱ្យទៅក្រុមហ៊ុនបោះផ្សាយដំបូងនោះទេ។ ក្រុមហ៊ុនបោះផ្សាយមូលបត្រ មិនទទួលបានផលចំណេញជាហិរញ្ញវត្ថុនៃការជួញដូរមូលបត្រកើនឡើងនៅលើទីផ្សារបន្ទាប់ទេ ហើយមូលបត្រទាំងអស់ដែលជួញដូរនៅទីផ្សារបន្ទាប់អាចត្រូវបានជួញដូរនៅក្នុងទីផ្សារមូលបត្រ ឬនៅក្រៅពីទីផ្សារមូលបត្រ ដែលហៅថាទីផ្សាររំលងបញ្ជា។

វាជាមុខងារនៃទីផ្សារមូលបត្រ និងទីផ្សាររំលងបញ្ជាក្នុងការផ្តល់ទីកន្លែងមួយក្នុងការកំណត់តម្លៃភាគហ៊ុនព្រមទាំងការផ្តល់មូលបត្រទៅឱ្យអ្នកទិញ[5]។

១.១.២.៥. ទីផ្សារមូលបត្រប្រតិស្រុត

ចរិកលក្ខណៈគតិយុត្តសំខាន់ៗរបស់ទីផ្សារមូលបត្រប្រតិស្រុត រួមមាន៖ ១-ទីផ្សារមូលបត្រប្រតិស្រុតជា

[5] បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១១, ទំព័រទី ១៦ ១៧ និង១៨)

ទីផ្សារដែលត្រូវបានបង្កើតឡើងដោយប្រតិករទីផ្សារមូលបត្រដែលត្រូវបានទទួលស្គាល់ និងស្ថិតនៅក្រោមការត្រួតពិនិត្យដោយអាណាព្យាបាលលើវិស័យមូលបត្រ មានន័យថាដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក), ២-ទីផ្សារមូលបត្រប្រតិស្រុតជាទីផ្សាររូបីដែលមានទីកន្លែងអនុញ្ញាឱ្យជើងសារ ឬពាណិជ្ជករមូលបត្រអាចជួបមុខគ្នាជាសារវ័ន្តជួញដូរមូលបត្រនៅលើទីផ្សារបាន (Marketing/Exchange floor) និង ៣-ទីផ្សារមូលបត្រប្រតិស្រុតជាទីផ្សារដែលមានវិធានដំណើរការ និងវិធានប្រតិបត្តិការសម្រាប់ការជួញដូរមូលបត្រច្បាស់លាស់ ហើយរាល់ការជួញដូរមូលបត្រចាំបាច់ត្រូវតែគោរពតាមវិធានប្រតិបត្តិការនេះតឹងរឹង។ ជាទូទៅ ទីផ្សារប្រតិស្រុតជាទីផ្សារដែលការជួញដូរធ្វើឡើងតាមប្រព័ន្ធដេញថ្លៃរវាងអ្នកទិញនិងអ្នកលក់ទាំងអស់ (Auction Market) ឬជាទីផ្សារដែលនាំមុខដោយបញ្ជា (Order Driven Market)។

១.១.២.៦.ទីផ្សាររំលងបញ្ជា

ទីផ្សាររំលងបញ្ជា ជាទីផ្សារដែលមិនមានបញ្ជា ឬទីកន្លែង និងមិនមានរចនាសម្ព័ន្ធទីផ្សារច្បាស់លាស់នោះទេ។ ការជួញដូរមូលបត្រនៅលើទីផ្សាររំលងបញ្ជា គឺធ្វើឡើងតាមរយៈប្រព័ន្ធអេឡិចត្រូនិច ដូចជា តាមរយៈទូរស័ព្ទ ឬទូរសារជាដើម និងរវាងពាណិជ្ជករមូលបត្រ និងពាណិជ្ជករមូលបត្រ ឬរវាងវិនិយោគិនធំៗ ដែលមានទំនាក់ទំនងដោយផ្ទាល់ជាមួយគ្នា។ ទីផ្សាររំលងបញ្ជាត្រូវបានគេចាត់ទុកថាជាបណ្តាញជួញដូររវាងពាណិជ្ជករមូលបត្រ (Dealer Network) ឬទីផ្សារដែលបង្កើតឡើងដោយពាណិជ្ជករមូលបត្រ (Dealer Market)។ ជាគោលការណ៍ ការជួញដូរនៅលើទីផ្សាររំលងបញ្ជាមិនតម្រូវឱ្យគោរពតាមវិធានប្រតិបត្តិការណាមួយនោះទេ ពោលគឺការជួញដូរត្រូវធ្វើឡើងតាមរយៈការព្រមព្រៀងរវាងគូរភាគី ជាពិសេសលើការកំណត់ថ្លៃ និងចំនួនមូលបត្រ។ មូលបត្រមួយអាចលក់ក្នុងពេលតែមួយក្នុងតម្លៃខុសគ្នានៅលើទីផ្សាររំលងបញ្ជា។ ការជួញដូរមិនមានលក្ខណៈជាការប្រមូលផ្តុំដូចជាទីផ្សារប្រតិស្រុតនោះទេ។ អ្នកលក់មូលបត្រត្រូវស្វែងរកទិញមូលបត្រ ហើយចំពោះតម្លៃអាចធ្វើការចរចាគ្នាបានដោយសេរី។ ហេតុដូចនេះទើបគេហៅថាទីផ្សាររំលងបញ្ជាថាជាទីផ្សារដែលនាំមុខដោយការដាក់ថ្លៃ[6]។

១.១.៣. មុខងារនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ មានមុខងារសំខាន់ជាមូលដ្ឋានពីរយ៉ាងគឺ៖

១.១.៣.១. មុខងារបង្កើតដើមទុន

ទីផ្សារមូលបត្រ ជាទីកន្លែងប្រជុំវិនិយោគិនទាំងអស់ដែលមានទុនដើម្បីវិនិយោគ នៅក្នុងក្រុមហ៊ុនបោះផ្សាយមូលបត្រទាំងឡាយណា ដែលស្វែងរកទុនដើម្បីបង្កើនមូលធនរបស់ខ្លួន។

[6] ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៥, ទំព័រទី ៣៧ និង ៣៨)

១.១.៣.២. មុខងារសន្ទនីយភាព

មុខងារសន្ទនីយភាព គឺជាលទ្ធភាពក្នុងការលក់ឧបករណ៍វិនិយោគនៅក្នុងទីផ្សារមូលបត្រ។ ទីផ្សារមូលបត្រផ្តល់សន្ទនីយភាពតាមរយៈការផ្តល់ជាទីកន្លែងជួញដូរ (តាំងនៅទីកន្លែង និងតាមប្រព័ន្ធ អេឡិចត្រូនិច) ដែលក្នុងនោះអ្នកទិញនិងអ្នកលក់ជួបគ្នាដើម្បីព្រមព្រៀងតម្លៃ និងធ្វើការជួញដូរមូលបត្រ។ សកម្មភាពនេះផ្តល់សន្ទនីយភាពក្នុងការទិញ និងលក់មូលបត្រនៅក្នុងទីផ្សារមូលបត្រ[7]។

១.១.៤. តួអង្គសំខាន់ៗក្នុងទីផ្សារមូលបត្រ

ទីផ្សារមូលបត្រ ត្រូវបានបង្កើតឡើងស្របតាមទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុស៊ីជម្រៅ និងគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។ រហូតមកដល់ពេលនេះ អត្ថិភាពជាអង្គ ៤ ជាសារវន្តដែលគាំទ្រដល់ដំណើរការនៃទីផ្សារមូលបត្រ ត្រូវបានកសាងជាបន្តបន្ទាប់រួមមាន៖

១.១.៤.១. ហេដ្ឋារចនាសម្ព័ន្ធ (Infrastructure)

ហេដ្ឋារចនាសម្ព័ន្ធ សំដៅដល់បទដ្ឋានគតិយុត្តផ្សេងៗដូចជា ច្បាប់ បទប្បញ្ញត្តិ ដែលបង្កើតឡើងដោយនិយ័តករមូលបត្រដើម្បីគ្រប់គ្រងទីផ្សារមូលបត្រ ឱ្យមានប្រសិទ្ធភាព សមធម៌ តម្លាភាព និងសណ្តាប់ធ្នាប់។ ជាមួយគ្នានេះហេដ្ឋារចនាសម្ព័ន្ធទីផ្សារមូលបត្រ គឺសំដៅដល់ប្រព័ន្ធជួញដូរ រក្សាទុក និងផាត់ទាត់ និងទូទាត់មូលបត្រផងដែរ។ នាពេលបច្ចុប្បន្ននេះ មូលបត្រភាគច្រើនមិនមែនជាប្រភេទក្រដាសដូចសម័យមុននោះទេ។ មូលបត្រត្រូវបានកត់ត្រា រក្សាទុក និងជួញដូរនៅក្នុងប្រព័ន្ធបច្ចេកវិទ្យាកុំព្យូទ័រទាំងអស់។ នៅកម្ពុជា និយ័តករមូលបត្រដែលបង្កើតបទដ្ឋានគតិយុត្តទីផ្សារមូលបត្រនោះគឺ គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)។ ចំណែកឯប្រព័ន្ធជួញដូររក្សាទុក និងផាត់ទាត់ ទូទាត់មូលបត្រត្រូវបានផ្តល់ដោយ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

១.១.៤.២. អន្តរការីផ្សារមូលបត្រ (Intermediary)

អន្តរការីផ្សារមូលបត្រមាននាទី ជួយសម្របសម្រួល ផ្តល់ប្រឹក្សាជូនដល់ក្រុមហ៊ុនដែលមានបំណងចង់បោះផ្សាយលក់មូលបត្រ ព្រមទាំងធានាឱ្យបាននូវការបោះផ្សាយលក់មូលបត្រដែលប្រកបដោយជោគជ័យ។ ជាពិសេស អន្តរការីធ្វើការទំនាក់ទនងផ្តល់ប្រឹក្សាក៏ដូចជាផ្តល់មធ្យោបាយជួញដូរដល់វិនិយោគិនផងដែរ។ បើគ្មានអន្តរការីនោះទេ នោះពុំមានស្ពានតភ្ជាប់ក្រុមហ៊ុនបោះផ្សាយទៅកាន់និយ័តករ និងមូលបត្រនោះឡើយ ហើយក៏គ្មានអ្នកទាក់ទាញវិនិយោគិនទិញមូលបត្រជូនក្រុមហ៊ុនបោះផ្សាយលក់មូលបត្រនោះដែរ។

[7] បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១១, ទំព័រទី ៨)

១.១.៤.៣. ក្រុមហ៊ុនចេះផ្សាយ (Issuer)

តួអង្គសំខាន់បំផុតមួយទៀតនៅក្នុងទីផ្សារមូលបត្រ គឺក្រុមហ៊ុនចេះផ្សាយលក់មូលបត្រជាសាធារណៈ ព្រោះបើគ្មានក្រុមហ៊ុនចេះផ្សាយនោះទេ ក៏គ្មានមូលបត្រសម្រាប់លក់ និងជួញដូរនៅលើទីផ្សារដែរ។ តួនាទីដ៏សំខាន់របស់ទីផ្សារមូលបត្រ គឺជួយផ្តល់ដើមទុនបន្ថែមដល់ក្រុមហ៊ុនចេះផ្សាយ ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។

១.១.៤.៤. វិនិយោគិន (Investor)

វិនិយោគិនជាតួអង្គសំខាន់មួយ ក្នុងចំណោមតួអង្គទាំងបួន ព្រោះបើគ្មានវិនិយោគិន ក៏ការចេះផ្សាយលក់ និង/ឬ ជួញដូរមូលបត្រមិនជោគជ័យដែរ។ វិនិយោគិនសំដៅដល់សាធារណៈជនទូទៅ ឬស្ថាប័នដែលបានទិញមូលបត្រ។[8]

១.១.៥. គុណសម្បត្តិនិងគុណវិបត្តិនៃទីផ្សារមូលបត្រ

១.១.៥.១. គុណសម្បត្តិនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្របានដើរតួយ៉ាងសំខាន់ចំពោះសេដ្ឋកិច្ចជាពិដូចជា៖

- ទីផ្សារមូលបត្រជួយជំរុញឱ្យមហាជនបង្កើននូវការសន្សំ និងកៀរគរមូលធនដែលនៅសេសសល់ មិនមានតម្រូវការប្រើប្រាស់យកទៅវិនិយោគក្នុងសេដ្ឋកិច្ច
- ទីផ្សារមូលបត្រ គឺជាមធ្យោបាយជួយប្រមែប្រមូលកៀរគរប្រភពធនធាននៅទំនេរតូចៗ មិនទាន់មានតម្រូវការប្រើប្រាស់ប្រមូលផ្តុំជាមូលធនធំមួយ ដើម្បីវិនិយោគក្នុងវិស័យសេដ្ឋកិច្ច
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយជួយសម្រួលដល់រាជរដ្ឋាភិបាល ក្នុងការអនុវត្តននូវកម្មវិធីអភិវឌ្ឍន៍សេដ្ឋច្ចជាតិឱ្យរីកចម្រើន
- ទីផ្សារមូលបត្រ គឺជាឧបករណ៍មួយដើម្បីទាក់ទាញ និងស្រូបនូវមូលធនពីបរទេស
- ទីផ្សារមូលបត្រ ជួយជំរុញឱ្យបណ្តាក្រុមហ៊ុននានា ធ្វើអាជីវកម្មប្រកបដោយប្រសិទ្ធិភាព និងអភិបាលកិច្ចល្អ
- ទីផ្សារមូលបត្រ ជួយជំរុញឱ្យប្រភពធនធានក្នុងស្រុកមានចរាចរ មានចលនារស់រវើក
- ទីផ្សារមូលបត្រ ជួយបង្កើតនូវទម្លាប់វិនិយោគ

១.១.៥.២. គុណវិបត្តិនៃទីផ្សារមូលបត្រ

ទីផ្សារមូលបត្រមានគុណវិបត្តិ មួយចំនួនដែលគេតែងតែជួប្រទះនូវបញ្ហាដូចខាងក្រោម ៖

- ការឆក់ឱកាសកេងចំណេញក្នុងការជួញដូរ (Speculation) គឺជាការទិញលក់មួយដែលមានការគិរគូរ

[8] https://www.serc.gov.kh/khmer/m46.php?pn=2 No8 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)

យ៉ាងហ្មត់ចត់ដើម្បីទទួលបានផលចំណេញដោយប្រឈមនឹងហានិភ័យ។ អ្នកឆក់ឱកាសកេងចំណេញក្នុងការជួញដូរនេះអាចធ្វើការជួញដូរភាគហ៊ុននាពេលបច្ចុប្បន្ន ដោយរំពឹងថានាពេលអនាគតនឹងទទួលបានប្រាក់ចំណេញទៅតាមការជួញដូរមួយលើកៗ។ ឆក់ឱកាសកេងចំណេញក្នុងការជួញដូររបៀបនេះវានឹងបង្ករឱ្យមានឥទ្ធិពលដល់តម្លៃភាគហ៊ុន។ ព្រឹត្តិការណ៍នេះធ្វើឱ្យមានភាពងាយស្រួលនៅពេលពួកគេព្រមព្រៀងគ្នាក្នុងការជួញដូរដែលនាំឱ្យស្ថានភាពនៅលើទីផ្សារ មានពេលខ្លះធ្វើឱ្យភាគហ៊ុនខ្វះ ឬលើសហើយធ្វើឱ្យមានចលនាឡើងចុះតម្លៃនៃការជួញដូរមូលបត្រនៅលើទីផ្សារមូលបត្រ។

- ការជួញដូរផ្ទៃក្នុង គឺមានបុគ្គលជាបុគ្គលិករបស់ក្រុមហ៊ុនចុះបញ្ជីឆ្លៀតឱកាសយកព័ត៌មានផ្ទៃក្នុងរបស់ក្រុមហ៊ុនដើម្បីធ្វើការជួញដូរភាគហ៊ុន ដើម្បីស្វែងរកប្រាក់ចំណេញរបស់ខ្លួនដែលមានឥទ្ធិពលដល់តម្លៃភាគហ៊ុនរបស់ទីផ្សារមូលបត្រ ដែលព័ត៌មាននេះ មិនមែនជាព័ត៌មានសាធារណៈ (ព័ត៌មានសម្ងាត់)។
- ការជួញដូរក្លែងក្លាយ និងការប្រើឧបាយកលក្នុងទីផ្សារ គឺជាការធ្វើសកម្មភាពណាមួយ ឬគេចវេះមិនធ្វើសកម្មភាពដែលបណ្តាលឱ្យ ឬអាចបណ្តាលឱ្យលក្ខណៈក្លែងបន្លំ ឬនាំឱ្យមានការយល់ខុសចំពោះការជួញដូរមូលបត្រ ឬធ្វើប្រតិបត្តិការផែនការជួញដូរ ដែលមានលក្ខណៈសិប្បនិម្មិតទាក់ទិននឹងមូលបត្រនៅលើទីផ្សារមូលបត្រកម្ពុជា។
- សេចក្តីថ្លែងការ ឬការផ្សព្វផ្សាយព័ត៌មានក្លែងបន្លំ ឬដែននាំឱ្យមានការយល់ខុសធ្ងន់ធ្ងរ ដែលបណ្តាលឱ្យមានសាធារណៈជនទិញលក់មូលបត្រ ឬបណ្តាលឱ្យមានការកើនឡើង ឬការថយចុះ ឬនៅថេរចំពោះតម្លៃនៃការជួញដូរនៅក្នុងទីផ្សារមូលបត្រកម្ពុជា។
- ក្រុមហ៊ុនដែលបោះពុម្ពផ្សាយលក់មូលបត្រ តម្រូវឱ្យមានបញ្ជីគណនេយ្យច្បាស់លាស់ មានតម្លាភាព និងអភិបាលកិច្ចអាជីវកម្មល្អ ដែលទាំងនេះជាបន្ទុកមួយសម្រាប់ក្រុមហ៊ុន ប៉ុន្តែក្រុមហ៊ុនបានផ្លែផ្កាមកវិញនូវទុនរយៈពេលវែងក្នុងតម្លៃថោកសមរម្យសម្រាប់ពង្រីកអាជីវកម្មរបស់ខ្លួន។[9]

១.២. មូលបត្រ

១.២.១. និយមន័យ

មូលបត្រ គឺជាកិច្ចសន្យាហិរញ្ញវត្ថុដែលអាចជួញដូរបាន ដែលកិច្ចសន្យានេះបញ្ជាក់ពីភាពជាម្ចាស់កម្មសិទ្ធិឬម្ចាស់បំណុលលើក្រុមហ៊ុនមួយ ហើយយើងក៏អាចធ្វើការជួញដូរមូលបត្រនេះបានដែរ។[10]

[9] http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)

[10] https://www.linkedin.com (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២២)

១.២.២. ប្រភេទនៃមូលបត្រ

មានប្រភេទខុសៗគ្នានៃមូលបត្រ ដែលត្រូវបានគេធ្វើការជួញដូរនៅលើទីផ្សារមូលបត្រ ប៉ុន្តែគេអាចធ្វើការបែងចែកមូលបត្រជាពីរប្រភេទធំៗ ពោលគឺ៖ (១) មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុន (Stock) និង (២) មូលបត្របំណុល (Bond) ឬសញ្ញាប័ណ្ណ។

១.២.២.១. មូលបត្រកម្មសិទ្ធិ (ប្រភេទភាគហ៊ុន)

មូលបត្រកម្មសិទ្ធិ ឬភាគហ៊ុនតំណាងឱ្យភាពម្ចាស់នៃក្រុមហ៊ុន។ វិនិយោគិនអាចទទួលបានផលចំណេញពីភាគហ៊ុនតាមវិធីពីរយ៉ាង ពោលគឺ (១)តាមរយៈការលក់ចេញពេលហ៊ុនឡើងថ្លៃ ឬ(២)តាមរយៈការទទួលបានភាគលាភ។

ការវិនិយោគលើភាគហ៊ុនមានហានិភ័យជាងការវិនិយោគលើសញ្ញាប័ណ្ណ ពីព្រោះថាអ្នកកាន់កាប់ភាគហ៊ុនមានអាទិភាពជាងអ្នកកាន់កាប់សញ្ញាប័ណ្ណនៅពេលក្រុមហ៊ុនមានបញ្ហា ហើយភាគហ៊ុនអាចផ្លាស់ប្តូរអាស្រ័យតាមប្រាក់ចំណេញរបស់ក្រុមហ៊ុន។ ទោះជាយ៉ាងណាក្តី ការវិនិយោគជាមួយភាគហ៊ុនអាចនឹង មានផលចំណេញច្រើនជាងសញ្ញាប័ណ្ណ។

ភាគហ៊ុនធម្មតា (Common Stock)

ភាគហ៊ុនធម្មតា គឺជាមូលបត្រទ្រព្យដែលមិនមានរយៈពេលកំណត់ គឺតាមស្ថេរភាពរបស់ក្រុមហ៊ុនដែលត្រូវបានបែងចែកភាគលាភនៅចុងឆ្នាំ។ ភាគហ៊ុនធម្មតាជាភាគហ៊ុនដែលទទួលបានការលើកទឹកចិត្តដោយផ្ទាល់ដល់អ្នកកាន់កាប់ភាគហ៊ុន តាមរយៈភាគលាភដែលទទួលបានពីប្រាក់ចំណេញរបស់ក្រុមហ៊ុន ការចំណេញលើមូលធន និងសិទ្ធិក្នុងការទិញភាគហ៊ុនថ្មីរបស់ក្រុមហ៊ុននៅពេលដែលក្រុមហ៊ុនសម្រេចនៅក្នុងការបង្កើនដើមទុនចុះបញ្ជីរបស់ខ្លួន ហើយតម្លៃបច្ចុប្បន្នរបស់ភាគហ៊ុនធម្មតាអាចប្រែប្រួលទៅតាមការរីកចម្រើនរបស់ក្រុមហ៊ុន។

លក្ខណៈរបស់វាមានដូចជា៖

- ភាគលាភមិនកំណត់ គឺអាស្រ័យលើផលចំណេញជាក់ស្តែងរបស់ក្រុមហ៊ុនដែលទទួលបានរាល់ឆ្នាំ និងគោលការណ៍បែងចែកផលចំណេញរបស់ក្រុមហ៊ុន។ ប្រសិនបើក្រុមហ៊ុនចំណេញច្រើនពីប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួននោះ បណ្តាម្ចាស់ភាគហ៊ុនធម្មតាក៏ទទួលបានភាគលាភច្រើនដែរ តែបើក្រុមហ៊ុនខាតបង់ពីប្រតិបត្តិការពាណិជ្ជកម្មរបស់ខ្លួនវិញនោះ ម្ចាស់ភាគហ៊ុនក៏មិនអាចទទួលបានភាគលាភដែរ

- បណ្តាម្ចាស់ភាគហ៊ុនធម្មតាភាគច្រើនទទួលបាននូវសិទ្ធិមួយចំនួនដូចជា ត្រូវបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាល ចូលរួមបោះឆ្នោតក្នុងការសម្រេចចិត្តលើទិសដៅ និងគោលនយោបាយរបស់ក្រុមហ៊ុនជាដើម។
- នៅពេលដែលក្រុមហ៊ុនដួលរលំ ឬពេលក្រុមហ៊ុនក្ស័យធន ម្ចាស់ភាគហ៊ុនទាំងនោះនឹងត្រូវបានបែងចែកប្រាក់ដែលសល់ក្រោយពេលដែលបានទូទាត់បណ្តាបរិមាណបំណុល និងទូទាត់ឱ្យម្ចាស់ភាគហ៊ុនបុរិមា (Preferred Stock) រួចរាល់។

❖ **ភាគហ៊ុនបុរិមា (Preferred Stock)**

ភាគហ៊ុនបុរិមា ផ្តល់ឱ្យអ្នកវិនិយោគនូវហានិភ័យនៃការខាតបង់ប្រាក់វិនិយោគតិចជាងការកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោត ប៉ុន្តែក៏ផ្តល់នូវចំណូលសរុបមានកំណត់ផងដែរ។ ចំណូលដែលអាចទទួលបានពីការវិនិយោគលើភាគហ៊ុនបុរិមារួមមាន ចំណូលដែលទទួលបានពីការវិនិយោគជាភាគលាភបូកជាមួយការប្រែប្រួលតម្លៃណាមួយរបស់ភាគហ៊ុននៅលើទីផ្សារ។

ជាទូទៅអ្នកកាន់កាប់ភាគហ៊ុនបុរិមា មានលក្ខណៈដូចគ្នានឹងអ្នកកាន់កាប់ភាគហ៊ុនធម្មតាដែរ ប៉ុន្តែខុសគ្នាត្រង់អ្នកកាន់កាប់ភាគហ៊ុនបុរិមា អាចមានសិទ្ធិទទួលបានភាគហ៊ុនមុនពេលនៅពេលបែងចែក ហើយភាគលាភត្រូវបានកំណត់ជាក់លាក់ពីដំបូងនៅលើទឹកប្រាក់កំណត់មួយ បន្ថែមពីនេះអ្នកកាន់កាប់ភាគហ៊ុនបុរិមាពុំមានសិទ្ធិក្នុងការបោះឆ្នោតផ្សេងៗនោះទេ។ ម៉្យាងទៀតភាគហ៊ុនបុរិមា មានលក្ខណៈពិសេសដែលអាចប្តូរទៅជាភាគហ៊ុនធម្មតាបាននៅពេលវាបំពេញទៅតាមលក្ខខណ្ឌដែលបានចុះក្នុងភាគហ៊ុនបុរិមានោះ[11]។

១.២.២.២. **មូលបត្របំណុល (ប្រភេទបំណុល)**

មូលបត្របំណុល ឬសញ្ញាប័ណ្ណ គឺជាមូលបត្រដែលបញ្ជាក់ពីបំណុលរយៈពេលវែងរបស់អ្នកបោះផ្សាយ ហើយអ្នកបោះផ្សាយត្រូវមានមុខងារសងការប្រាក់ និងតម្លៃសញ្ញាប័ណ្ណដល់ម្ចាស់កម្មសិទ្ធិសញ្ញាប័ណ្ណនៅពេលដល់កាលកំណត់សងរបស់សញ្ញាប័ណ្ណ។ សម្រាប់អ្នកវិនិយោគលើប័ណ្ណបំណុលនោះនឹងទទួលបាននូវអត្រាការប្រាក់ថេរមួយអាស្រ័យទៅលើជំនាន់មួយដែលបានកំណត់ជាស្រេច ទោះបីជាអត្រាការប្រាក់នៅលើទីផ្សារមានការប្រែប្រួលយ៉ាងណាក៏ដោយ។

សញ្ញាប័ណ្ណត្រូវបានបែងចែកជាច្រើនប្រភេទខុសៗគ្នា ដោយផ្អែកទៅតាមអ្នកបោះផ្សាយតាមកាលកំណត់សងជាដើម ប៉ុន្តែយើងធ្វើការបែងចែកសញ្ញាប័ណ្ណដែលផ្អែកទៅលើអ្នកបោះផ្សាយវិញនោះ យើងអាចបែងចែកសញ្ញាប័ណ្ណជាពីរប្រភេទធំៗដាច់ដោយឡែកពីគ្នា៖

[11] បៀន សាំង, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១១, ទំព័រទី ៣៥.៣៦)

❖ សញ្ញាប័ណ្ណរដ្ឋ

- Treasury/Government Bill (T-bill) ៖ ប័ណ្ណរតនាគាររយៈពេលខ្លី ជាប្រភេទមូលបត្របំណុលដែលទទួលបានចំណូលថេរ ហើយគ្មានហានិភ័យចេញដោយរាជរដ្ឋាភិបាល និងមានរយៈពេលតិចជាង១ឆ្នាំ
- Treasury/ Government Note (T-notes) ៖ ជាប្រភេទមូលបត្រដែលបោះដោយរាជរដ្ឋាភិបាល និងចេញដោយក្រសួងរតនាគារ មានរយៈពេលជាមធ្យម ១ឆ្នាំ ទៅ ២ឆ្នាំ
- Treasury/Government Bond (T-Bond) ៖ ជាប័ណ្ណបំណុលដែលមានរយៈពេលលើសពី១០ឆ្នាំ។[12]

❖ សញ្ញាប័ណ្ណអាជីវកម្ម

សញ្ញាប័ណ្ណអាជីវកម្ម គឺជាប្រភេទមូលបត្រដែលបោះផ្សាយដោយក្រុមហ៊ុនសាជីវកម្មក្នុងគោលដៅប្រមូលមូលធនបណ្តោះអាសន្ន បន្ថែមលើមូលធនដែលមានស្រាប់សម្រាប់យកមកធ្វើការពង្រីកអាជីវកម្មបន្ថែមទៀត។ សញ្ញាប័ណ្ណសាជីវកម្មអាចបោះផ្សាយលក់ជាសាធារណៈក្នុងជាទម្រង់ ៖ មូលបត្រដាក់បញ្ចាំ (Mortgage Bond) សញ្ញាប័ណ្ណដែលអាចប្តូរបាន (Convertible Bond) សញ្ញាប័ណ្ណដែលមានលក្ខខណ្ឌប័ណ្ណសន្យា (Zero Coupon Bond) ផលបត្រពាណិជ្ជកម្ម (Commercial Paper) ជាដើម។

ជាទូទៅការវិនិយោគលើសញ្ញាប័ណ្ណទទួលបានការចាប់អារម្មណ៍ខ្លាំង ដោយសារវាផ្តល់នូវអត្ថប្រយោជន៍ជាច្រើនទាំងក្រុមហ៊ុនវិនិយោគិនសាធារណៈ និងរដ្ឋ ដូចជា៖

- **ចំពោះក្រុមហ៊ុន៖** ក្រៅពីការបោះផ្សាយភាគហ៊ុនដើម្បីប្រមូលមូលធនបន្ថែមនៅអាចបោះផ្សាយសញ្ញាប័ណ្ណដែលអាចធ្វើហិរញ្ញប្បទានរយៈពេលវែងបានដូចគ្នា ប៉ុន្តែសញ្ញាប័ណ្ណមិនអាចធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ និងភាពជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុននោះ។ ម៉្យាងវិញទៀតក្រុមហ៊ុនចំណេញការប្រាក់ លើសញ្ញាប័ណ្ណនោះមានកម្រិតទាប ដែលវាផ្តល់ភាពងាយស្រួល និងផលចំណេញជាច្រើនដល់ក្រុមហ៊ុនក្នុងការប្រមូលមូលធនបន្ថែម។

- **ចំពោះវិនិយោគិនសាធារណៈ៖** ការវិនិយោគលើសញ្ញាប័ណ្ណមានកម្រិតហានិភ័យទាបជាពិសេសលើការវិនិយោគលើប័ណ្ណរតនាគារជាតិ (ជាសញ្ញាប័ណ្ណមានហានិភ័យ)។ ជាទូទៅសញ្ញាប័ណ្ណមានតម្លៃចរិកទាបដែលធ្វើឱ្យមានភាពងាយស្រួលដល់វិនិយោគិនក្នុងការវិនិយោគ និងទទួលបានការប្រាក់ថេរពីសញ្ញាប័ណ្ណទាំងនោះ។

[12]ឈាង ម៉េងហៀក, មូលដ្ឋានគ្រឹះនៃវិនិយោគ (បោះពុម្ពឆ្នាំ ២០២០-២០២១, ជំពូកទី១ ទំព័រទី១៦)

➢ **ចំពោះរដ្ឋ ៖** សញ្ញាប័ណ្ណបានផ្តល់ឱ្យរដ្ឋនូវហិរញ្ញប្បទានរយៈពេលវែងមួយ ក្នុងការវិនិយោគគម្រោងធំៗ (ការសាងសង់សាលារៀនហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាដើម ដែលផ្តល់ជាប្រយោជន៍សាធារណៈជនទូទៅ ដោយរដ្ឋធ្វើការចំណាយការប្រាក់ទាបជាជាងកម្ចីពីធនាគារ ឬកម្ចីពីបរទេស។

❖ ភាពខុសគ្នារវាងមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល មានដូចជា៖[13]

➢ មូលបត្រកម្មសិទ្ធិ

- ជាប្រភេទប័ណ្ណកម្មសិទ្ធិ
- ជាម្ចាស់កម្មសិទ្ធិនៅពេលទិញ Stock
- ទទួលបានភាគលាភ
- មិនមានការសងការប្រាក់ដើមទេ
- មានសិទ្ធិក្នុងការបោះឆ្នោត
- ទទួលបានប្រាក់ចំណេញនាពេលអនាគត
- នៅពេលក្រុមហ៊ុនក្សីយធុនលក់ Assets ឡៃឡុងយកមូលបត្រមកទូទាត់ក្រោយមូលបត្របំណុល និងទទួលបាននៅក្នុងកម្រិតទាបជាងមូលបត្របំណុល
- ក្រុមហ៊ុនសារជីវកម្មជាអ្នកចេញប័ណ្ណ។

➢ មូលបត្របំណុល

- ជាប្រភេទប័ណ្ណបំណុល
- ពេលទិញមូលបត្របំណុលយើងក្លាយជាម្ចាស់បំណុល
- ទទួលអត្រាការប្រាក់
- ទទួលបានការសងការប្រាក់ដើម (ទទួលបានចុងគ្រា)
- មិនមានសិទ្ធិក្នុងការបោះឆ្នោត
- មិនទទួលបានប្រាក់ចំណេញនាពេលអនាគត

[13] ហេង ចាន់ប៉ូលីន, ទីផ្សារមូលបត្រកម្ពុជា (ជំពូកទី១,ទំព័រទី ៦)

- នៅពេលក្រុមហ៊ុនក្សីយធុនលក់ Assets ឡែឡុង មូលបត្របំណុលទទួលបានការទូរទាត់មុនមូលបត្រកម្មសិទ្ធិ និងទទួលបាននៅក្នុងកម្រិតខ្ពស់ជាងមូលបត្រកម្មសិទ្ធិ

- រាជរដ្ឋាភិបាលជាអ្នកចេញប័ណ្ណ។

១.២.២.៣. ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរិវេទីវ (Derivative Instrument)

ឧបករណ៍និស្សន្ទ ឬឧបករណ៍ដេរិវេទីវ គឺជាឧបករណ៍ហិរញ្ញវត្ថុប្រភេទមួយនៃមូលបត្រ ដែលសំដៅដល់កិច្ចសន្យាគម្លាតតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុដើម ដែលមានប្រភពចេញពីមូលបត្រកម្មសិទ្ធិ មូលបត្របំណុល សន្ទស្សន៍ទីផ្សារលោហៈធាតុមានតម្លៃ ប្រេងឆៅ ឧស្ម័នធម្មជាតិ រួមទាំងរូបិយប័ណ្ណជាដើម ហើយត្រូវបានជួញដូរក្នុងទីផ្សារឧបករណ៍និទស្សន៍។[14]

១.៣. តួអង្គសំខាន់ៗក្នុងវិស័យមូលបត្រ

តួអង្គសំខាន់ៗដែលមិនអាចខ្វះបាននៅក្នុងវិស័យមូលបត្រ ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុងច្បាប់ស្តីពីមូលបត្រមហាជន។ តួអង្គទាំងនោះរួមមាន៖

១.៣.១. គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក)

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) ត្រូវបានបង្កើតឡើងដោយច្បាប់មូលបត្រមហាជន។ ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ គ.ម.ក ត្រូវបានកំណត់ដោយអនុក្រឹត្យ។ មុខងារសំខាន់ៗរបស់ គ.ម.ក ត្រូវបានកំណត់ក្នុងមាត្រា ៧ នៃច្បាប់។ យោងតាមមាត្រា ៧ នៃច្បាប់ស្តីពីមូលបត្រមហាជន គ.ម.ក មានមុខងារដូចខាង ក្រោម[15]៖

- គ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងទីផ្សារមូលបត្ររដ្ឋ
- ដាក់ឱ្យអនុវត្តន៍គោលនយោបាយដែលពាក់ព័ន្ធនឹងទីផ្សារមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់ការអនុញ្ញាតជូនប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករប្រព័ន្ធជាត់ទាត់ និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ
- កំណត់លក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនមូលបត្រ និងភ្នាក់ងាររបស់ក្រុមហ៊ុនមូលបត្រ
- លើកកម្ពស់ និងជំរុញដល់ការគោរពតាមលក្ខខណ្ឌនៃច្បាប់នេះ
- ដើរតួនាទីជាស្ថាប័នពិនិត្យ និងដោះស្រាយលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់នីតិបុគ្គលមានអាជ្ញាប័ណ្ណដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សមាជិកចូលរួម ឬអ្នកវិនិយោគ

[14] ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៥, ទំព័រទី ៧៧)

[15] ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន (ជំពូកទី២ មាត្រា៧ មុខងាររបស់គណៈកម្មការមូលបត្រកម្ពុជា)

- ពិគ្រោះយោបល់ជាមួយបុគ្គលដែលមានលក្ខណៈសម្បត្តិសមស្រប ដើម្បីបង្កើតគោលនយោបាយសម្រាប់ការអភិវឌ្ឍទីផ្សារមូលបត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបំពេញការងារផ្សេងទៀតដែលមានចែងអនុក្រឹត។

គណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) មានសិទ្ធិអំណាច និងមុខងារលើវិស័យមូលបត្រដូចជា៖

១.៣.១.១. សិទ្ធិអំណាចជាអាណាព្យាបាលលើវិស័យមូលបត្រ

គ.ម.ក ជាស្ថាប័នតែមួយគត់ដែលមានសិទ្ធិជាអាណាព្យាបាលក្នុងវិស័យមូលបត្រ។ គ.ម.ក ជាអ្នកគ្រប់គ្រង និងត្រួតពិនិត្យទីផ្សារមូលបត្រនៅកម្ពុជារួមទាំងទីផ្សារមូលបត្ររដ្ឋផងដែរ។ ក្នុងនាមជាអាណាព្យាបាល គ.ម.ក ជាអ្នកផ្តល់ការអនុញ្ញាត និងអាជ្ញាប័ណ្ណចំពោះបុគ្គលទាំងឡាយដែលធ្វើសកម្មភាពពាក់ព័ន្ធនឹងមូលបត្រ។ រាល់បុគ្គលទាំងអស់ដែលធ្វើសកម្មភាពអាជីវកម្មពាក់ព័ន្ធនឹងវិស័យមូលបត្រ ត្រូវទទួលបានការអនុញ្ញាត ឬអាជ្ញាប័ណ្ណជាមុនពី គ.ម.ក និងស្ថិតក្រោមការគ្រប់គ្រង និងត្រួតពិនិត្យពី គ.ម.ក ចំពោះសកម្មភាពទាំងឡាយក្នុងវិស័យមូលបត្រ។

១.៣.១.២. មុខងារជានិយ័តករក្នុងវិស័យមូលបត្រ

គ.ម.ក ជានិយ័តករក្នុងមូលបត្រ។ គ.ម.ក ជាអ្នករៀបចំបង្កើត និងដាក់អនុវត្តគោលនយោបាយ ដើម្បីអភិវឌ្ឍន៍ទីផ្សារមូលបត្រនៅកម្ពុជា។ គ.ម.ក ជាអ្នកកំណត់លក្ខខណ្ឌលម្អិតនានាលើលក្ខខណ្ឌដែលច្បាប់ និងអនុក្រឹតបានកំណត់។ ការបង្កើតទីផ្សារមូលបត្រ និងដំណើរការបោះផ្សាយក៏ដូចជាការឡើយប្រសិនបើ គ.ម.ក មិនទាន់បានកំណត់លក្ខខណ្ឌលម្អិតបន្ថែមនោះទេ។ រហូតមកដល់ពេលនេះ គ.ម.ក ក៏បានចេញ គោលការណ៍ណែនាំចំពោះនីតិវិធី និងយន្តការសំខាន់ៗនានាដើម្បីលើកកម្ពស់ និងធានាការយល់ដឹង និងការអនុវត្តនូវបទប្បញ្ញត្តិនានាប្រកបដោយប្រសិទ្ធិភាពខ្ពស់[16]។

១.៣.១.៣. មុខងារផ្សេងទៀត

ក្រៅពីមុខងារដ៏សំខាន់ខាងលើ គ.ម.ក ក៏មានសិទ្ធិដើរតួនាទីជាអ្នកសម្របសម្រួល និងដោះស្រាយវិវាទ និងសិទ្ធិពិសេសជាមន្ត្រីនគរបាលយុត្តិធម៌ផងដែរ[17]។

[16] ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៥, ទំព័រទី ៩៤-៩៥ និង ៩៦)

[17] មាត្រាទី១០ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

១.៣.២. ក្រុមហ៊ុនមូលបត្រនិងអាជីវកម្មមូលបត្រ

១.៣.២.១. អាជីវកម្មមូលបត្រ

តាមច្បាប់ អាជីវកម្មមូលបត្រត្រូវគិតទាំងសកម្មភាព៖

- **អាជីវកម្មជើងសារមូលបត្រ៖** *ការទិញ ឬលក់មូលបត្រក្នុងនាមជាភ្នាក់ងាររបស់បុគ្គលផ្សេងទៀត។* ក្នុងករណីនេះ ក្រុមហ៊ុនមូលបត្រតួនាទីជាតំណាងរបស់អតិថិជនហើយធ្វើការទិញ ឬលក់មូលបត្រទៅតាមការបញ្ជារបស់អតិថិជន។ នេះជាប្រតិបត្តិការក្នុងករណីគណនីអតិថិជន មានន័យថា អតិថិជនជាអ្នកទទួលនិងរ៉ាប់រងការចំណេញខាត។ ក្រុមហ៊ុនទទួលបាននូវកម្រៃសេវាពីអតិថិជន តែប៉ុណ្ណោះ។
- **អាជីវកម្មជួញដូរមូលបត្រ៖** *ការទិញ ឬលក់មូលបត្រដោយប្រើប្រាស់មូលនិធិរបស់ខ្លួន និងនាមខ្លួនឯង។* សកម្មភាពនេះជាប្រភេទ*អាជីវកម្មជួញដូរមូលបត្រ។* ក្នុងករណីនេះ ក្រុមហ៊ុនមូលបត្រដើរតួជាពាណិជ្ជករមូលបត្រហើយធ្វើការទិញ ឬលក់មូលបត្រក្នុងនាមខ្លួនឯង និងដោយប្រើប្រាស់មូលនិធិរបស់ខ្លួន ដូចជាអ្នកវិនិយោគសាធារណៈផ្សេងទៀតដែរ។ នេះជាប្រតិបត្តិការជួញដូរក្នុងគណនី ផ្ទាល់របស់ក្រុមហ៊ុនមូលបត្រ ពោលគឺ ក្រុមហ៊ុនមូលបត្រជាអ្នករ៉ាប់រងហានិភ័យនៃការជួញដូរផ្ទាល់ខ្លួន។
- **អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ៖** *ការផ្តល់ប្រឹក្សាអំពីវិនិយោគមូលបត្រ ឬការបោះផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនអ្នកវិនិយោគសាធារណៈ។* សកម្មភាពនេះ ជាប្រភេទអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ។ អាជីវកម្មផ្តល់ប្រឹក្សាវិនិយោគ រួមមាន ១-ការផ្តល់ប្រឹក្សាអំពីការវិនិយោគលើមូលបត្រដល់ អ្នកវិនិយោគសាធារណៈដោយទទួលបាននូវកម្រៃជើងសារ និង ២-ការបោះពុម្ពផ្សាយសេចក្តីវិភាគអំពីការវិនិយោគមូលបត្រជូនដល់អ្នកវិនិយោគសាធារណៈ។ ក្នុងករណីនេះ ក្រុមហ៊ុនមូលបត្រដើរតួនាទីជាអ្នកប្រឹក្សាវិនិយោគ។ សេវាផ្តល់ប្រឹក្សាវិនិយោគនេះ ជាការផ្តល់ប្រឹក្សាទៅឱ្យអ្នកវិនិយោគសាធារណៈក្នុងការសម្រេចចិត្តវិនិយោគលើមូលបត្រ។ អ្នកដែលជាគោលដៅនៃសេវានេះ គឺជាអ្នកវិនិយោគសាធារណៈ មិនមែនជាបុគ្គលផ្សេងទៀតដូចជាក្រុមហ៊ុនបោះផ្សាយនោះទេ។ អ្នកផ្តល់ប្រឹក្សាដល់ ក្រុមហ៊ុនបោះផ្សាយជាទីប្រឹក្សាវិជ្ជាជីវៈ។ ការផ្តល់ប្រឹក្សាវិនិយោគអាចត្រូវធ្វើឡើងដោយក្រុមហ៊ុនមូលបត្រ ឬដោយក្រុមហ៊ុនទីប្រឹក្សាវិនិយោគដែលទទួលបានអាជ្ញាប័ណ្ណដោយឡែក។ បច្ចុប្បន្នអាជ្ញាប័ណ្ណសម្រាប់ក្រុមហ៊ុនទីប្រឹក្សាវិនិយោគនេះត្រូវបានលុបចោលហើយ។
- **អាជីវកម្មធានាទិញមូលបត្រ៖** *ការចុះកិច្ចព្រមព្រៀងធានា ជាមួយក្រុមហ៊ុនដែលធ្វើសំណើលក់ ឬទិញមូលបត្រ ឬចុះកិច្ចព្រមព្រៀងធានាទិញ ឬលក់បន្ត។* សកម្មភាពនេះជាសកម្មភាពធានាទិញ។ អាជីវកម្មធានាទិញនេះ ជាអាជីវកម្មដែលធ្វើឡើងតែជាមួយក្រុមហ៊ុនបោះផ្សាយតែប៉ុណ្ណោះ ដើម្បីធានាទិញការបោះផ្សាយរបស់ក្រុមហ៊ុននេះហើយធ្វើឡើងតាមរយៈកិច្ចសន្យាធានាទិញ។

១.៣.២.២. ប្រភេទអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនមូលបត្រ

បុគ្គលដែលមានបំណងធ្វើអាជីវកម្មមូលបត្រណាមួយ ឬទាំងអស់ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីអគ្គនាយកនៃ គ.ម.ក។ លក្ខខណ្ឌលម្អិតនៃការផ្តល់អាជ្ញាប័ណ្ណ ត្រូវបានកំណត់ដោយអនុក្រឹតអនុវត្តតាមច្បាប់មហាជន និងដោយ គ.ម.ក។ យោងតាមការប្រកាសស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និងភ្នាក់ងារមូលបត្រ អាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនមូលបត្រមាន ៤ប្រភេទគឺ អាជ្ញាប័ណ្ណជាក្រុមហ៊ុនធានាទិញមូលបត្រ អាជ្ញាប័ណ្ណជាពាណិជ្ជករមូលបត្រ អាជ្ញាប័ណ្ណជាឈ្មួញជើងសារមូលបត្រ និងអាជ្ញាប័ណ្ណជាក្រុមហ៊ុនប្រឹក្សាវិនិយោគ។

១.៣.២.៣. លក្ខខណ្ឌនៃអាជ្ញាប័ណ្ណ

លក្ខខណ្ឌរួមសម្រាប់ទទួលបានអាជ្ញាប័ណ្ណជាក្រុមហ៊ុនមូលបត្រដែលត្រូវបានកំណត់ក្នុងមាត្រា ៤០ នៃអនុក្រឹតរួមមាន៖

- ត្រូវជាក្រុមហ៊ុនមូលធន ឬក្រុមហ៊ុនសហកម្មសិទ្ធិស្របតាមច្បាប់ស្តីពីសហគ្រាសសាធារណៈ ឬបុគ្គលផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី គ.ម.ក។
- ត្រូវតែជាសមាជិក និងអ្នកចូលរួមក្នុងទីផ្សារ ឬត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ ដើម្បីក្លាយជាសមាជិករបស់ទីផ្សារ លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ គ.ម.ក។
  - លក្ខខណ្ឌពាក់ព័ន្ធនឹងគុណវុឌ្ឍិ លក្ខណៈសម្បត្តិ និងអត្តចរិកល្អរបស់អភិបាលក្រុមហ៊ុន ឬសហកម្មសិទ្ធិ។
  - ត្រូវមានអភិបាលម្នាក់ ឬសហកម្មករម្នាក់ និងនិយោជិតម្នាក់ដែលមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីទទួលបាន អាជ្ញាប័ណ្ណជាភ្នាក់ងារក្រុមហ៊ុនមូលបត្រ។
  - ត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្ម ឧបករណ៍តម្កល់ធានាផ្សេងទៀតដែលកំណត់ដោយ គ.ម.ក។
  - ត្រូវមានមូលធនសុទ្ធអប្បរមា និងរចនាសម្ព័ន្ធមូលធនដែលកំណត់ដោយ គ.ម.ក ទៅតាមប្រភេទអាជីវកម្មនីមួយៗរបស់ក្រុមហ៊ុនមូលបត្រ។
  - ត្រូវមានអគារ ប្រព័ន្ធឧបករណ៍ និងសម្ភារៈគ្រប់គ្រាន់ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវរបស់ប្រតិបត្តិករ។

លក្ខខណ្ឌលម្អិត និងបន្ថែមត្រូវបានកំណត់ដោយប្រកាសរបស់ គ.ម.ក។ លក្ខខណ្ឌលម្អិត និងបន្ថែមពីនេះពាក់ព័ន្ធនឹងធនធានមនុស្សរបស់ក្រុមហ៊ុន ចំនួនមូលធនអប្បរមា មូលធនសុទ្ធអប្បរមា និងប្រាក់តម្កល់អាជីវកម្មទៅតាមប្រភេទអាជីវកម្មមូលបត្រនីមួយៗ ផែនការអាជីវកម្មរយៈពេល ៣ឆ្នាំ លក្ខខណ្ឌនៃការគ្រប់គ្រងហានិភ័យ និងការត្រួតពិនិត្យផ្ទៃក្នុង និងផែនការគ្រប់គ្រងហានិភ័យបច្ចុប្បន្នកម្មជាដើម។

១.៣.២.៤. តួនាទីរបស់ក្រុមហ៊ុនមូលបត្រ

ដើម្បីធានាក្រុមហ៊ុនមូលបត្រ អាចធ្វើអាជីវកម្មមូលបត្រដោយមានប្រសិទ្ធិភាព ច្បាប់តម្រូវឱ្យក្រុមហ៊ុនមូលបត្រត្រូវមានភ្នាក់ងារដែលមានគុណវុឌ្ឍិនិដែលទទួលស្គាល់ដោយ គ.ម.ក។ ភ្នាក់ងារក្រុមហ៊ុនមូលបត្រនេះអាចជាអគ្គនាយក នាយក បុគ្គលិក ឬនិយោជិតរបស់ក្រុមហ៊ុន។ ភ្នាក់ងារក្រុមហ៊ុមូលបត្រ ជាអ្នកធ្វើសកម្មភាព ១- បើក និងគ្រប់គ្រងគណនីឱ្យអតិថិជនរបស់ក្រុមហ៊ុនមូលបត្រ ២- ទទួល និងអនុវត្តន៍បញ្ជាទិញ ឬលក់មូលបត្រ ក្នុងនាមអតិថិជនរបស់ក្រុមហ៊ុនមូលបត្រ និង ៣-បំពេញការងារផ្សេងទៀតតាមការឯកភាពរបស់ក្រុមហ៊ុន។ ក្នុងន័យនេះ ក្រុមហ៊ុនមូលបត្រត្រូវទទួលខុសត្រូវផ្តែករដ្ឋប្បវេណីដែលកើតចេញពីសកម្មភាពរបស់ភ្នាក់ងារ ក្រុមហ៊ុនមូលបត្រដែលស្ថិតនៅក្រោមលក្ខខណ្ឌនៃអាជ្ញាប័ណ្ណរបស់ខ្លួន ឬសកម្មភាពផ្សេងទៀតដែលទទួលបាន ការអនុញ្ញាតពីក្រុមហ៊ុនមូលបត្រ[18]។

១.៣.៣.ប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិករជាប់ទាត់និងទូទាត់ និងប្រតិបត្តិកររក្សាទុកមូលបត្រ

១.៣.៣.១. ប្រតិបត្តិករទីផ្សារមូលបត្រ

ទីផ្សារមូលបត្រត្រូវបានដាក់ឱ្យដំណើរការ និងគ្រប់គ្រងដោយប្រតិបត្តិករទីផ្សារមូលបត្រដែលទទួលបានការអនុញ្ញាតពីអគ្គនាយកនៃគ.ម.ក។ សេវាកម្មដែលផ្តល់ប្រតិបត្តិករទីផ្សារមូលបត្រជា សេវាកម្មទីផ្សារមូលបត្រ។ ប្រតិបត្តិកររនេះជាអ្នកបង្កើតទីផ្សារ មានន័យថាជាអ្នកផ្តល់ជាទីកន្លែង ឬប្រព័ន្ធ ឬមធ្យោបាយ ដើម្បីឱ្យអ្នកចូលរួមក្នុងទីផ្សារធ្វើសកម្មភាពជួញដូរមូលបត្រ។ ប្រតិបត្តិករទីផ្សារមូលបត្រជា ម្ចាស់ទីផ្សារមូលបត្រ។

១.៣.៣.២. ប្រតិបត្តិករជាប់ទាត់ និងទូទាត់

ប្រតិបត្តិករប្រព័ន្ធប្រព័ន្ធជាត់ទាត់ និងទូទាត់ ជាអ្នកផ្តល់សេវាកម្មប្រព័ន្ធជាត់ទាត់ និងទូទាត់។ ច្បាប់បានកំណត់និយមន័យនៃប្រព័ន្ធជាត់ទាត់ និងទូទាត់ថាសំដៅដល់ប្រព័ន្ធដែលផ្តល់លទ្ធភាពដល់ភាគីធ្វើប្រតិបត្តិការជួញដូរបំពេញកាតព្វកិច្ចរបស់ខ្លួនទៅវិញទៅមក ដោយធ្វើការផ្ទៀងផ្ទាត់ប្រតិបត្តិការឱ្យបានច្បាស់លាស់ និងធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ដែលជាថ្នូរនឹងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។ យោងតាមនិយមន័យនេះ គោលបំណងក្នុងការបង្កើតឱ្យមានប្រព័ន្ធជាត់ទាត់ និងទូទាត់ គឺដើម្បីធានានូវភាពត្រឹមត្រូវ

[18] ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៥, ទំព័រទី ៩៦-៩៧-៩៨-៩៩-១០០ និង ១០១)

និងប្រសិទ្ធភាពនៃប្រតិបត្តិការទូទាត់ ដោយព្យាយាមលុបបំបាត់ ឬកាត់បន្ថយជាអតិបរមាហានិភ័យនៃការទូទាត់ សំដៅធានាឱ្យមានការទូទាត់ថ្លៃទិញជូនអ្នកលក់ដែលជាថ្នូរ និងការផ្ទេរកម្មសិទ្ធិមូលបត្រទៅឱ្យអ្នកទិញ។

១.៣.៣.៣. ប្រតិបត្តិការរក្សាទុកមូលបត្រ

ប្រតិបត្តិការរក្សាទុកមូលបត្រ សំដៅដល់បុគ្គលមួយដែលយល់ព្រមជាមួយបុគ្គលមួយផ្សេងទៀតដែលជាអតិថិជនរបស់ខ្លួនក្នុងការផ្តល់សេវាកម្មរក្សាទុកមូលបត្រ ទោះបីជាអតិថិជននោះធ្វើសកម្មភាពក្នុងនាមខ្លួនឯង ឬធ្វើសកម្មភាពក្នុងន័យបុគ្គលផ្សេងទៀតក៏ដោយ។ សេវាកម្មរក្សាទុកមូលបត្ររួមមាន៖

- ការកាន់កាប់ ឬចុះបញ្ជីសិទ្ធិស្របច្បាប់លើមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀតក្នុងនាមអតិថិជន ឬបុគ្គលផ្សេងទៀតដែលជាអតិថិជនតែងតាំង
- ការទទួលរក្សាទុកនូវមូលបត្រ ឬឧបករណ៍ហិរញ្ញវត្ថុដ៏ទៃទៀត ទោះបីជាក្នុងរូបភាពវិញ្ញាបនបត្រកម្មសិទ្ធិ ឬជាទម្រង់អរូបីក្តី ដោយស្របទៅតាមវិធានប្រតិបត្តិការរក្សាទុកមូលបត្រក្នុងមានអតិថិជន ឬបុគ្គលផ្សេងទៀតដែលអតិថិជនតែងតាំង។
- ការផ្តល់សេវាកម្ម និងលក្ខណៈងាយស្រួលផ្សេងៗទៀតដែលទាក់ទិននឹងការផ្តល់សេវាកម្មទាំងពីរខាងលើ។

១.៣.៣.៤. វិធានប្រតិបត្តិការ

វិធានប្រតិបត្តិការនេះជា វិធានផ្ទាល់របស់ប្រតិបត្តិករនីមួយៗ ហើយមានអានុភាពចាប់បង្ខំចំពោះបុគ្គលទាំងអស់ដែលប្រើប្រាស់ប្រព័ន្ធនីមួយៗនេះ។ ក្នុងន័យនេះ ប្រតិបត្តិករនីមួយៗជាស្វ័យនិយ័តការវិជ្ជាជីវៈ ពីព្រោះវិធានប្រតិបត្តិការនេះត្រូវបង្កើតឡើងដោយប្រតិបត្តិករដោយខ្លួនឯង ប៉ុន្តែមានអានុភាពជាវិធានដែលអនុវត្តចំពោះបុគ្គលពាក់ព័ន្ធទាំងអស់។

១.៣.៣.៥. ការផ្តល់អនុញ្ញាត

គ.ម.ក បានផ្តល់អនុម័តប្រកាសស្តីពី ការផ្តល់ការអនុញ្ញាតធ្វើជាប្រតិបត្តិករទីផ្សារមូលបត្រ ប្រតិបត្តិការប្រព័ន្ធជាត់ទាត់ និងទូទាត់មូលបត្រ និងប្រតិបត្តិការរក្សាទុកមូលបត្រ ដែលកំណត់ពីលក្ខខណ្ឌលម្អិតផ្តល់ការអនុញ្ញាតនេះ[19]។

១.៣.៤. អ្នកចូលរួមក្នុងទីផ្សារផ្សេងទៀត

១.៣.៤.១. អ្នកវិនិយោគសាធារណៈ

វិនិយោគិនសាធារណៈ គឺជាអ្នកទិញ និងអ្នកលក់មូលបត្រដែលស្វែងរកប្រាក់ចំណេញទៅលើការវិនិយោគរបស់ខ្លួន។ វិនិយោគិន គឺជាអ្នកបែងចែកទុកទុនរបស់ខ្លួន ដោយរំពឹងថានឹងទទួលបានចំណូលហិរញ្ញវត្ថុ

[19] ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៥, ទំព័រទី ១០១-១០២ និង ១០៣)

នាថ្ងៃអនាគត។ នៅក្នុងវិស័យមូលបត្រ វិនិយោគិនសំដៅដល់បុគ្គល ឬសាធារណៈជនដែលបានទិញ កាន់កាប់ និងផ្ទេរដូរមូលបត្រដើម្បីទទួលបានប្រាក់ចំណេញជាភាគលាភ និងការចំណេញមូលធន ឬការប្រាក់។

វិនិយោគិនលើទីផ្សារមូលបត្រ ចែកចេញជា ២ ប្រភេទ៖

- វិនិយោគិនជាបុគ្គល (Individual Investor)
- វិនិយោគិនជាស្ថាប័ន (Institutional Investor)។

១.៣.៤.២. កត្តាជំរុញឱ្យមានការវិនិយោគលើមូលបត្រ

ទីផ្សារមូលបត្រ ជាទីផ្សារមួយដែលមានហានិភ័យខ្ពស់ចំពោះវិនិយោគិនសាធារណៈ។ ជាទូទៅមានមូលហេតុ ២យ៉ាង ដែលជំរុញឱ្យអ្នកវិនិយោគិនសាធារណៈយល់ព្រមចុះឈ្មោះទិញមូលបត្រដែលដាក់លក់ជាសាធារណៈ៖

- **ការចូលរួមចំណែកក្នុងការបែងចែកភាគលាភ៖** គឺឆន្ទៈក្នុងការទទួលបានផលប្រយោជន៍ពីការរីកចម្រើនរបស់ក្រុមហ៊ុន។ ក្នុងករណីដែលក្រុមហ៊ុនបោះផ្សាយមូលបត្រទទួលបានជោគជ័យ វិនិយោគិនសាធារណៈនឹងទទួលបាននូវចំណែកតាមសមាមាត្រនៃសិទ្ធិដែលខ្លួនមាននៅក្នុងក្រុមហ៊ុន ឬទទួលបាននូវអត្រាការប្រាក់ដែលខ្ពស់ជាងអត្រាការប្រាក់បញ្ញើដែលផ្តល់ដោយធនាគារ។
- **តម្រៃនៃការផ្ទេរដូរមូលបត្រនៅលើទីផ្សារ៖** គឺការស្វែងរកការចំណេញពីការផ្ទេរដូរមូលបត្រនៅលើទីផ្សារដោយលក់ទៅវិញក្នុងតម្លៃខ្ពស់ជាងតម្លៃទិញ។ វិនិយោគិនសាធារណៈសង្ឃឹមថានៅពេលសំណើមានការកើនឡើងតម្លៃរបស់មូលបត្រនឹងកើនឡើង។

១.៣.៤.៣. ភ្នាក់ងារបញ្ជីការមូលបត្រ

ភ្នាក់ងារបញ្ជីការមូលបត្រ គឺជាបុគ្គលដែលផ្តល់សេវានានាពាក់ព័ន្ធនឹងការកត់ត្រាមូលបត្រដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈដោយក្រុមហ៊ុនបោះផ្សាយ។ សេវាកម្មរបស់ភ្នាក់ងារបញ្ជីការមូលបត្រត្រូវធ្វើឡើងនៅក្នុងក្របខណ្ឌនៃការធ្វើសំណើនៃការបោះផ្សាយលក់មូលបត្រជាសាធារណៈ។ សេវាកម្មដែលផ្តល់ដោយភ្នាក់ងារនេះរួមមាន៖

- គ្រប់គ្រងឱ្យបានត្រឹមត្រូវនូវដំណើរការនៃការធ្វើបរិវិសកម្ម និងការបែងចែកមូលបត្រស្របតាមនីតិវិធីនៃការបោះផ្សាយលក់មូលបត្រ។
- កត់ត្រាបញ្ជីកម្មសិទ្ធិករមូលបត្រក្រោយពេលធ្វើការបែងចែកមូលបត្រត្រូវបានបញ្ចប់នៅទីផ្សារដំបូង។
- ធ្វើរបាយការណ៍ស្តីពីការបញ្ចប់ និងជោគជ័យនៃការរក្សាទុកមូលបត្រនៅប្រតិបត្តិការរក្សាទុកមូលបត្រ

ជូនក្រុមហ៊ុនមូលបត្រ និង គ.ម.ក។

- ជូនដំណឹងដល់កម្មសិទ្ធិករមូលបត្រដោយបញ្ជាក់ពីភាពជាម្ចាស់លើមូលបត្រ ដែលបានធ្វើបរិវិសកម្មមូលបត្ររបស់ក្រុមហ៊ុនបោះផ្សាយ។

១.៣.៤.៤. ភ្នាក់ងារចុះបញ្ជីផ្ទេរធ្វើមូលបត្រ

ភ្នាក់ងារនេះផ្តល់សេវាក្នុងនាមក្រុមហ៊ុនបោះផ្សាយ ក្រោយពេលមូលបត្រត្រូវបានបែងចែកទៅឱ្យអ្នកធ្វើបរិវិសកម្មរួចហើយ។ សេវាកម្មរបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រមានដូចខាងក្រោម៖

- រក្សា និងគ្រប់គ្រងបញ្ជីកម្មសិទ្ធិករមូលបត្រ រួមទាំងព័ត៌មានលម្អិតរបស់កម្មសិទ្ធិករមូលបត្រឱ្យមានសង្គតិភាពជាមួយនឹងកំណត់ត្រារបស់ប្រតិបត្តិកររក្សាទុកមូលបត្រ
- រដ្ឋបាលកិច្ចពាក់ព័ន្ធនឹងការផ្លាស់ប្តូរកម្មសិទ្ធិការធ្វើរបាយការណ៍ស្ថិតិព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ
- រៀបចំការងារពាក់ព័ន្ធនឹងកម្មសិទ្ធិករមូលបត្រដែលត្រូវផ្តល់ដោយក្រុមហ៊ុនបោះផ្សាយដូចជា ការជូនដំណឹងអំពីការបែងចែកភាគលាភ ការបង់ការប្រាក់ជាដើម
- បញ្ជូនរបាយការណ៍ និងព័ត៌មានផ្សេងទៀតរបស់ក្រុមហ៊ុនបោះផ្សាយដល់កម្មសិទ្ធិករមូលបត្រ និងដោះស្រាយបញ្ហាទាក់ទងនឹងភាពជាម្ចាស់លើមូលបត្រពាក់ព័ន្ធនឹងសេវារបស់ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ
- សេវាពាក់ព័ន្ធដ៏ទៃទៀតដែលទទួលបានការអនុញ្ញាតពី គ.ម.ក។

១.៣.៤.៥. ភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស

ភ្នាក់ងារនេះផ្តល់សេវាកម្មក្នុងនាមក្រុមហ៊ុនបោះផ្សាយ ដែលរួមមាន៖

- គណនាភាគលាភ ការប្រាក់ ប្រាក់ដើម ឬការទូទាត់ផ្សេងទៀតដែលត្រូវផ្តល់ឱ្យដល់កម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធតាមការណែនាំរបស់ក្រុមហ៊ុនបោះផ្សាយ
- ធ្វើការទូទាត់ជូនកម្មសិទ្ធិករមូលបត្រ ឬភាគីពាក់ព័ន្ធក្នុងនាមក្រុមហ៊ុនបោះផ្សាយ
- បញ្ជូនព័ត៌មានចាំបាច់ដែលពាក់ព័ន្ធនឹងការទូទាត់ ឬព័ត៌មានផ្សេងទៀតដល់កម្មសិទ្ធិករមូលបត្រ និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងការទូទាត់ទាំងនេះជូនទៅក្រុមហ៊ុនបោះផ្សាយ និង គ.ម.ក តាមការចាំបាច់។

១.៣.៤.៦. បុគ្គលដែលអាចក្លាយជាភ្នាក់ងារបញ្ជីការមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ឬភ្នាក់ងារទូទាត់ជំនួស

បុគ្គលដែលដាក់ពាក្យស្នើសុំធ្វើជាភ្នាក់ងារបញ្ជីការមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ ភ្នាក់ងារទូទាត់ជំនួសអាចជាប្រតិបត្តិកររក្សាទុកមូលបត្រ, ធនាគារពាណិជ្ជដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងក្រុមហ៊ុនមូលធនផ្សេងទៀតស្របតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម។ ប្រសិនបើ

បុគ្គលដាក់ពាក្យស្នើសុំជាភ្នាក់ងារចុះបញ្ជីការផ្ទេរមូលបត្រ មិនមែនជាប្រតិបត្តិកររក្សាទុកមូលបត្របុគ្គលដាក់ពាក្យស្នើសុំត្រូវមានកិច្ចសន្យាជាមួយប្រតិបត្តិកររក្សាទុកមូលបត្រស្តីពីការផ្តល់ព័ត៌មាននៃការផ្លាស់ប្តូរកំណត់ត្រាភាពជាម្ចាស់កម្មសិទ្ធិលើមូលបត្រដែលគ្រប់គ្រងដោយប្រតិបត្តិកររក្សាទុកមូលបត្រ។

១.៣.៤.៧. ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ

ការទូទាត់សាច់ប្រាក់នៃប្រតិបត្តិការជួញដូរមូលបត្រនៅលើទីផ្សារ ផ.ម.ក ត្រូវធ្វើឡើងតាមរយៈភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ។ ស្របតាមប្រកាសស្តីពីការទទួលស្គាល់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រ ភ្នាក់ងារនេះត្រូវតែជាធនាគារពាណិជ្ជដែលបានទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។ ក្រៅពីវិធានដែលកំណត់ដោយ គ.ម.ក ប្រតិបត្តិកររបស់ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រក៏ត្រូវស្ថិតនៅក្រោមវិធានរបស់ធនាគារជាតិនៃកម្ពុជាផងដែរ។

ក្រៅពីតួអង្គទាំងអស់ខាងលើ នៅមានតួអង្គមួយចំនួនផ្សេងទៀត ដូចជាក្រុមហ៊ុនផ្តល់សេវាវាយតម្លៃនៅក្នុងវិស័យមូលបត្រ និងក្រុមហ៊ុនគណនេយ្យជំនាញផ្តល់សេវានៅក្នុងវិស័យមូលបត្រជាដើម[20]។

១.៤.យន្តការចូលទីផ្សារមូលបត្រជាសាធារណៈ

ជាទូទៅក្រុមហ៊ុនត្រូវអនុវត្តយន្តការទាំង ១២ មុននឹងឈានជើងចូលក្នុងទីផ្សារមូលបត្រកម្ពុជា និងអាចបោះផ្សាយលក់មូលបត្រជាលើកដំបូង (IPO) ជាសាធារណៈបាន។ យន្តការទាំង ១២ នេះរួមមាន៖

យន្តការទី១៖ ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក គ.ម.ក។ ក្នុងលិខិតសម្តែងឆន្ទៈនេះត្រូវមានខ្លឹមសារ ៣ ចំណុច ដូចខាងក្រោម៖

១. គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

២. គម្រោងពេលវេលាទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

៣. ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលរំពឹងទុក ដែលរួមមានក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យ ជំនាញមេធាវី ឬក្រុមមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

[20] ញាន វណ្ណៈ, នីតិទីផ្សារមូលបត្រកម្ពុជា (បោះពុម្ពនៅប្រទេសកម្ពុជា, ឆ្នាំ ២០១៥, ទំព័រទី ១០៤-១០៥-១០៦ និង ១០៧)

យន្តការទី២៖ ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់មួយ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាកម្មដល់ក្រុមហ៊ុនបោះផ្សាយនូវគ្រប់ដំណាក់កាលនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលបានអាជ្ញាប័ណ្ណពី គ.ម.ក។

យន្តការទី៣៖ ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

ក្រៅពីក្រុមហ៊ុនធានាទិញ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការតែងតាំងបុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃដែលទទួលបានការទទួលស្គាល់ពី គ.ម.ក ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈស្របតាមបទបញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រអាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយមូលបត្រលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវបង្កើតក្រុមការងារ បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

យន្តការទី៤៖ ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់

ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងដែលរួមមាន ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។

យន្តការទី៥៖ ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីបានពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំឯកសារស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

យន្តការទី៦៖ ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងទទួលបានការអនុញ្ញាតជាគោលការណ៍សំណើសុំបោះផ្សាយលក់មូលបត្រកម្ពុជាសាធារណៈ ពី គ.ម.ក

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ ពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជាក្រុមហ៊ុនបោះផ្សាយលក់មូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយមូលបត្រដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូល

បត្រត្រូវរៀបបំឯកសារដាក់ស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក គ.ម.ក តាមទម្រង់ដែលកំណត់ដោយ គ.ម.ក។ ក្រុមហ៊ុនបោះផ្សាយត្រូវដាក់ឯកសារផ្តល់ព័ត៌មាន និងឯកសារភ្ជាប់នានា។ ក្រោយពេលទទួលបានសំណើនេះ គ.ម.ក ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជាពិសេស ឯកសារផ្តល់ព័ត៌មានមុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍ស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនក្រុមហ៊ុនបោះផ្សាយ។ អគ្គនាយកនៃ គ.ម.ក ត្រូវពិនិត្យ និងសម្រេចលើពាក្យស្នើសុំក្នុងរយៈពេលយ៉ាងយូរ ៣ ខែគិតចាប់ពីថ្ងៃដាក់ពាក្យស្នើ។

យន្តការទី៧៖ ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើ សំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈពី គ.ម.ក ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រ។ ការកំណត់ថ្លៃនេះត្រូវធ្វើឡើងតាមរយៈវិធីសាស្ត្រប៊ុកបៀលឌីង។ ការធ្វើប៊ុកបៀលឌីងនេះ ពោលគឺជាការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយនឹងអ្នកវិនិយោគសក្តានុពល មុននឹងឈានទៅដល់ការកំណត់ថ្លៃលក់មូលបត្រ។

យន្តការទី៨៖ ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រដែលបានកំណត់អាចដាក់លក់នៅលើទីផ្សារមូលបត្របានដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលទាំងវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

យន្តការទី៩៖ ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក

ក្រោយពីបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័ត៌មាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន គ.ម.ក ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

យន្តការទី១០៖ ការធ្វើបរិវិសកម្មមូលបត្រ

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក

ក្រុមហ៊ុនបោះផ្សាយមូលបត្រ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រពោលគឺ ការអនុញ្ញាតឱ្យអ្នកវិនិយោគសាធារណៈចុះឈ្មោះសុំទិញមូលបត្រដែលក្រុមហ៊ុនធ្វើសំណើលក់ជាសាធារណៈ។ ការធ្វើបរិវិសកម្មមូលបត្រនេះ ត្រូវធ្វើឡើងនៅក្នុងកំឡុងពេលដែលឯកសារផ្តល់ព័ត៌មាននៅមានសុពលភាពពោលគឺ ក្នុងរយៈពេលមិនលើសពីប្រាំមួយខែដែលគិតចាប់ពីថ្ងៃដែលឯកសារផ្តល់ព័ត៌មានចុះបញ្ជីនៅ គ.ម.ក។

យន្តការទី១១៖ ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ

ក្រោយពីបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រតាមទម្រង់ដែលកំណត់ដោយ គ.ម.ក ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះភ្លាមជូន គ.ម.ក ដោយភ្ជាប់មកជាមួយនូវលិខិតជាលាយលក្ខខ័ណ្ឌអក្សររបស់ធនាគារពាណិជ្ជអំពីចំនួនទឹកប្រាក់នៅក្នុងគណនីដោយឡែក បង្កើតឡើងសម្រាប់គោលបំណងនៃការបោះផ្សាយមូលបត្រ។

យន្តការទី១២៖ ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងបញ្ជូនមូលបត្រកម្មសិទ្ធិទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទទៅក្រុមហ៊ុនផ្សារមូលបត្រ ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន[21]។

[21] គោលការណ៍ណែនាំស្តីពី យន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងលេខ ០០១ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០១១

ជំពូក២

ស្ថានភាពទូទៅរបស់ធនាគារ អេស៊ីលីជា គីអិលស៊ី

ជំពូក២

ស្ថានភាពទូទៅរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី

២.១.ប្រវត្តិសង្ខេបធនាគារអេស៊ីលីដា

នៅក្នុងខែមករា ឆ្នាំ១៩៩៣ ធនាគារអេស៊ីលីដា ភីអិលស៊ី ត្រូវបានមានវត្តមានឡើងក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយមានទិសដៅអភិវឌ្ឍន៍មុខរបរខ្នាតតូចបំផុត និងធំបំផុតតាមរយៈការផ្តល់ឥណទានដោយមានការជួយគាំទ្រពីអង្គភាពពលកម្មអន្តរជាតិ (ILO) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ធនាគារអេស៊ីលីដា ភីអិលស៊ី ត្រូវបានទទួលការគាំទ្រពីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសំខាន់ៗជាច្រើនដូចជា មូលនិធិ WID នៃប្រទេសជប៉ុន រដ្ឋាភិបាលនៃប្រទេសណូវែលសេឡង់។ ធនាគារអេស៊ីលីដា ភីអិលស៊ី ត្រូវបានក្លាយខ្លួនជាធនាគារពាណិជ្ជ គឺដោយសារតែការផ្តួចផ្តើមរបស់ក្រុមប្រឹក្សាភិបាល និងអង្គការដៃគូរអន្តរជាតិរបស់ធនាគារអេស៊ីដា ដោយពឹងផ្អែកទៅលើកត្តាធំៗ ២គឺការ ពង្រីកបណ្តាញប្រតិត្តិការគ្រប់រាជធានីខេត្តក្នុងព្រះរាជាណាចក្រកម្ពុជា និងកត្តាស្វែងរកប្រាក់ចំណេញដែលធានានូវនិរន្តភាព។

នៅថ្ងៃ ០៧ ខែតុលា ឆ្នាំ២០០០ ធនាគារអេស៊ីលីដា ត្រូវបានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេសពីធនាគារជាតិនៃកម្ពុជា។ បន្ទាប់មកទៀតនាថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៣ បានទទួលអាជ្ញាប័ណ្ណជាធនាគារពាណិជ្ជពីធនាគារជាតិដែលធ្វើឱ្យធនាគារអេស៊ីលីដា មានលទ្ធិភាពទៅបំពេញទៅតាមត្រូវការរបស់អតិថិជននូវសេវាកម្មរបស់ធនាគារបានទូទៅ និងបានប្តូរឈ្មោះជាផ្លូវការ "ធនាគារអេស៊ីលីដា ភីអិលស៊ី" ។ បើក្រឡេកមកមើលពីភាគហ៊ុនវិញ ធនាគារអេស៊ីលីដា មានការរួមចំណែកភាគហ៊ុនចំនួន ៥៤,៤៥% ដោយសារភាគហ៊ុនិករបស់ប្រទេសកម្ពុជារួមទាំងបុគ្គលិកធនាគារនិងភាគហ៊ុនិកសាធារណៈដែរ ហើយចំណែកដែលនៅសល់ ៤៨,៥១% ទៀតកាន់កប់ដោយ៖ Sumitomo Mitui Banking Corporation (១៨,០៦៦%) COFIBRED (១២,១២៧១%), ORIX Corporation (១២,១២៧%) និងមូលនិធិវិនិយោគបីគ្រប់គ្រងដោយ Triodos Investment Management គឺ Triodos Sustainable Finance Foundation, Triodos Fair Share Fund, និង Triodos Microfinance Fund (៦,១៨៧៣%) ។ ចំណែកឯសាបណ្តាញប្រតិបត្តិការវិញមានបណ្តាញទូទាំងព្រះរាជាណាក្រកម្ពុជា (សាខាចំនួន ២៦៣ សាខា) និងបានពង្រីកតំបន់ប្រតិបត្តិការទៅកាន់ប្រទេសឡាវ (មាន ៣៨ សាខា) និងមីយ៉ាន់ម៉ា (មាន ១៧ សាខា) ។[22] ធនាគារអេស៊ីលីដា ភីអិលស៊ី បានចុះបញ្ជីមូលបត្រកម្មសិទ្ធិរបស់ខ្លួនជាផ្លូវការនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា នាថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ វិនិយោគិន

[22] https://www.acledabank.com.kh/kh/khm/ff_overview (ចូលទស្សនា ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

អាចធ្វើការដូរភាគហ៊ុនរបស់ធានាគារនៅលើ ទីផ្សារមូលបត្រកម្ពុជាចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពីម៉ោង ៨ព្រឹក ដល់ម៉ោង ៣រសៀល លើកលែងតែថ្ងៃឈប់សម្រាកជាសាធារណៈ។

២.១.១. ការិយាល័យកណ្តាលអេស៊ីលីដា

ដូចដែលបានដឹងហើយមកថាធនាគារអេស៊ីលីដា ចាប់តាំងពីឆ្នាំបង្កើតរហូតមកដល់បច្ចុប្បន្ន គឺមានការអភិវឌ្ឍ និងភាពរីកចម្រើនជាបន្តបន្ទាប់ដោយសារតែការគាំទ្រ និងដំណើរការរបស់ធនាគារនេះហើយទើបធ្វើឱ្យធនាគារអភិវឌ្ឍន៍ ខ្លួនជាបន្តបន្ទាប់ ដែលមានបណ្តាញសាខាជាច្រើនរួមជាមួយនឹងការិយាល័យកណ្តាលដែលយើងអាចហៅថា ទីស្នាក់ការកណ្តាល។ ចំពោះទីតាំងទីស្នាក់ការកណ្តាលវិញ គឺមានការអភិវឌ្ឍជាបន្តបន្ទាប់បន្ថែមទៀត។ ខាងស្តាំនេះជារូបទីស្នាក់ការកណ្តាលនាពេលបច្ចុប្បន្នរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី។

រូបភាពទី១៖ ទីស្នាក់ការកណ្តាលរបស់ធនាគារ អេស៊ី លីដា ភីអិលស៊ី

ទីស្នាក់ការកណ្តាលរបស់ធនាគាអេស៊ីលីដា តាំងពីចាប់ផ្តើមគឺមានការផ្លាស់ប្តូរទីតាំងជាបន្តបន្ទាប់ដូចជា៖

- **ការិយាល័យកណ្តាល សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា អេស៊ីលីដា** (១៩៩២ - ១៩៩៣)
  ទីតាំង៖ ខណ្ឌឫស្សីកែវ ភ្នំពេញ
- **ការិយាល័យកណ្តាល សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា អេស៊ីលីដា** (១៩៩៣ - ១៩៩៤)
  ទីតាំង៖ ផ្ទះលេខ១៨៦ ផ្លូវលេខ១២២ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ភ្នំពេញ
- **ការិយាល័យកណ្តាល សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ស្តាប់នមីក្រូហិរញ្ញវត្ថុអេស៊ីលីដា** (១៩៩៤ - ៣០ សីហា ១៩៩៩)
  ទីតាំង៖ ផ្ទះលេខ២៣២ ផ្លូវលេខ១៦៣ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន ភ្នំពេញ
- **ការិយាល័យកណ្តាលធនាគារអេស៊ីលីដាភីអិលស៊ី** (១៩៩៩ - ០៨ មេសា ២០០៧)
  ទីតាំង៖ អគារលេខ២៨ មហាវិថីម៉ៅសេទុង សង្កាត់បឹងត្របែក ខណ្ឌចំការមន ភ្នំពេញ
- **ការិយាល័យកណ្តាល ធនាគារអេស៊ីលីដា ភីអិលស៊ី** (០៩ មេសា ២០០៧ - ១០ ធ្នូ ២០១៥) មកបច្ចុប្បន្ន
  ទីតាំង៖អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

២.១.២. ស្ថាបនិក

ធនាគារអេស៊ីលីដា ត្រូវបានបង្កើតឡើងដោយស្ថាបនិកមួយក្រុមដែលមានសមាជិកចំនួន ២៨នាក់ អេស៊ីលីដា ត្រូវបានបង្កើតក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលមួយ ដែលបានជួបប្រជុំគ្នានៅទីភ្នាក់ងារអភិវឌ្ឍន៍

សេដ្ឋកិច្ចក្នុងស្រុក (LEDA ភ្នំពេញ) ដែលមានទីតាំងស្ថិតនៅក្នុង ខណ្ឌឫស្សីកែវ នៅថ្ងៃទី១៩ ខែ មករា ឆ្នាំ ១៩៩៣ និង បានប្រារព្ធពិធីមហាសន្និបាតដំបូងរបស់អេស៊ីលីដា រួចធ្វើការបោះឆ្នោតបង្កើតសមាគមទីភ្នាក់ងារ អភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា (អេស៊ីលីដា) ។ [23]

ខាងក្រោមនេះគឺជាឈ្មោះរបស់ស្ថាបនិក អេស៊ីលីដា ៖

១. លោក កែវ ចំរើន	១៥. លោក សយ សារឿន
២. លោក កែវ នព្វរតន៍	១៦. លោក សុខ ចាន់រិទ្ធី
៣. លោក ងីម ខេមរិទ្ធ	១៧. លោក ស៊ុន ប៊ុនថន
៤. លោក ឆាយ សឿន	១៨. លោក សួង សេងហួត
៥.លោក ជាម ទាង	១៩. លោក សៅ រឿន
៦. លោកស្រី ដាវ វ៉ាន់ឌី	២០. លោក ហុង សេដ្ឋា
៧. លោក នៅ សារឿន	២១. លោក ហ៊ឹង ឧសភា
៨. លោកស្រី ព្រឿន ម៉ាកព្រេង	២២. លោក ឡាយ ឆាំ
៩. លោក ម៉ក់ សុខា	២៣.លោក ឡែម សារុន
១០. លោកស្រី លី ធីតា	២៤. លោក អ៊ុន ចាន់នី
១១. លោក វ៉ាន់ សារឿន	២៥. លោក អ៊ុង ប៊ុនថន
១២. លោក វ៊ឹង ស៊ុនលី	២៦. លោកស្រី អៀង ផល្លា
១៣. លោក ស រ័ត្ន	២៧. លោក អ៊ុំ សារិន
១៤. លោកស្រី សន សុជាតិ	២៨. លោក ឯក ដន

២.១.៣. ដំណើរនៃការពង្រីកបណ្តាញសាខារបស់ធនាគារអេស៊ីលីដា

អេស៊ីលីដា បានពង្រីកបណ្តាញប្រតិបត្តិការឱ្យកាន់តែសុះសាយដើម្បីបម្រើសេវាអតិថិជនឱ្យកាន់តែមានភាពងាយស្រួល ។ ធនាគារអេស៊ីលីដា មានបណ្តាញប្រតិបត្តិការយ៉ាងធំទូលាយគ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា (មាន ២៦៣ សាខា) និងបានពង្រីកតំបន់ប្រតិបត្តិការទៅកាន់ប្រទេសឡាវ (មាន ៣៨ សាខា) និងមីយ៉ាន់ម៉ា (មាន ១៧ សាខា)។ បណ្តាសាខារបស់ធនាគារអេស៊ីលីដាទាំងអស់ គឺត្រូវបានបម្រើសេវាកម្មរបស់អតិថិជនយ៉ាងទូលំទូលាយ។[24]

[23] https://www.acledabank.com.kh/kh/khm/ff_history.founder (ចូលទស្សនា ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)

❖ **ព្រះរាជាណាចក្រកម្ពុជា**

ឆ្នាំបង្កើត	**ខេត្តនិងក្រុងដែលត្រូវបានពង្រីកបណ្តាញសាខា**
១៩៩៣	ភ្នំពេញ, កណ្តាល, បន្ទាយមានជ័យ, សៀមរាប, បាត់ដំបង, កំពង់ចាម
១៩៩៤	តាកែវ, កំពត, កែប
១៩៩៥	ក្រុងព្រះសីហនុ
១៩៩៦	ពោធិ៍សាត់
១៩៩៧	កំពង់ស្ពឺ, កំពង់ធំ
២០០០	កំពង់ឆ្នាំង, ស្វាយរៀង
២០០១	ព្រៃវែង
២០០៣	កោះកុង
២០០៤	ប៉ៃលិន, ឧត្តរមានជ័យ
២០០៥	ស្ទឹងត្រែង
២០០៦	រតនគិរី មណ្ឌលគិរី

តារាងទី២ ៖ បណ្តាញពង្រីកសាខារបស់ អេស៊ីលីដា នៅព្រះរាជាណាចក្រកម្ពុជា

❖ **សាធារណរដ្ឋប្រជាធិបតេយ្យមានិតឡាវ**

ឆ្នាំបង្កើត	**ខេត្តដែលត្រូវបានពង្រីកបណ្តាញសាខា**
២០០៨	រដ្ឋធានីវៀងច័ន្ទ, សាក់វណ្ណខេត, ចំប៉ាសាក់
២០០៩	សាឡាវ៉ាន់
២០១០	ខាំមួន
២០១១	វៀងច័ន្ទ
២០១២	បលីខាំសៃ, សេកង, លួងផាក់បាង, អាត់តាពើ
២០១៣	បកែវ, សៃញាក់ប៊ូលី, សៀងឃ្វាង, អ៊ុឌុមសៃ, លួងណាំថា

តារាងទី៣ ៖ បណ្តាញពង្រីកសាខារបស់ អេស៊ីលីដា នៅសាធារណរដ្ឋប្រជាធិបតេយ្យមានិតឡាវ

[24] https://www.acledabank.com.kh/kh (ចូលទស្សនា ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)

❖ **សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា**

ឆ្នាំបង្កើត	ខេត្តដែលត្រូវបានពង្រីកបណ្តាញសាខា
២០១៣	ភូមិភាគយ៉ាំងកូង ភូមិភាគបាកូ
២០១៩	Mon State
២០២០	Magway Region

តារាងទី៤ ៖ បណ្តាញពង្រីកសាខារបស់ អេស៊ីលីដា នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

២.២.និមិត្តសញ្ញា អត្ថន័យ និង ប្រព័ន្ធទំនាក់ទំនងរបស់ធនាគារអេស៊ីលីដា

២.២.១. និមិត្តសញ្ញា

ខាងក្រោមនេះ គឺជានិមិត្តសញ្ញារបស់ ធនាគារអេស៊ីលីដា [25]

រូបភាពទី២៖ និមិត្តសញ្ញារបស់ធនាគារអេស៊ីលីដាបច្ចុប្បន្ន

ធនាគារអេស៊ីលីដាមានការវិវឌ្ឍស្លាកសញ្ញារបស់ខ្លួនចំនួន៥ដងមកទល់នឹងបច្ចុប្បន្ន



រូបភាព៣៖ និមិត្តសញ្ញានៃការវិវត្តរបស់ធនាគារអេស៊ីលីដាមកទល់បច្ចុប្បន្ន

[25] https://www.acledabank.com.kh/kh/khm/md_logo (ចូលទស្សនា ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)

២.២.២. អត្ថន័យនៃរូបសញ្ញារបស់ធនាគារអេស៊ីលីដា

និមិត្តសញ្ញារបស់ធនាគារអេស៊ីលីដា ភីអិលស៊ី មានព័ណ៌ស, ព័ណ៌មាស និងព័ណ៌ខៀវទឹកបិក ដែលវាមានអត្ថន័យដូចខាងក្រោម៖

ព័ណ៌ស៖ អភិសមាចារ (តម្លាភាព ភាពស្មោះត្រង់ និងសុចរិតភាព)

ព័ណ៌មាស៖ គុណតម្លៃ និងគុណភាព

ព័ណ៌ខៀវទឹកបិក៖ សាមគ្គីភាព ស្ថិរភាព និងសុវត្ថិភាព

ចំពោះអត្ថន័យនៃព័ណ៌បីបញ្ចូលគ្នា ប្រៀបបានទៅនឹងគ្រាប់ពូជ និងធនធានដែលបានរីកដុះដាល និងអភិវឌ្ឍន៍ក្នុងវិស័ហិរញ្ញវត្ថុប្រកបដោយចីរភាព។[26]

២.៣.៣. ប្រព័ន្ធទំនាក់ទំនងរបស់ធនាគារអេស៊ីលីដា

ចំពោះបណ្តាញទំនាក់ទំនងមកកាន់ធនាគារអេស៊ី លីដា ភីអិលស៊ី មានដូចខាងក្រោម៖

អាសយដ្ឋាន ៖ អគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ប្រអប់សំបុត្រ ៖ ១១៤៩

ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧, ០២៣ ៤៣០ ៩៩៩/ទូរសារ៖ ០២៣ ៤៣០ ៥៥៥

អ៊ីម៉ែល ៖ acledabank@acledabank.com.kh /SWIFT Code: ACLBKHPP

២.៣. ទស្សន: និងបេសកកម្ម របស់ធនាគារអេស៊ីលីដា

២.៣.១. ទស្សន:

ធនាគារអេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្មហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

២.៣.២. បេសកកម្ម

បេសកកម្មរបស់ ធនាគារអេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជននូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគហ៊ុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌វិជ្ជាជីវៈ សង្គម ច្បាប់ និង បរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។[27]

[26] https://www.acledabank.com.kh/kh/khm/md_logo (ចូលទស្សនា ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)

[27] https://www.acledabank.com.kh/kh/khm/ff_vision_mission (ចូលទស្សនា ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)

២.៤. ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សារបស់ធនាគារអេស៊ីលីដា ភីអិលស៊ី គឺមានលោក ឆាយ សឿន ជាប្រធានក្រុមប្រឹក្សាភិបាល និងសមាជិក ៩នាក់ ទៀត ដែលមានដូចខាងក្រោម[28]៖

តារាងទី៥៖ រចនាសម្ព័ន្ធក្រុមប្រឹក្សារបស់ធនាគារអេស៊ីលីដា

[28] https://www.acledabank.com.kh/kh/khm/ff_bod (ចូលទស្សនា ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)

២.៥. គណកម្មាធិការប្រតិបត្តិ

គណកម្មាធិការប្រតិបត្តរបស់ធនាគារអេស៊ីលីដា មានដូចជា៖

១. បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ

២. បណ្ឌិត សូ ផនណារី អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ

៣. លោក ស្រីម៉ារ អមរា អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ

៤. លោក រ័ត្ន យូម៉ែង អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបា

៥. លោក លី ថៃ អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច

៦. លោកស្រី ប៊ុត ប៊ុនសីហា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន

៧. លោក ម៉ាច់ ធារី អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា

៨. បណ្ឌិត ឡឹង សុភាព អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ



តារាងទី៦៖ រចនាសម្ព័ន្ធគណកម្មាធិការប្រតិបត្តិរបស់ធនាគារអេស៊ីលីដា

២.៦. សាខនកម្មផ្ទៃក្នុង

ធនាគារអេស៊ីលីដាមានសាវនការផ្ទៃក្នុងគឺ លោកស្រី គឹម សុធារី មានឋានៈជាប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សាវនកម្មផ្ទៃក្នុងទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងសវនកម្មផ្ទៃក្នុងប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការសវនកម្មផ្ទៃក្នុង ដែលធ្វើការត្រួតពិនិត្យនាយកដ្ឋានចំនួន ២ និងការិយាល័យចំនួន ៤ មានដូចជា៖

- នាយកដ្ឋានអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
- នាយកដ្ឋានសវនកម្មសន្តិសុខពត៌មានវិទ្យា
- ការិយាល័យរបាយការណ៍សវនកម្ម
- ការិយាល័យសវនកម្មឥណទាន
- ការិយាល័យសវនកម្មហិរញ្ញវត្ថុ
- ការិយាល័យសវនកម្មប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

២.៧. ឥតហុនិក

ធនាគារអេស៊ីលីដាមានភាហុនិកដូចជា៖

- អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ (AFT) ជាភាគហ៊ុនិកមួយរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ដែលបានបង្កើតឡើង អនុលោមតាមច្បាប់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានគោលដៅលើកទឹកចិត្តដល់ធនាគារអេស៊ីលីដា ភីអិលស៊ី ឱ្យប្រកាន់ខ្ជាប់នូវគោលបំណង ដើម្បីគាំទ្រដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម និងរក្សានូវសញ្ជាតិជាក្រុមហ៊ុនខ្មែរ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលមិនស្ថិតក្នុងចំណុះឱ្យគណៈបក្សនយោបាយណាមួយ ឬស្ថាប័ននយោបាយណាមួយឡើយ។
- ភាគហ៊ុនិកដែលធ្វើនិយ័តកម្ម ពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ីជាភាគហ៊ុនិកដែលតម្រូវឱ្យធ្វើនិយ័តកម្មពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី។
- SUMITOMO MITSUI BANKING CORPORATION (SMBC) គឺជាធនាគារជប៉ុនធំមួយដែលប្រតិបត្តិការទូទាំងពិភពលោក ដែលប្តេជ្ញាធ្វើការឆ្ពោះទៅគោលដៅរបស់ខ្លួនគឺ "ពន្លឿនយុទ្ធសាស្ត្រផ្តោតលើអាស៊ី" ។
- COFIBRED - COMPAGNIE FINANCIÈRE DE LA BRED (BRED'S FINANCIAL COMPANY)៖ COFIBRED គឺជាបុត្រសម្ព័ន្ធពេញលេញរបស់ BRED BanquePopulaire ។

- ORIX CORPORATION ក្រុមហ៊ុន ORIX (TSE: 8591; NYSE: IX) ជាក្រុមហ៊ុនផ្តល់សេវាហិរញ្ញវត្ថុ និងវិនិយោគ និងធ្វើប្រតិបត្តិការអាជីវកម្មលើ៦វិស័យ រួមមាន៖ សេវាកម្មហិរញ្ញវត្ថុ សាជីវកម្ម ភតិសន្យាហិរញ្ញវត្ថុ អចលនទ្រព្យ វិនិយោគ និងប្រតិបត្តិការសេវាលក់រាយ និងអាជីវកម្មក្រៅប្រទេស។
- NORTH HAVEN THAI PRIVATE EQUITY RUMDUL COMPANY (HONG KONG) LIMITED ("NHTPE RUMDUL")
- TRIODOS FAIR SHARE FUND និង TRIODOS MICROFINANCE FUND គឺជាមូលនិធិវិនិយោគ គ្រប់គ្រងដោយ Triodos Investment Management ។ Triodos Investment Management គឺជាបុត្រសម្ព័ន្ធពេញលេញ និងកាន់កាប់ភាគហ៊ុនចំនួន ១00% ដោយធនាគារ Triodos ដែលជាធនាគារមួយមាននិរន្តរភាពឈានមុខគេនៅលើពិភពលោក ។ មូលនិធិនេះផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាជន និងសហគ្រាសខ្នាតតូច និងមធ្យមដែលមានចំណូលទាបនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដើម្បីរួមចំណែកក្នុងវិស័យហិរញ្ញវត្ថុរួមមួយ ប្រកបដោយនិរន្តរភាព ។

២.៨. សេវាកម្ម និងផលិតផល

ធនាគារអេស៊ីលីដា មានសេវាកម្ម និងផលិតផលជាច្រើនដែលបម្រើឱ្យអតិថិជនទៅតាមតម្រូវការ និងមានភាពងាយស្រួល ដោយមានប្រព័ន្ធបច្ចេកវិជ្ជាកម្រិតពិភពលោក បណ្តាប្រតិបត្តិការធំជាងគេនៅក្នុងប្រទេស និងមានធនាគារដៃគូពាសពេញពិភពលោក ដែលសេវាកម្ម និងផលិតផលទាំងនោះមានដូចជា៖

- **ឯកត្តជន**

ប្រភេទ	ប្រភេទផ្សេងៗ
សេវាឥណទាន	- ឥណទានអាជីវកម្មខ្នាតតូច - ឥណទានអាជីវកម្មខ្នាតមធ្យមនិងសាជីវកម្ម - ឥណទានវិបារូបរ៍ - ឥណទានសម្រាប់ទុនបង្វិល - ឥណទានសម្រាប់កិច្ចធានា - ឥណទានពាណិជ្ជកម្ម
សេវាបញ្ញើ និងសន្សំ	- គណនីបញ្ញើសំចៃ - គណនីបញ្ញើតាមតម្រូវការ - គណនីចរន្ត - ប្រាក់បញ្ញើមានកាលកំណត់

	- គណនី Euro Flex - គណនីមូលបត្រ - គណនីព្រះសង្ឃ និងគណនីមូលនិធិវត្ត
សេវាចាត់ចែងសាច់ប្រាក់	- សេវាលិខិតអះអាងលើគណនី និងព័ត៌មានអតិថិជន - សេវាមូលប្បទានប័ត្រសាច់ប្រាក់ - សេវាបើកប្រាក់បៀវត្ស - សេវាប្រមូលសាច់ប្រាក់ - សេវាទូទាត់ឱ្យអ្នកផ្គត់ផ្គង់ - សេវាសម្រួលគណនីអតិថិជន - សេវាបញ្ជាអចិន្ត្រៃយ៍ - សេវាទិញមូលប្បទានប័ត្រ - បរទេសនិងមូលប្បទានប័ត្រទេសចរណ៍ - សេវាមូលប្បទានប័ណ្ណ - សេវាប្រមូលប្រាក់បង់ពន្ធ - សេវាកិច្ចសន្យាប្តូររូបិយប័ណ្ណទុកមុន - សេវាផ្ទេរប្រាក់ទូទាត់ជាកញ្ចប់ - សេវាប្តូរប្រាក់
សេវាផ្ទេរប្រាក់	- សេវាលិខិតអះអាងលើគណនី និងព័ត៌មានអតិថិជន - សេវាមូលប្បទានប័ត្រសាច់ប្រាក់ - សេវាបើកប្រាក់បៀវត្ស - សេវាប្រមូលសាច់ប្រាក់ - សេវាទូទាត់ឱ្យអ្នកផ្គត់ផ្គង់ - សេវាសម្រួលគណនីអតិថិជន - សេវាបញ្ជាអចិន្ត្រៃយ៍ - សេវាទិញមូលប្បទានប័ត្របរទេស និងមូលប្បទានប័ត្រទេសចរណ៍

	- សេវាមូលប្បទានប័ណ្ណ - សេវាប្រមូលប្រាក់បង់ពន្ធ - សេវាកិច្ចសន្យាប្តូររូបិយប័ណ្ណទុកមុន - សេវាផ្ទេរប្រាក់ទូទាត់ជាកញ្ចប់ - សេវាប្តូរប្រាក់
សេវាហិរញ្ញប្បទានពាណិជ្ជកម្ម	- សេវា DOCUMENTARY COLLECTION - Export Documentary Collection - សេវាលិខិតឥណទាន - សេវាលិខិតធានា
សេវាពាក់ព័ន្ធមូលបត្រ និងបរធន	- សេវារក្សាសុវត្ថិភាព ក្នុងវិស័យមូលបត្រ - សេវាប្រតិបត្តិការ RTP - សេវារក្សាទុកបរធន - គណនីមូលនិធិសោធននិវត្តន៍ - គណនីមូលនិធិគាំពារសុខភាព - គណនីមូលនិធិសិក្សាអប់រំ - គណនីអាណាត្តិព្យាបាលសម្រាប់គ្រឹះស្ថាន - សេវាទូទាត់សងប្រាក់ - សេវាបញ្ជីតាមរយៈប្រអប់សុវត្ថិភាព
សេវាធានារ៉ាប់រងអាយុជីវិត ក្នុងនាមជាអ្នកណែនាំអតិថិជន	
សេវាពិនិត្យសុខភាពហិរញ្ញវត្ថុ	

តារាងទី៧ ៖ សេវាកម្ម និងផលិតផល (ឯកត្តជន)

❖ **ប័ណ្ណ**

ប្រភេទ	ប្រភេទប័ណ្ណផ្សេងៗ
ប័ណ្ណឥណទានប្រើប្រាស់ផ្ទាល់ខ្លួន ចំពោះប្រតិបត្តិការប័ណ្ណមានដូចជា ម៉ាស៊ីនអេធីអឹម ម៉ាស៊ីនឆូតកាត និងសេវាអេស៊ីលីដា អ៊ីខុមមើស	
ប័ណ្ណអេស៊ីលីដា ប័ណ្ណអេធីអឹម អេស៊ីលីដា គឺជាប័ណ្ណចេញដោយ ធនាគារអេស៊ីលីដា ជូនដល់អតិថិជន ដើម្បីធ្វើប្រតិបត្តិការតាមម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិ (ATM)	 ប័ណ្ណធម្មតា ប័ណ្ណព័ណ៌មាស
ប័ណ្ណវីសាអេស៊ីលីដា ជាប្រភេទប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការទូទាត់ចំណាយផ្សេងៗតាមម៉ាស៊ីនឆូតកាត ឬដកសាច់ប្រាក់តាមម៉ាស៊ីនអេធីអឹម ដែលមានបិទស្លាកសញ្ញា VISA ឬ VISA Plus នៅទូទាំងប្រទេស និងពាសពេញពិភពលោក	 ប័ណ្ណឥណទាន ប័ណ្ណឥពន្ធ ប័ណ្ណឥទានមាស

ប័ណ្ណម៉ាស្ទ័រកាតអេស៊ីលីដា ជាប្រភេទប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការទូទាត់ចំណាយផ្សេងៗតាមម៉ាស៊ីនឆូតកាត ឬដកសាច់ប្រាក់តាមម៉ាស៊ីនអេធីអឹម ដែលមានបិទស្លាកសញ្ញា Mastercard នៅទូទាំងប្រទេស និងពាសពេញពិភពលោក	 ប័ណ្ណឥណទាន ប័ណ្ណឥណពន្ធ ប័ណ្ណឥទានមាស
ប័ណ្ណចេស៊ីប៊ីអេស៊ីលីដា ជាប្រភេទប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការដកសាច់ប្រាក់នៅតាមម៉ាស៊ីនអេធីអឹម និងទូទាត់ចំណាយផ្សេងៗតាមម៉ាស៊ីនឆូតកាត ឬតាមអ៊ីនធើណេតដែលមានបិទស្លាកសញ្ញាចេស៊ីប៊ីនៅទូទាំងប្រទេស និងពាសពេញពិភពលោក ។	 ប័ណ្ណឥណពន្ធ - ប្រាក់រៀល ប័ណ្ណឥណពន្ធ - ប្រាក់ដុល្លារអាមេរិក

ប័ណ្ណយូភីអាយអេស៊ីលីដា ជាប្រភេទប័ណ្ណសម្រាប់ធ្វើប្រតិបត្តិការដកសាច់ប្រាក់នៅតាមម៉ាស៊ីនអេធីអឹម និងទូទាត់ចំណាយផ្សេងៗ តាមម៉ាស៊ីនឆូតកាត ឬតាមអ៊ីនធើណេត ដែលមានបិទស្លាកសញ្ញា Union-Pay នៅទូទាំងប្រទេស និងពាសពេញពិភពលោក ។	

តារាងទី៨ ៖ សេវាកម្ម និងផលិតផល (ប័ណ្ណ)

ជំពូកទី៣
ដំណើរការចោះផ្សាយលក់
មូលបត្រកម្មសិទ្ធិរបស់
ធនាគារអេស៊ីលីជា តីអិលស៊ី

ជំពូកទី៣

ជំណើរការចោះផ្សាយលក់មូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី

មុនថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេសដែលមានទីស្នាក់ការនៅរាជធានីភ្នំពេញ និងមានសាខាចំនួន ១៤ ក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ២០០៣ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារពាណិជ្ជឯកទេស សម្រាប់រយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០០៣។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ ២០០៦ អាជ្ញាប័ណ្ណរបស់ធនាគារត្រូវបានប្តូរសារជាថ្មីម្តងទៀតទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍។ ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅ អាគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនញេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងឆ្នាំ២០១៩ ក្រុមប្រឹក្សាភិបាលរបស់ធនាគារអេស៊ីលីដាបានលើកយកសំណើដើម្បីស្នើសុំធ្វើការចោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាលើកដំបូង (IPO)។ បន្ទាប់មកទៀតនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ធនាគាអេស៊ីលីដា ទទួលបានលិខិតអនុញ្ញាតពីធនាគារជាតិនៃកម្ពុជាសម្រាប់បន្តគម្រោង IPO បន្តទៀត។ រហូតមកដល់ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ សេចក្តីប្រកាសជាសាធារណៈស្តីពីការធ្វើ IPO ត្រូវបានធ្វើឡើងដោយធនាគារអេស៊ីលីដា។ ក្រោយមកនៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០២០ ធនាគារជោគជ័យនៅក្នុងការចុះបញ្ជីនៅលើទីផ្សារមូលបត្រកម្ពុជា។ ភាគហ៊ុនថ្មីត្រូវបានបោះផ្សាយចំនួន ៤.៣៤៤.៨៦៥ ភាគហ៊ុន ក្នុងតម្លៃចាវីក ៤.០០០រៀល (០.៩៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន នៅក្នុងតម្លៃបោះផ្សាយ ១៦.២០០រៀល (៣.៩៧ ដុល្លារអាមេរិក) នៃចំនួនភាគហ៊ុនដែលបានចុះបញ្ជីសរុប ៤៣៣.១៦៣.០១៩ ភាគហ៊ុន។ ធនាគារទទួលបានសាច់ប្រាក់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងចំនួន ១៧.០៨២.១០៥ ដុល្លារ អាមេរិក និងចំណាយថ្លៃដើមអស់ ១.០៣១.០២៥ ដុល្លារអាមេរិក ដែលទទួលបានបុព្វលាភភាគហ៊ុន ចំនួន ១១.៧០៦.២១៥ ដុល្លារអាមេរិក (៤៧.៧២៦.២៣៩ ពាន់រៀល)។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ ២០២០ ម្ចាស់ភាគហ៊ុនបានអនុម័តឱ្យកែប្រែលក្ខន្តិកៈក្រុមហ៊ុនទាក់ទងនឹងការបង្កើនដើមទុនសម្រាប់ការចោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ ២០២១ ធនាគារបានដាក់លិខិតស្នើសុំធនាគារ ជាតិនៃកម្ពុជាក្នុងការបង្កើនដើមទុន ហើយត្រូវបានអនុម័តនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១។ ការកែប្រែលក្ខន្តិកៈ ក្រុមហ៊ុនក៏ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១[29]។

[29] ធនាគារអេស៊ីលីដា, របាយការណ៍ប្រចាំឆ្នាំ ២០២១ https://www.acledabank.com.kh/kh/eng/bp_annualreport ទំព័រទី០១ (ចូលទស្សនាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២)

រូបភាពទី៤៖ វិញ្ញាបនប័ត្រចុះបញ្ជីមូលបត្រ

៣.១ ព័ត៌មានក្រុមហ៊ុនពាក់ព័ន្ធនឹងការបោះផ្សាយ IPO

ដើម្បីធ្វើការបោះផ្សាយមូលបត្រជាលើកដំបូង ធនាគារអេស៊ីលីដា ភីអិលស៊ី មិនអាចអនុវត្តនីតិវិធីនានាក្នុងការបោះផ្សាយមូលបត្រតែម្នាក់ឯងនោះទេ។ យោងតាមយន្តការណែនាំស្តីពីការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងចេញផ្សាយដោយ គ.ម.ក ធនាគារអេស៊ីលីដា ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈលើកដំបូងដែលរួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនផ្តល់សេវាសវនកម្ម និងក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់ជាដើម។ ក្រុមហ៊ុនទាំងអស់នេះត្រូវមានការទទួលស្គាល់ពី គ.ម.ក ផងដែរ។

ក្រុមហ៊ុនធានាទិញមូលបត្រដែលទទួលស្គាល់ដោយ គ.ម.ក មានចំនួន ៧ ក្នុងនោះមាន (១) យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (២) អ អេច ប៊ី ស៊ីឃ្យូរីធី (ខេមបូឌា) ម.ក (៣) កាណា ស៊ីឃ្យូរីធី អិលធីឌី (៤) កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (៥) អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី និង (៦) ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (៧) ខេមបូឌា ស៊ីឃ្យូរីធី ម.ក។

បច្ចុប្បន្ន ក្រុមហ៊ុនផ្តល់សេវាសវនកម្មទទួលស្គាល់ដោយ គ.ម.ក មានចំនួន ៨ ដូចជា (១) ក្រុមហ៊ុន ប្រាយវ័តធែរ ហាវខូភើស៍ (ខេមបូឌា) (២) ក្រុមហ៊ុន ខេ ភី អឹម ជ្ជី ខេមបូឌា (៣) ក្រុមហ៊ុន ប៊ី ឌី អូ (ខេមបូឌា)

លីមីធីត (៤) ក្រុមហ៊ុន អឺនស្ត៍ អែន យ៉ុង (ខេមបូឌា) (៥) ក្រុមហ៊ុន ព្រ្មុន សថដុន (ខេមបូឌា) លីមីធីត (៦) ក្រុមហ៊ុន ក្លូវ (ខេមបូឌា) ឯ.ក (៧) ក្រុមហ៊ុន ឌីឡ្វីយធ៏ (ខេមបូឌា) ខូ អិលធីឌី និង (៨) ក្រុមហ៊ុន បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក[30]។

ឯក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់មានអាជ្ញាប័ណ្ណពី គ.ម.ក មានចំនួន ១៥ ដូចជា (១) ក្រុមហ៊ុនមេធាវី អេច ប៊ី អេស (២) ការិយាល័យមេធាវី អ អេន ធី សុខ អេន ហេង (៣) ការិយាល័យមេធាវី សុក ស៊ីផាន់ណា និងសហការីជាំសមាជិក ZICO law (៤) ការិយាល័យមេធាវី សិទ្ធិស័ក្តិ (៥) ក្រុមមេធាវី អាស៊ី កម្ពុជា (៦) ការិយាល័យមេធាវី ប៊ុន និងសហការី (៧) ការិយាល័យមេធាវី ភីវ៉ាយធី និង សហការី (៨) ការិយាល័យមេធាវី ស៊ី អេស អែល និង សហភាគា (៩) ក្រុមមេធាវី អេច.អឹម.អិល & ខន់សាល់ថិន (១០) ការិយាល័យមេធាវី សុិន & ផាតនើ (១១) ក្រុមមេធាវី កម្ពុជាបាយ័ន (ស៊ី ប៊ី អិល) (១២) ក្រុមមេធាវី មេគង្គ (១៣) ក្រុមមេធាវី កម្ពុជាសហប្រតិបត្តិការអន្តរជាតិ (១៤) ក្រុមមេធាវី ស៊ី អេស ភី និង សហការី និង (១៥) ការិយាល័យមេធាវី សិដ្ឋាល័យ[31]។

ក្រុមហ៊ុនដែល ធនាគារអេស៊ីលីដា បានជ្រើសរើសក្នុងក្រុមការងារបោះផ្សាយមូលបត្រជាលើកដំបូងមាន ដូចជា៖

- ធនាគារអេស៊ីលីដា ភីអិលស៊ី (ក្រុមហ៊ុនបោះផ្សាយ)
- ក្រុមហ៊ុន យាន់តា ស៊ីយ៉ូរីធី (ខេមបូឌា) ភីអិលស៊ី (ក្រុមហ៊ុនធានាទិញមូលបត្រ)
- ការិយាល័យមេធាវី សិទ្ធិស័ក្តិ (ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់)
- ក្រុមហ៊ុន ខេ ភី អឹម ជ្វី ខេមបូឌា (ក្រុមហ៊ុនផ្តល់សេវាសវនកម្ម)

ខាងក្រោមនេះ ជាតារាងព័ត៌មាននៃក្រុមហ៊ុនដែលពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិនៃធនាគារ អេស៊ីលីដា ភីអិលស៊ី។

៣.១.១. ព័ត៌មានទូទៅអំពីក្រុមហ៊ុនបោះផ្សាយ

ឈ្មោះក្រុមហ៊ុន	ធនាគារអេស៊ីលីដា ភីអិលស៊ី
អាសយដ្ឋាន	អគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

[30] https://www.serc.gov.kh/khmer/m53.php?pn=6 (ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២)

[31] https://www.serc.gov.kh/khmer/m58.php?pn=6 (ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២)

លេខទូរស័ព្ទ	+៨៥៥ (0)២៣ ៩៩៨ ៧៧៧; +៨៥៥ (0)២៣ ៤៣0 ៩៩៩
លេខទូរសារ	+៨៥៥ (0)២៣ ៤៣0 ៥៥៥
ប្រអប់សំបុត្រ	១១៤៩
អ៊ីម៉ែល	acledabank@acledabank.com.kh
គេហទំព័រ	https://www/acledabank.com.kh
លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម	0000៣0៧៧
លេខអាជ្ញាប័ណ្ណពីធនាគារជាតិ	0៦

តារាងទី៩៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនបោះផ្សាយមូលបត្រ

៣.១.២. ព័ត៌មានទូទៅអំពីក្រុមហ៊ុនធានាទិញមូលបត្រ

ឈ្មោះក្រុមហ៊ុន	ក្រុមហ៊ុន យាន់តា ស៊ីឃ្យួរីធី (ខេមបូឌា) ភីអិលស៊ី
អាសយដ្ឋាន	អគារ Emerald ជាន់ទី ៤ លេខ ៦៤ (កែងផ្លូវ ១៧៨) មហាវិថីព្រះនរោត្តម សង្កាត់ជ័យជំនះ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទូរស័ព្ទ	+៨៥៥ (0)២៣ ៨៦0 ៨00
លេខទូរសារ	+៨៥៥ (0)២៣ ២២៤ ១២៦
អ៊ីម៉ែល	yuanta@yuantacambodia.com
គេហទំព័រ	https://www.yuantacambodia.com
លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម	0001៤៥៥២
លេខអាជ្ញាប័ណ្ណអាជីវកម្ម	00៧ គ.ម.ក/ក.គ

តារាងទី១0៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនធានាទិញមូលបត្រ

៣.១.៣. ព័ត៌មានទូទៅអំពីក្រុមហ៊ុនសេវាកម្មផ្នែកច្បាប់

ឈ្មោះក្រុមហ៊ុន	ការិយាល័យមេធាវី សិទ្ធិសិ្ត
ឈ្មោះមេធាវីតំណាង	១. លោក សុន សុខកេង ២. លោក តាន់ ម៉ែងស្រួយ ៣. លោកស្រី ម៉ែង ម៉ាណែត
អាសយដ្ឋាន	អគារ Millennium លេខ៦៨ ជាន់ទី៣ ផ្លូវ ៥៧ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទូរស័ព្ទ	+៨៥៥ (0)២៣ ៦៣៧៣១៦៨
អ៊ីម៉ែល	sokeng.son@sithisak-lawoffice.com
គេហទំព័រ	https://www.sithisak-lawoffice.com
លេខវិញ្ញាបនបត្រចុះបញ្ជីចេញដោយគណៈមេធាវីកម្ពុជា	L00៧៨/១៩
លេខចុះបញ្ជីទទួលស្គាល់ពី គ.ម.ក	០០៣ គ.ម.ក កា.ម

តារាងទី១១៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

៣.១.៤. ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាសវនកម្ម

ឈ្មោះក្រុមហ៊ុន	ក្រុមហ៊ុន ខេ ភី អឹម ជ្ជី ខេមបូឌា (KPMG)
ឈ្មោះសវនកម្មឯករាជ្យ	លោក ង៉ែត ហ៊ុយ
អាសយដ្ឋាន	ប្រអប់សំបុត្រ ២៣៥២ អគារ Delana ជាន់ទី៤ ផ្លូវ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
លេខទូរស័ព្ទ	+៨៥៥ (0)២៣ ២១៦ ៨៩៩
លេខទូរសារ	+៨៥៥ (0)២៣ ២១៧ ២៧៩
អ៊ីម៉ែល	kpmg@kpmg.com.kh
គេហទំព័រ	https://www.kpmg.com.kh
លេខចុះបញ្ជីជាសមាជិក វ.គ.ស.ក	I-0000៥
លេខចុះបញ្ជីទទួលស្គាល់ពី គ.ម.ក	០០៨ គ.ម.ក/ស.ង

តារាងទី១២៖ ព័ត៌មានទូទៅអំពីក្រុមហ៊ុនផ្តល់សេវាសវនកម្ម

៣.១.៥. កិច្ចព្រមព្រៀងធានាទិញមូលបត្រ

សម្រាប់ការបោះផ្សាយនេះ គឺមិនមានការធានាទិញមូលបត្រពី ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី ឬបុគ្គលណាម្នាក់ឡើយ។ ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី គឺជាទីប្រឹក្សាហិរញ្ញវត្ថុតែមួយគត់ នៅក្នុងសំណើបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនេះ។ ក្រុមហ៊ុន យាន់តា និងក្រុមហ៊ុនបោះផ្សាយបានចុះកិច្ចព្រមព្រៀងដោយអនុញ្ញាតឱ្យ ក្រុមហ៊ុន យាន់តា ខិតខំឱ្យអស់ពីលទ្ធភាពក្នុងការលក់មូលបត្រកម្មសិទ្ធិនេះទៅសាធារណៈជន។

៣.១.៦. ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈជាសាធារណៈ

ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈរបស់ ធនាគារអេស៊ីលីដា ភីអិលស៊ី មានចំនួនប្រហែល ១.000.000 ដុល្លារអាមេរិក ដែលមានបង្ហាញដូចក្នុងតារាងខាងក្រោម៖

ក្រុមហ៊ុនធានាទិញមូលបត្រ	៥៦៧.០៩០ ដុល្លារអាមេរិក
ទីប្រឹក្សាច្បាប់	៦១.៤៤០ ដុល្លារអាមេរិក
ក្រុមហ៊ុនផ្តល់សេវាសវនកម្ម	៩៣.១៥០ ដុល្លារអាមេរិក
បោះពុម្ព និងផ្សព្វផ្សាយ	៦៨.៨៦៨ ដុល្លារអាមេរិក
ចុះបញ្ជីឯកសារផ្តល់ព័ត៌មាន*	៣.000 ដុល្លារអាមេរិក
ពិនិត្យលទ្ធភាពចុះបញ្ជី*	១.000 ដុល្លារអាមេរិក
ថ្លៃចុះបញ្ជី	១៨៩.៣១៦ ដុល្លារអាមេរិក
ចំណាយផ្សេងៗ	១៦.១៣៦ ដុល្លារអាមេរិក

*ការទូទាត់ជាក់ស្តែងជាប្រាក់រៀល។ យើងសន្មតថាអត្រាប្តូរប្រាក់ស្មើ ៤.000រៀល/ដុល្លារអាមេរិក។

តារាងទី១៣៖ ចំណាយពាក់ព័ន្ធនឹងការបោះផ្សាយមូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ

៣.២. ការបង្ហាញព័ត៌មានហិរញ្ញវត្ថុរបស់ធនាគារ

របាយការណ៍ហិរញ្ញវត្ថុពិតជាមានសារៈសំខាន់ណាស់ ទាំងក្រុមហ៊ុន វិនិយោគិន រួមទាំងសាធារណៈជន ទូទៅដើម្បីឈ្វេងយល់អំពីដំណើរការរបស់ក្រុមហ៊ុនប្រចាំដើម្បីឱ្យមហាជន និងវិនិយោគិនសិក្សា និងវិភាគមុន

ធ្វើការវិនិយោគ។ ខាងក្រោមនេះរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គិតត្រឹម ៣ឆ្នាំចុងក្រោយ(២០១៧,២០១៨,២០១៩ ត្រីមាសទី៣)៖[32]

- **តារាងតុល្យការរួមរបស់ធនាគារ អេស៊ីលីដា**

ឯកតាគិតជាដុល្លារអាមេរិក	២០១៧	២០១៨	២០១៩(ត្រីមាសទី៣)
ទ្រព្យសកម្ម			
សាច់ប្រាក់ក្នុងដៃ	៣២១.៧៤៤.២៤៥	៤០៧.៨៦៤.៧០៣	៤២៧.៦៨៨.៧០៨
សមតុល្យក្នុងធនាគារកណ្តាល	១.៤៩៧.១៣៣.៣២៤	១.៤៧០.៥៩២.៥១៤	១.៧៣៣.៦៣១.០៧៧
សមតុល្យក្នុងធនាគារផ្សេងៗ	១២០.២៥៤.៩១៧	២៦.៥៦៧.៦៩២	១៣៤.៩៦៤.៨៣២
ឥណទាន និងបុរេប្រទានអតិថិជន	៣.០៨៥.២១៤.៦៥១	៣.៥១៣.៥៩៣.៨១៥	៣.៦៥៩.២៦៤.៥៩៤
ទ្រព្យសកម្មផ្សេងៗ	៤៩.៥៦៩.៧៧៩	៥១.៣៥១.៤០២	៥១.១៤៩.៨២២
ប្រាក់បញ្ញើតម្កល់តាមច្បាប់	៣០៧.១៥៩	២៤៨.៨៨០	២៤៤.១៤១
ទ្រព្យសម្បត្តិ និងបរិក្ខារ	១៣៣.៣២៨.២៨៧	១៣៧.៨៦២.០៩៧	១៣៣.២៧៦.២៧៧
ទ្រព្យសកម្មអរូបី	១១.៣៤០.៣៤៥	១១.១៩៧.៨៨៧	៩.១០៥.០៨០
ពន្ធពន្យារទ្រព្យសកម្ម	២៥.៣២១.០២៤	២១.៩៣៩.៩១៧	២៣.១១៨.៨៣១
ការវិនិយោគផ្សេងៗ	១៥៣.៥២៩	១៥៣.៥២៩	១៥៣.៥២៩
ទ្រព្យសកម្មសរុប	៥.២៤៤.៣៦៧.២៦០	៥.៦៤១.៣៧២.៤៣៦	៦.១៧២.៥៩៦.៨៩១
បំណុល និងមូលធនបំណុល			
ប្រាក់បញ្ញើរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេង	២១២.៤៥៥.០៨៩	២៨៦.៩៤១.៣០៩	២៩៤.០៥៣.២១៨
ប្រាក់បញ្ញើរបស់អតិថិជន	៣.១១៧.២០៩.៧២៦	៣.៥៤៨.៨៨៩.០៤០	៤.០៤៩.៥៨១.៥១៥

[32] https://www.acledabank.com.kh/kh/assets/pdf_zip/disclosure (ចូលទស្សនាថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២២)

បំណុលផ្សេងៗ	៧៨.៤២២.១៧១	៦៣.៧៥១.១០៨	៥៦.៥៩៧.៥៥១
ប្រាក់កម្ចី	៦០៨.៤៨៨.៨០៣	៥៤២.៣៩៨.៩១៦	៥១៨.០៦៨.១២៨
សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យការ	១.៨១៤.៦២០	១.៦៦៦.១៤៧	១.៥៤១.៦៧២
បំណុលផ្សេងៗ	៨៦.០៩៧.៣៤២	១០៣.៩៦៣.៧០៤	១១៨.៥៤០.៣៨២
ប្រាក់កម្ចី	៩០៦.៣៧៨.១៨២	៧៨៤.៦៧១.៨៧៩	៧១២.៦៧៣.០៩៩
បំណុលបន្ទាប់បន្សំ	១០៨.៦៨៤.០៩០	៧៧.១០១.៤៩០	៦៤.៦០១.៤៩០
បំណុលពន្ធលើប្រាក់ចំណេញក្នុងគ្រា	២៣.៩៧១.៦០៥	១៣.៨១០.៩៩៧	២៣.២០៦.១៣៥
អត្ថប្រយោជន៍បុគ្គលិក	៤៧.៥៤១.២៨៤	១៧.៩៥២.៥០៥	១៨.០៧៣.១៩៩
បំណុលសរុប	៤.៥០៤.១៥១.៩៣៨	៤.៨៣៤.៩៩៧.០៧១	៥.២៨២.២៧០.៧១០
មូលធន			
ដើមទុន	៣៥៨.៥៤៤.៩៥៦	៣៩៥.២២៤.១០៥	៤២៨.៨១៨.១៥៤
ទុនបម្រុងទូទៅ	៣០២.១៤៨.៤១០	៣៤៨.១៦២.៨០៦	៣៩០.១៥៩.៧៥២
ទុនបម្រុងសម្រាប់ប្តូរប្រែប័ណ្ណ	(២.៥១២.៤៩៩)	(៦.៧៤១.៤៧០)	(៧.៩៣៩.៩៦៦)
ទុនបម្រុងផ្សេងៗ	(១៤.១៣២.០០៧)	(១៤.២៧៩.៣៤៤)	(១៤.២៧៩.៣៤៤)
ប្រាក់ចំណេញរក្សាទុក	៩១.៦៨៤.៥០៤	៨៤.០០៩.២៦៨	៩៣.៥៦៧.៥៨៥
	៧៣៥.៧៣៣.៣៦៤	៨០៦.៣៧៥.៣៦៥	៨៩០.៣២៦.១៨១
អប្បភាគភាគកម្ម	៤.៤៨១.៩៥៨	-	-
មូលធនសរុប	៧២០.២១៥.៣២២	៨០៦.៣៧៥.៣៦៥	៨៩០.៣២៦.១៨១
បំណុល និងមូលធនសរុប	៥.២៤៤.៣៦៧.២៦០	៥.៦៤១.៣៧២.៤៣៦	៦.១៧២.៥៩៦.៨៩១

តារាងទី១៤៖ តុល្យការរួមរបស់ធនាគារអេស៊ីលីដា

❖ **របាយការណ៍លទ្ធផលរួមរបស់ធនាគារអេស៊ីលីដា**

ឯកតាគិតជាដុល្លាអាមេរិក	២០១៧	២០១៨	២០១៩(ត្រីមាសទី៣)
ចំណូលការប្រាក់	៤២៥.៣៤៥.៦២៩	៤២៣.២៥៦.១៨៤	៣៤១.៣៤៦.៣៣៣
ចំណាយការប្រាក់	(១៤៩.៦៤១.២៦០)	(១៥១.៤០៤.៦៨២)	(១១៦.១០០.២២១)
ចំណូលការប្រាក់សុទ្ធ	**២៧៥.៧០៤.៣៦៩**	**២៧១.៨៥១.៥០២**	**២៥៥.២៤៦.១១២**
ចំណូលកម្រៃ និងជើងសា	៥៨.៨១២.០១៩	៦៤.៤១៣.៤១៨	៥៤.០១០.៦៥៣
ចំណាយកម្រៃ និងជើងសា	(២.៨៦៧.០៦១)	(៧៤៩.៥០១)	(៥៤៨.៧៩៣)
ចំណូលកម្រៃ និងជើងសាសុទ្ធ	៥៥.៩៩៤.៩៥៨	៦៣.៦៦៣.៩១៧	៥៣.៤៦១.៨៦០
សំវិធានធនឥណទានបាត់បង់ និងសមតុល្យនៅធនាគារផ្សេងៗ	(៣៤.២៥០.៣២៤)	(៤០.៧១១.១១០)	(៩.៧០៧.១៥០)
សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យសំវិធានធនឥណទានបាត់បង់ និងសមតុល្យនៅធនាគារផ្សេងៗ សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យការការ-សុទ្ធ	**(៣៦.០៦៤.៩៤៤)**	**(៤០.៥៦៨.៨៦២)**	**(៩.៥៧៦.១២១)**
ចំណូលបន្ទាប់ពីការកាត់កងសំវិធានធន-សុទ្ធ	**(៣៦.០៦៤.៩៤៤)**	**(៤០.៥៦៨.៨៦២)**	**(៩.៥៧៦.១២១)**
ចំណូលផ្សេងៗ	១០.៦០១.៨២៤	១៤.៩៣៣.៩១៦	១២.៥៤៥.៤៩០
ចំណាយបុគ្គលិក	(១១២.២៣៨.៨៦៩)	(១២៥.៩២២.២៣១)	(១០៤.៤១០.៧២៧)
ចំណាយទូទៅ និងរដ្ឋបាល	(៥២.៣០៨.៧៣៦)	(៥១.៨៦៥.៦៥៨)	(៣៩.៧៣៤.២៦០)

ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ	(២១.២៦៥.២២៦)	(២១.៩៣៤.៨៤៨)	(១៦.០០៥.១០៤)
ចំណាយរំលស់ទ្រព្យសកម្មអរូបី	(៤.០៥១.០៨៤)	(៣.៥៥០.០៥៥)	(២.៦៩៦.៣០៨)
	(១៨៩.៨៦៣.៩១៥)	(២០៣.២៧២.៧៩២)	(១៦២.៨៤៦.៣៩៩)
ចំណេញមុនបង់ពន្ធលើប្រាក់ចំណេញ	**១១៦.៣៧២.២៩២**	**១០៦.៦០៧.៦៨១**	**១១៨.៨៣០.៩៤២**
ចំណាយពន្ធលើប្រាក់ចំណេញ	(២៣.៨២២.២៩៤)	(២២.៥៩៨.៤២៣)	(២៥.៦៦៣.៣៥៧)
ចំណេញក្នុងគ្រា	**៩២.៥២៧.៨៩៨**	**៨៤.០០៩.២៦៨**	**៩៣.៥៦៧.៥៨៥**
ត្រូវបែងចែកជូន៖			
ម្ចាស់ភាគហ៊ុនរបស់ធនាគារ	៩១.៦៨៤.៥០៤	៨៤.០០៩.២៦៨	៩៣.៥៦៧.៥៨៥
អប្បភាគភាគកម្ម	៨៤៣.៤៩៤	-	-
	៩២.៥២៧.៩៩៨	៨៤.០០៩.២៦៨	៩៣.៥៦៧.៥៨៥

តារាងទី១៥៖ របាយការណ៍លទ្ធផលរួមរបស់ធនាគារអេស៊ីលីដា

៣.៣. ការពិពណ៌នាអំពីមូលបត្រកម្មសិទ្ធិចេញផ្សាយដំបូង (IPO)

៣.៣.១. ព័ត៌មានស្តីពីមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់

យោងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល កាលពីថ្ងៃទី ២១-២២ ខែមីនា ឆ្នាំ ២០១៩ ក្រុមប្រឹក្សាភិបាលបានសម្រេចអនុម័ត និងស្នើទៅកាន់ភាគហ៊ុនិកសម្រាប់ការអនុម័តជាចុងក្រោយលើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈទាំងមូលបត្រកម្មសិទ្ធិថ្មី និងមូលបត្រកម្មសិទ្ធិដែលកំពុងកាន់កាប់មិនលើសពី ២០% នៃមូលបត្រកម្មសិទ្ធិសរុបរបស់ធនាគារដើម្បីចុះបញ្ជីមូលបត្រនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។

ធនាគារអេស៊ីលីដា ភីអិលស៊ី និងភាគហ៊ុនិករបស់ធនាគារបានសម្រេចធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិថ្មីចំនួន ២%ដែលស្មើនឹង ៨,៧៥១,៣៩១ និងមូលបត្រកម្មសិទ្ធិបច្ចុប្បន្នរហូតដល់ ៣%ដែលស្មើនឹង ១៣,១២៧,០៨៦ ភាគហ៊ុន ផ្អែកតាមលទ្ធភាពនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម។

ប្រភេទមូលបត្រកម្មសិទ្ធិ	ប្រភេទមូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ	៤,000 រៀល (១.00 ដុល្លារអាមេរិក)
លក់ក្នុងតម្លៃមួយឯកតាមូលបត្រកម្មសិទ្ធិ	១៦,២០០ រៀល
ចំនួនមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់	៨,៧៥១,៣៩១ ភាគហ៊ុន
ចំនួនមូលបត្រកម្មសិទ្ធិបច្ចុប្បន្នដែលធ្វើសំណើលក់	រហូតដល់ ១៣,១២៧,០៨៦ ភាគហ៊ុន អាស្រ័យលើការសម្រេចចិត្តរបស់ភាគហ៊ុនិក ផ្អែកតាមលទ្ធផលនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម
កាលបរិច្ឆេទការធ្វើប៊ុកបៀលឌីង	០៣/មីនា/២០២០ ដល់ ១៤/មីនា/២០២០
កាលបរិច្ឆេទធ្វើបរិវិសកម្ម	២៤/មីនា/២០២០ ដល់ ២៤/មេសា/២០២០
ទីកន្លែងនៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម	សាខាអេស៊ីលីដា និងក្រុមហ៊ុនស៊ីយ៉ូរីធីមួយចំនួន

តារាងទី១៦៖ លក្ខខណ្ឌនៃសំណើមូលបត្រ

៣.៣.២. ផែនការបែងចែកមូលបត្រកម្មសិទ្ធិ

មូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់ដោយធនាគារ ត្រូវបានបែងចែកទៅឱ្យវិនិយោគិនជា ពីរដំណាក់កាល គឺ ដំណាក់កាលនៃការធ្វើប៊ុកបៀលឌីង និងដំណាក់កាលនៃការធ្វើបរិវិសកម្ម។ ខាងក្រោមជាតារាងផែនការបែងចែកមូលបត្រ។

	ចំនួនមូលបត្រធ្វើការបែងចែក	ប្រភេទ
ការធ្វើប៊ុកបៀលឌីង	៤,៣៧៥,៦៩៦	មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
ការធ្វើបរិវិសកម្ម	ពី ៤,៣៧៥,៦៩៥ ទៅ ១៧,៥០២,៧៨១	មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោត
សរុប	យ៉ាងតិច ៨,៧៥១,៣៩១	

តារាងទី១៧៖ ផែនការបែងចែកមូលបត្រ

៣.៣.៣. តម្លៃមួយឯកតានៃមូលបត្រកម្មសិទ្ធិ

តម្លៃមូលបត្រកម្មសិទ្ធិពី ១៥,០០០ រៀល ទៅ ១៧,៥០០ រៀល (៣.៧៥ ដុល្លារអាមេរិក ទៅ ៤.៣៥ ដុល្លារអាមេរិក) ដែលបានដាក់ឱ្យវិនិយោគិនធ្វើការកំណត់ថ្លៃក្នុងរង្គប៊ុកបៀលឌីង គឺផ្អែកលើការវាយតម្លៃដោយប្រៀបធៀប (Relative Valuation) ជាមួយក្រុមហ៊ុនដែលស្រដៀងគ្នាក្នុងអាជីវកម្មធនាគារក្នុងតំបន់។

ក្រុមហ៊ុនធានាទិញមូលបត្រជឿជាក់ថា ការវាយតម្លៃធនាគារអេស៊ីលីដា ភីអិលស៊ី ដោយប្រើវិធីសាស្ត្រវាយតម្លៃដោយប្រៀបធៀប (Relative Valuation) គឺមានលក្ខណៈសមស្របជាងការប្រើវិធីសាស្ត្រវាយតម្លៃដាច់ខាត (Absolute Model) ឬវិធីសាស្ត្រលំហូរសាច់ប្រាក់អប្បរហារ (Discounted Cash Flow Model) ដែលតម្រូវឱ្យមានការប៉ាន់ស្មានទាំងលំហូរសាច់ប្រាក់ និងអត្រាអប្បហារ។ ព័ត៌មានសំខាន់ៗសម្រាប់ប៉ាន់ស្មានតម្លៃដើមនៃមូលធន (Cost of Equity) ដូចជាការប្រែប្រួលនៃបែលតា (Beta) អត្រាសំណងលើហានិភ័យមូលធន (Equity Risk Premium) និងអត្រាសំណងគ្មានហានិភ័យ (Risk Free Rate) មិនមានស្រាប់នោះទេនៅប្រទេសកម្ពុជា ដោយសារគ្មានការជួញដូរមូលបត្ររដ្ឋ ហើយទីផ្សារមូលធនទើបតែចាប់ផ្តើមនៅឡើយ។ ដូចនេះ ការប្រើវិធីសាស្ត្រតម្លៃដាច់ខាតនឹងមានការសន្មតជាច្រើនដែលធ្វើឱ្យការវាយតម្លៃជាច្រើនដែលធ្វើឱ្យការវាយតម្លៃជារួម មិនអាចប្រើប្រាស់បានបើប្រៀបធៀបទៅនឹងវិធីសាស្ត្រវាយតម្លៃដោយប្រៀបធៀប។

តម្លៃក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិដែលធ្វើសំណើលក់គឺស្មើនឹង ១៦,២០០ រៀល។ ធនាគារអេស៊ីលីដា និងក្រុមហ៊ុនធានាទិញមូលបត្របានកំណត់ថ្លៃចុងក្រោយ ដោយផ្អែកលើនីតិវិធីនៃការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្ម។ តម្លៃចុងក្រោយនេះត្រូវបានអនុម័តដោយ ធ.ម.ក និង គ.ម.ក។

៣.៣.៤. សាច់ប្រាក់ដែលបានមកពីការចោះផ្សាយលក់មូលបត្រកម្មសិទ្ធិ

តាមរយៈការចោះផ្សាយមូលបត្រកម្មសិទ្ធិថ្មីចំនួន ៨,៧៥១,៣៩១ ភាគហ៊ុន (មានសិទ្ធិចោះឆ្នោត) ដែលមានតម្លៃនឹង ១៦,២០០រៀល ធនាគារអេស៊ីលីដា នឹងទទួលបានសាច់ប្រាក់សុទ្ធពីការចោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈចំនួនប្រហែល ១៣៧.៨ ពាន់លានរៀល (ប្រហែល ៣៤.៤៤ លានដុល្លារអាមេរិក)។ ធនាគារអេស៊ីលីដា មានបំណងប្រើប្រាស់សាច់ប្រាក់ដែលទទួលបានពីការចោះផ្សាយនេះសម្រាប់គោលបំណងសាជីវកម្មទូទៅ។

៣.៤. សិទ្ធិរបស់ភាគហ៊ុនិក

ការទិញភាគហ៊ុនត្រលប់ដោយក្រុមហ៊ុន

ធនាគារអាចទិញភាគហ៊ុនរបស់ខ្លួនត្រឡប់មកវិញ ដោយត្រូវមានការយល់ព្រមជាមុនដោយសំឡេង

ឆ្នោតគាំទ្រយ៉ាងតិចចំនួន ២/៣ នៃសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងដោយសំឡេងឆ្នោតគាំទ្ររបស់ភាគហ៊ុនិកភាគច្រើន ២/៣ នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតសរុប ព្រមទាំងត្រូវអនុលោមតាមនីតិវិធីច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ទីកន្លែងនៃមហាសន្និបាតភាគហ៊ុនិក

មហាសន្និបាតភាគហ៊ុនត្រូវធ្វើឡើងនៅទីស្នាក់ការកណ្តាល ឬនៅទីកន្លែងផ្សេងទៀតដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ឬភាគហ៊ុនិកដែលជាអ្នកកោះប្រជុំ។

ការជូនដំណឹងអំពីមហាសន្និបាតភាគហ៊ុនិក

ប្រធានក្រុមប្រឹក្សាភិបាល ឬក្រុមប្រឹក្សាភិបាលត្រូវជូនដំណឹងអំពីមហាសន្និបាតភាគហ៊ុនិកតាមរយៈលិខិតជាលាយលក្ខណ៍អក្សរ ឬតាមមធ្យោបាយអេឡិចត្រូនិកដល់ភាគហ៊ុនិកទាំងអស់ដែលមានសិទ្ធិក្នុងការចូលរួមមហាសន្និបាតភាគហ៊ុនិកឱ្យបានយ៉ាងតិច ២០ថ្ងៃ ប៉ុន្តែមិនឱ្យលើសពី ៥០ថ្ងៃ មុនកាលបរិច្ឆេទមហាសន្និបាតឡើយ។ ការជូនដំណឹងនោះត្រូវបញ្ជាក់កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងមហាសន្និបាត ព្រមទាំងរបៀបវារៈដែលត្រូវពិភាក្សា និងសម្រេចផងដែរ។

ការកែប្រែរបៀបវារៈមហាសន្និបាតភាគហ៊ុនិក

ភាគហ៊ុនិកចូលរួមមហាសន្និបាតដោយផ្ទាល់ ឬតាមរយៈអាណត្តិគាហកដែលកាន់កាប់ភាគហ៊ុនយ៉ាងហោចណាស់ ៧៥% (ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតទើបអាចកែប្រែរបៀបវារៈមហាសន្និបាតបានក្នុងពេល ឬមុនពេលមហាសន្និបាត។

កាលបរិច្ឆេទកំណត់ទុក

សម្រាប់គោលបំណងកំណត់ចំនួនភាគហ៊ុនិកដែលមានសិទ្ធិទទួលបានសេចក្តីជូនដំណឹង ឬមានសិទ្ធិបោះឆ្នោតនៅក្នុងកិច្ចប្រជុំណាមួយរបស់ភាគហ៊ុនិក ឬនៅក្នុងកិច្ចប្រជុំលើពេលណាមួយ ឬមានសិទ្ធិទទួលបានការទូទាត់ភាគលាភ ឬដើម្បីកំណត់ចំនួនភាគហ៊ុនិកសម្រាប់គោលបំណងផ្សេងណាមួយ ក្រុមប្រឹក្សាភិបាលអាចកំណត់នូវកាលបរិច្ឆេទកំណត់ទុកសម្រាប់ការកំណត់ចំនួនភាគហ៊ុនិក ដោយមិនត្រូវលើសពី ៥០ថ្ងៃ និងមហាសន្និបាតភាគហ៊ុនិកមិនត្រូវតិចជាង ២០ថ្ងៃ មុនចំណាត់ការធ្វើអ្វីមួយក្រោយការកំណត់កាលបរិច្ឆេទកំណត់ទុក។

ប្រសិនបើក្រុមប្រឹក្សាភិបាលមិនបានបង្កើតកាលបរិច្ឆេទកំណត់ទុក នោះកាលបរិច្ឆេទកំណត់ទុកត្រូវកំណត់នៅថ្ងៃធ្វើការចុងក្រោយ មុនពេលជូនដំណឹងអំពីកិច្ចប្រជុំ ឬប្រសិនបើគ្មានការជូនដំណឹងទេ ត្រូវយកថ្ងៃបើកកិច្ចប្រជុំ។

កាលបរិច្ឆេទកំណត់ទុក ដើម្បីកំណត់ចំនួនភាគហ៊ុនិកសម្រាប់បញ្ហាណាមួយក្រៅពីសិទ្ធិទទួលសេចក្តីជូនដំណឹងអំពីកិច្ចប្រជុំ ឬសិទ្ធិបោះឆ្នោតត្រូវយកថ្ងៃធ្វើការចុងក្រោយដែលក្រុមប្រឹក្សាភិបាលអនុម័តសេចក្តីសម្រេចដែលទាក់ទងនឹងបញ្ហានេះ។

នៅពេលការកំណត់ចំនួនភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតនៅក្នុងមហាសន្និបាត ត្រូវបានធ្វើឡើងដូចមានចែងក្នុងមាត្រានេះការកំណត់នេះត្រូវអនុវត្តចំពោះការលើកពេលកិច្ចប្រជុំផងដែរ លើកលែងតែក្រុមប្រឹក្សាភិបាលបានកំណត់កាលបរិច្ឆេទកំណត់ទុកថ្មី។

កូរ៉ុម

កូរ៉ុមនៃមហាសន្និបាតភាគហ៊ុនិក ត្រូវតែជាភាគហ៊ុនិកចូលរួមមហាសន្និបាតដោយផ្ទាល់ ឬតាមរយៈអាណាព្យាបាល ដែលកាន់កាប់ភាគហ៊ុនយ៉ាងតិច ៥១% (ហាសិបមួយភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត។ ភាគហ៊ុនដែលតំណាងតាមរយៈអាណាព្យាបាលនឹងត្រូវរាប់បញ្ចូលដើម្បីកំណត់កូរ៉ុមនៃមហាសន្និបាត។ ប្រសិនបើកូរ៉ុមមិនគ្រប់ចំនួនដើម្បីធ្វើមហាសន្និបាត ត្រូវផ្ញើជូនគ្រប់ភាគហ៊ុនិកទាំងអស់។ នៅពេលចាប់បន្តមហាសន្និបាតដែលបានផ្អាកនោះ ភាគហ៊ុនិកទាំអស់ដែលមានវត្តមានក្នុងមហាសន្និបាតដែលផ្អាកនោះ ជាកូរ៉ុមដែលអាចធ្វើមហាសន្និបាតបាន។

អាណាព្យាបាល

ភាគហ៊ុនិក អាចផ្តល់អាណាព្យាបាលជាលាយលក្ខណ៍អក្សរទៅអ្នកតំណាងណាម្នាក់ឱ្យចូលរួម និងបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក។ អាណាព្យាបាលនោះមានសុពលភាពសម្រាប់តែមហាសន្និបាតភាគហ៊ុនិកមួយលើកប៉ុណ្ណោះ (ចំពោះមហាសន្និបាតភាគហ៊ុនិកដែលបានផ្អាកនោះ ក៏ចាត់ទុកថាជាផ្នែកដូចគ្នាមួយនៃមហាសន្និបាតភាគហ៊ុនិកផងដែរ)។ អាណាព្យាបាលអាចដកហូតមកវិញបានគ្រប់ពេល ហើយត្រូវបានដកដោយស្វ័យប្រវត្តិ ប្រសិនបើភាគហ៊ុនិកដែលបានផ្តល់សិទ្ធិប្រទាននោះបានចូលរួមមហាសន្និបាតភាគហ៊ុនិកដោយផ្ទាល់។ ករណីអាណាព្យាបាលចូលរួមបោះឆ្នោតនៅក្នុងមហាសន្និបាតភាគហ៊ុនិក លិខិតតែងតាំងអាណាព្យាបាលរូបនោះត្រូវដាក់ជូនប្រធានក្រុមប្រឹក្សាភិបាលនៅក្នុងអំឡុង ឬមុនពេលចាប់ផ្តើមកិច្ចប្រជុំ។

លិខិតអាណាព្យាបាលត្រូវចុះកាលបរិច្ឆេទ មានហត្ថលេខារបស់ភាគហ៊ុនិក ព្រមទាំងត្រូវបញ្ជាក់៖

១. ចំនួនភាគហ៊ុនដែលកាន់កាប់ដោយភាគហ៊ុនិកតាមរយៈអាណាព្យាបាល

២. ឈ្មោះ និងអាសយដ្ឋានពេញលេញរបស់អាណាព្យាបាលនោះ

៣. កិច្ចប្រជុំដែលអាណាព្យាបាលនោះត្រូវបានតែងតាំងឱ្យចូលរួម។

ការរំលាយដោយស្ម័គ្រចិត្ត និងការជម្រះបញ្ជី

ធនាគារអាចបញ្ឈប់សកម្មភាពអាជីវកម្ម និងជម្រះបិទតាមការសម្រេចពិសេសរបស់ភាគហ៊ុនិកក្រោមលក្ខខណ្ឌណាមួយដូចខាងក្រោម៖

១. ភាពក្សីយធនរបស់ធនាគារ

២. ការសម្រេចរបស់ភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនយ៉ាងតិចចំនួន ៧៥% (ចិតសិបប្រាំភាគរយ) នៃភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោតសរុបទាំងអស់។

ធនាគារក៏អាចត្រូវបានរំលាយដោយការសម្រេចរបស់តុលាការ។

ក្នុងករណីជម្រះបញ្ជី ក្រុមប្រឹក្សាភិបាលត្រូវរៀបចំផែនការដើម្បីរំលាយធនាគារដែលត្រូវយកមកអនុវត្តបន្ទាប់ពីទទួលបានការអនុម័តពីភាគហ៊ុនិក។ ការរំលាយ និងការជម្រះបញ្ជីធនាគារត្រូវអនុវត្តស្របតាមនីតិវិធីដែលមានកំណត់ក្នុងច្បាប់ និងបទប្បញ្ញតិពាក់ព័ន្ធជាធរមាន។

ការទូទាត់ភាគលាភក្រោមគោលនយោបាយភាគលាភ

ធនាគារនឹងទូទាត់ភាគលាភទៅឱ្យភាគហ៊ុនិកទាំងអស់របស់ខ្លួន អនុលោមតាមគោលនយោបាយដែលពាក់ព័ន្ធទៅនឹងការប្រកាស និងការទូទាត់ភាគលាភ និងអនុម័តពីភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនដោយសំឡេងឆ្នោតគាំទ្រយ៉ាងតិច ៥១% នៃភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតដែលបានចូលរួមការបោះឆ្នោត។

បុព្វសិទ្ធិ (សិទ្ធិទិញមុនគេ)

ក្នុងករណីធនាគារអេស៊ីលីដា ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែម ភាគហ៊ុនិកទាំងអស់មានសិទ្ធិទិញមុនគេនូវមូលបត្រកម្មសិទ្ធិដែលបោះផ្សាយបន្ថែមនេះទៅតាមសមាមាត្រនៃចំនួន និងប្រភេទនៃមូលបត្រកម្មសិទ្ធិដែលខ្លួនកាន់កាប់តាមតម្លៃ និងលក្ខខណ្ឌដូចគ្នាក្នុងករណីបោះផ្សាយលក់ទៅតតិយជន។ ដូចនេះធនាគារអេស៊ីលីដា ត្រូវធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិបន្ថែមនេះក្នុងលក្ខខណ្ឌដូចគ្នាសម្រាប់អ្នកកាន់កាប់មូលបត្រកម្មសិទ្ធិទាំងអស់ដែលមានសិទ្ធិទិញមុននេះ និងត្រូវជាភាគហ៊ុនដែលមានឈ្មោះក្នុងបញ្ជីឈ្មោះភាគហ៊ុនិករបស់អេស៊ីលីដានៅកាលបរិច្ឆេទកំណត់ទុក។

កាលបរិច្ឆេទកំណត់ទុក គឺត្រូវកំណត់នៅត្រឹមថ្ងៃបិទការជួញដូរដែលអេស៊ីលីដាជ្រើសរើសសម្រាប់បិទបញ្ជីភាគហ៊ុនិក ដើម្បីកំណត់ពីភាគហ៊ុនិកណាមានសិទ្ធិទទួលបានសិទ្ធិទិញមុននេះ។ ការបរិច្ឆេទ អិចរាយ៍ (ex-right) នោះភាគហ៊ុនិកមុនជាអ្នកមានសិទ្ធិ។

បន្ទាប់ពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ ធនាគារអេស៊ីលីដា តាមរយៈសេចក្តីសម្រេចក្រុមប្រឹក្សាភិបាល និងបន្ទាប់ពីទទួលបានការអនុម័តពីភាគហ៊ុនិកអាចបោះផ្សាយមូលបត្រកម្ម

សិទ្ធិបន្ថែមលក់ទៅឱ្យតតិយជនក្រៅពីភាគហ៊ុនិកដែលកំពុងកាន់កាប់ភាគហ៊ុនស្រាប់ដោយមិនគិតពីសិទ្ធិទិញមុនគេក្នុងករណីដូចខាងក្រោម៖

- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ
- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជូនទៅនិយោជិតរបស់ធនាគារអេស៊ីលីដា
- ការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិដើម្បីសម្រេចគោលបំណងអាជីវកម្មពិសេស ដែលរួមមានការដាក់ឱ្យប្រើប្រាស់នូវបច្ចេកវិទ្យាថ្មី ឬការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពហិរញ្ញវត្ថុ។ល។
- ការបោះផ្សាយក្នុងទម្រង់ជាប័ណ្ណទទួលតម្កល់មូលបត្រកម្មសិទ្ធិ (depositary receipts) ស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សិទ្ធិស្នើសុំធ្វើការវាយតម្លៃមូលបត្រកម្មសិទ្ធិ

យោងតាមច្បាប់សហគ្រាសពាណិជ្ជកម្ម ក្នុងករណីមានការរំលាយក្រុមហ៊ុនបញ្ចូលគ្នាជាមួយក្រុមហ៊ុនមួយផ្សេងទៀត ភាគហ៊ុនិកនៃក្រុមហ៊ុនដើមមានសិទ្ធិទាមទារឱ្យមានការវាយតម្លៃលើ និងទិញមូលបត្រកម្មសិទ្ធិរបស់ខ្លួន។ ដើម្បីអនុវត្តសិទ្ធិនេះ ភាគហ៊ុនិកនោះត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- កាន់កាប់មូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនដើមមុនពេលអនុញ្ញាតឱ្យមានការរំលាយក្រុមហ៊ុនបញ្ចូលគ្នាតាមរយៈមហាសន្និបាតភាគហ៊ុនិក។
- មិនបានបោះឆ្នោតគាំទ្រការរំលាយក្រុមហ៊ុនបញ្ចូលគ្នា។
- ធ្វើការទាមទារជាលាយលក្ខណ៍អក្សរទៅក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិក:
- ស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម។
- ប្រគល់ប័ណ្ណភាគហ៊ុនរបស់ខ្លួនទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តស្របពេលដែលកំពុងស្នើសុំឱ្យមានការវាយតម្លៃ។

ថ្លៃទិញមូលបត្រកម្មសិទ្ធិនេះ ត្រូវកំណត់តាមរយៈការចរចារគ្នារវាងភាគហ៊ុនដើម និងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្នុងរយៈពេលមិនលើសពី ៩០ថ្ងៃ។ ករណីគ្មានការឯកភាពគ្នាលើតម្លៃសមរម្យទេនោះ តុលាការនឹងសម្រេចលើតម្លៃសមរម្យនោះ ហើយភាគហ៊ុនិកនៃក្រុមហ៊ុនដើមត្រូវទទួលតាមការកំណត់របស់តុលាការ។

សិទ្ធិទទួលបានព័ត៌មាន

សាធារណៈជនអាចចូលទៅកាន់គេហទំព័ររបស់ធនាគារអេស៊ីលីដា និង ផ.ម.ក ឬស្នើសុំទៅធនាគារ

ដើម្បីពិនិត្យមើលឯកសារផ្តល់ព័ត៌មានដែលបានចុះបញ្ជី ព័ត៌មានហិរញ្ញវត្ថុ និងព័ត៌មានពាក់ព័ន្ធនានាផ្សេងទៀត។ បន្ថែមពីនេះ បន្ទាប់ពីទទួលបានសំណើ និងការបង់ថ្លៃសមរម្យ ធនាគារត្រូវផ្តល់ជូនភាគហ៊ុនិករបស់ខ្លួននូវ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលធ្វើសវនកម្មរួច លទ្ធផលប្រតិបត្តិការ របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ព័ត៌មានអំពីអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតអំពីក្រុមហ៊ុនក្នុងទម្រង់បោះពុម្ព។

៣.៥. គោលនយោបាយភាគលាភ

ធនាគារអេស៊ីលីដាកំណត់ការបែងចែកភាគលាភឱ្យមានភាពត្រឹមត្រូវ និងមានប្រសិទ្ធិភាពហ៊ុនិកដោយ ដាក់ចេញនូវគោលនយោបាយបែងចែកភាគលាភ ដើម្បីបែងចែងភាគលាភដល់ភាគហ៊ុនិក ហើយធ្វើឱ្យមាន កំណើនដើមទុនផងដែរ។ ធនាគារចាត់ថ្នាក់ភាគលាភជាបីប្រភេទដូចខាងក្រោម៖

- ភាគលាភជាសាច់ប្រាក់
- ភាគលាភជាមូលបត្រកម្មសិទ្ធិ
- ក្នុងទម្រង់ផ្សេងទៀតតាមការកំណត់របស់ក្រុមប្រឹក្សាភិបាល និងភាគហ៊ុនិកដោយស្របទៅតាមច្បាប់ និងបទប្បញ្ញតិជាធរមាន។

អនុបាតភាគលាភ

ធនាគារកំណត់អនុបាតភាគលាភរហូតដល់ ៥0% នៃប្រាក់ចំណេញក្រោយបង់ពន្ធនៃឆ្នាំសារពើពន្ធ មុន។

លក្ខខណ្ឌនៃការបែងចែងភាគលាភ

ភាគលាភនឹងបែងចែកជូនភាគហ៊ុនិកយ៉ាងតិចមួយដងក្នុងមួយឆ្នាំ។ ភាគលាភនឹងបែងចែកនៅពេលមានចំណេញពីប្រតិបត្តិការរបស់ធនាគារ និងត្រូវបានទទួលស្គាល់ជាក់ស្តែងដោយសវនករឯករាជ្យ។ ភាគលាភនឹងត្រូវធ្វើការបែងចែកនឹងស្របតាមផែនការអាជីវកម្ម។ ករណីមានតម្រូវការចាំបាច់ដើម្បីរក្សាប្រាក់ចំណេញសម្រាប់គោលបំណងវិនិយោគ ឬគោលបំណងណាមួយ តាមរយៈការពិភាក្សាយ៉ាងហ្មត់ចត់ជាមួយក្រុមប្រឹក្សាភិបាល ធនាគារអេស៊ីលីដា នឹងស្នើសុំការអនុញ្ញាតពី គ.ម.ក និងផ្សព្វផ្សាយជាសាធារណៈ។

ការប្រកាសភាគលាភ

ភាគលាភនឹងត្រូវប្រកាសដោយសេចក្តីសម្រេចក្រុមប្រឹក្សាភិបាល ដែលមានសំឡេងឆ្នោតយ៉ាងតិច ៧៥% (ចិតសិបប្រាំភាគរយ) និងអនុម័តដោយភាគហ៊ុនិកដែលមានសិទ្ធិបោះឆ្នោតយ៉ាងតិច ៥១%។

ការប្រកាសភាគលាភត្រូវពិចារណាពីកត្តា និងព័ត៌មានមួយចំនួនដូចខាងក្រោម៖

- គ្មានកត្តាជាសារវន្តណាមួយដែលប៉ះពាល់ដល់ប្រាក់ចំណេញក្រោយបង់ពន្ធ

- តម្រូវការសាច់ប្រាក់ចំណេញពីប្រតិបត្តិការពេលបច្ចុប្បន្ន និងអនាគត
- តម្រូវការវិនិយោគសម្រាប់ផែនការអនាគត
- ស្ថានភាពហិរញ្ញវត្ថុ និងកិច្ចព្រមព្រៀងបំណុល
- ព័ត៌មានដែលតម្រូវដោយអាជ្ញាធរពាក់ព័ន្ធ និងកត្តាសេដ្ឋកិច្ចពាក់ព័ន្ធនានាដែលអាចប៉ះពាល់ដល់សម្ព័ន្ធធនាគារអេស៊ីលីដា។

ការទូទាត់ភាគលាភ

ធនាគារត្រូវកំណត់ពីកាលបរិច្ឆេទចាប់ផ្តើម និងកាលបរិច្ឆេទបិទការទូទាត់ភាគលាភ។ កាលបរិច្ឆេទចាប់ផ្តើមនៃការទូទាត់ភាគលាភត្រូវចាប់ផ្តើមមិនលើសពី ៧ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទកំណត់ទុក។ ធនាគារត្រូវធ្វើការទូទាត់ភាគលាភជូនភាគហ៊ុនិកទាំងអស់ ដែលមានក្នុងបញ្ជីឈ្មោះភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភនៅក្នុងរយៈពេលដូចបានកំណត់ខាងលើ។

ភាគលាភត្រូវធ្វើការទូទាត់ដូចខាងក្រោម៖

- ភាគលាភជាសាច់ប្រាក់ត្រូវធ្វើការទូទាត់បន្ទាប់ពីធនាគារទទួលបានការបញ្ជាក់ពី ព័ត៌មានលេខគណនីរបស់ភាគហ៊ុនិកទាំងអស់។
- ភាគលាភជាមូលបត្រកម្មសិទ្ធិត្រូវធ្វើការទូទាត់ទៅតាមការអនុញ្ញាតពីធនាគារជាតិកម្ពុជា បន្ទាប់ពីមហាសន្និបាតភាគហ៊ុនិក។
- ភាគហ៊ុនិកមានសិទ្ធិធ្វើការតវ៉ាករណីមិនពេញចិត្តលើការបែងចែកភាគលាភក្នុងរយៈពេល ៧ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីកាលបរិច្ឆេទបិទការទូទាត់ភាគលាភ។

ធនាគារត្រូវផ្តល់របាយការណ៍ស្តីពីការទូទាត់ភាគលាភជូន គ.ម.ក ក្នុងរយៈពេល ៣ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីការកំណត់រយៈពេលនៃការតវ៉ា[33]។

៣.៦. នីតិវិធីការធ្វើប៊ុកមៀលឌីង និងការធ្វើបរិវិសកម្ម

៣.៦.១. ដំណាក់កាលប៊ុកមៀលឌីង

៣.៦.១. ១. ព័ត៌មានលម្អិតអំពីប៊ុកមៀលឌីង

ខាងក្រោមនេះគឺជាព័ត៌មានលម្អិតអំពីប៊ុកបៀលឌីង៖

[33] ធនាគារអេស៊ីលីដា, ឯកសារផ្តល់ព័ត៌មាន https://www.acledabank.com.kh/kh/assets/pdf_zip/disclosure-documents-khm.pdf (ចូលទស្សនាទី ១០ ខែកក្កដា ឆ្នាំ២០២២)

រយៈពេលនៃការធ្វើប៊ុកបៀលឌីង	• ០៣/មីនា/២០២០ ទៅ ១៨/មីនា/២០២០ • ០៨:០០ព្រឹក ដល់ ០៥:០០ល្ងាច ពីថ្ងៃចន្ទ ដល់សៅរ៍
ចំនួនមូលបត្រកម្មសិទ្ធិដែលលៃបម្រុងទុកសម្រាប់ធ្វើប៊ុកបៀលឌីង	មូលបត្រកម្មសិទ្ធិថ្មីមានចំនួន ៤.៣៧៥.៦៩៦ មូលបត្រកម្មសិទ្ធិ
ចំនួនមូលបត្រកម្មសិទ្ធិអប្បបរមាសម្រាប់ប៊ុកបៀលឌីង	យ៉ាងតិច ១០០ ឯកតាមូលបត្រកម្មសិទ្ធិ (កើនម្តង ១០ឯកតាមូលបត្រកម្មសិទ្ធិ)
ចន្លោះថ្លៃ	១៥,០០០រៀល ទៅ ១៧,៤០០រៀល
គម្លាតតម្លៃ	១០០រៀល

តារាងទី១៨៖ ព័ត៌មានលម្អិតអំពីប៊ុកបៀលឌីង

៣.៦.១.២. ការចូលរួមធ្វើប៊ុកបៀលឌីង

ក. វិនិយោគិនត្រូវមានអត្តសញ្ញាណវិនិយោគ និងគណនីជួញដូរដើម្បីចូលរួមក្នុងការធ្វើប៊ុកបៀលឌីង (ការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិ)។

ខ. ការដាក់ពាក្យស្នើសុំប៊ុកបៀលឌីង

- វិនិយោគិនត្រូវបំពេញពាក្យស្នើសុំចូលរួមប៊ុកបៀលឌីងជាមួយភ្នាក់ងារលក់ដែលមានទីតាំងដូចបានបញ្ជាក់ក្នុងឧបសម្ព័ន្ធ៨ នៃឯកសារផ្តល់ព័ត៌មាន។
- វិនិយោគិនត្រូវជ្រើសរើសថ្លៃមួយរវាងចន្លោះថ្លៃដែលបានកំណត់។
- វិនិយោគិនត្រូវបំពេញចំនួនមូលបត្រកម្មសិទ្ធិដែលមានបំណងធ្វើបរិវិសកម្ម។

គ. ការដាក់ប្រាក់តម្កល់សម្រាប់ធ្វើប៊ុកបៀលឌីង

- វិនិយោគិនត្រូវតម្កល់ប្រាក់ស្មើនឹង១០ (ដប់) ភាគរយ នៃតម្លៃសរុប (ចំនួនមូលបត្រកម្មសិទ្ធិxថ្លៃស្នើសុំ) ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង (ប្រាក់តម្កល់ ១០%) ក្នុងគណនីប៊ុកបៀលឌីង ដូចខាងក្រោម៖

ឈ្មោះគណនី	ធនាគារអេស៊ីលីដា ភីអិលស៊ី-គណនីប៊ុកបៀលឌីង
លេខគណនី (រៀល)	០០០១០៣៥៧១៧៦៩១៥
លេខកូដ SWIFT	ACLBKHPP

តារាងទី១៩៖ គណនីប៊ុកបៀលឌីង

- វិនិយោគិនត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីការដាក់តម្កល់ប្រាក់ ១០% (ឧទាហរណ៍ វិក័យបត្រដាក់/ផ្ទេរប្រាក់ លេខសម្គាល់ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារជាដើម) ក្នុងពាក្យស្នើសុំប៊ុកបៀកឌីងហើយដាក់ជូនភ្នាក់ងារលក់។
- គោលបំណងនៃការដាក់/ផ្ទេរប្រាក់គឺ សម្រាប់ប៊ុកបៀលឌីងរបស់ធនាគារអេស៊ីលីដា។ ប្រាក់ដែលផ្ទេរពីបរទេស ត្រូវមកដាក់ធនាគារអេស៊ីលីដា យ៉ាងយូរក្នុងថ្ងៃចុងក្រោយនៃរយៈពេលនៃការធ្វើប៊ុកបៀលឌីង មុនម៉ោង ៥:00 ល្ងាច (ម៉ោងនៅកម្ពុជា UTC + ៧:00)។
- ប្រាក់តម្កល់ក្នុងការធ្វើប៊ុកបៀលឌីងនឹងមិនមានការប្រាក់។

ឃ. វិនិយោគិនត្រូវទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិក្នុងការបដិសេធពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ប្រសិនបើពាក្យស្នើសុំមិនត្រូវបានបំពេញក្នុងលក្ខខណ្ឌនៃការធ្វើប៊ុកបៀលឌីង។

៣.៦.១.៣. ទិធីសាស្ត្រក្នុងការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិ

ថ្លៃមូលបត្រកម្មសិទ្ធិចុងក្រោយ នឹងត្រូវបានកំណត់ដោយប្រើប្រាស់បច្ចេកទេសថ្លឹងរកមធ្យោបាយលើមូលដ្ឋានថ្លៃ និងចំនួនមូលបត្រកម្មសិទ្ធិដែលវិនិយោគិនបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង និងអាចកែសម្រួលទៅតាមតម្រូវការទីផ្សារដោយមានការសម្រេចចិត្តពី គ.ម.ក។

៣.៦.១.៤. ការលៃបម្រុងទុកនៃមូលបត្រកម្មសិទ្ធិ

ក. បន្ទាប់ពីថ្លៃចុងក្រោយត្រូវបានកំណត់ វិនិយោគិននឹងត្រូវបែងចែកជាពីរក្រុម។ វិនិយោគិនដែលដាក់ថ្លៃស្មើ ឬខ្ពស់ជាងថ្លៃចុងក្រោយ គឺជាវិនិយោគិនដែលទទួលបានជោគជ័យ ហើយវិនិយោគិនដែលកាន់ថ្លៃទាបជាងថ្លៃចុងក្រោយ គឺជាវិនិយោគិនដែលមិនទទួលជោគជ័យ។

ខ. មូលបត្រកម្មសិទ្ធិដែលលៃបម្រុងទុកក្នុងដំណាក់កាលប៊ុកបៀលឌីងចំនួន ៤.៣៧៥.៦៩៦ មូលបត្រកម្មសិទ្ធិនឹងត្រូវបានលៃបម្រុងទុកសម្រាប់វិនិយោគិនដែលទទួលបានជោគជ័យ។

គ. ស្របតាមប្រកាស និងបទប្បញ្ញត្តិរបស់ គ.ម.ក ដើម្បីផ្តល់អាទិភាពដល់វិនិយោគសញ្ជាតិខ្មែរ៖

- មូលបត្រកម្មសិទ្ធិស្មើនឹង ២០% នៃចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ដំណាក់កាលប៊ុកបៀលឌីង នឹងត្រូវលៃបម្រុងទុកឱ្យវិនិយោគិនដែលទទួលបានជោគជ័យដែលលមានសញ្ជាតិខ្មែរតាមវិធានសមាមាត្រ (Pro Rata) ជាមុនសិន។

- បន្ទាប់មក មូលបត្រកម្មសិទ្ធិស្មើនឹង ៨០% ផ្សេងទៀត នឹងត្រូវលៃបម្រុងទុកឱ្យវិនិយោគិនដែលទទួលបានជោគជ័យដែលមានសញ្ជាតិខ្មែរ និងវិនិយោគិនដែលទទួលបានជោគជ័យដែលមិនមែនសញ្ជាតិខ្មែរទាំងអស់ទៅតាមវិធានសមាមាត្រ (Pro Rata)។

ឃ. ក្នុងករណីដែលការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យមានចំនួនលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ដំណាក់កាលប៊ុកបៀលឌីង ការលៃបម្រុងទុកមូលបត្រកម្មសិទ្ធិជូនវិនិយោគិនដែលទទួលបានជោគជ័យ នឹងធ្វើតាមវិធានសមាមាត្រ (Pro Rata)។

ង. ក្នុងករណីដែលការធ្វើបរិវិសកម្មដោយវិនិយោគិនដែលទទួលបានជោគជ័យមានចំនួនតិចជាងចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកសម្រាប់ដំណាក់កាលប៊ុកបៀលឌីង មូលបត្រកម្មសិទ្ធិដែលនៅសល់ក្នុងដំណាក់កាលប៊ុកបៀលឌីង នឹងត្រូវផ្ទេរទៅដំណាក់កាលបរិវិសកម្ម។

ច. វិនិយោគិនដែលទទួលបានជោគជ័យត្រូវចូលរួមក្នុងដំណាក់កាលបរិវិសកម្ម និងត្រូវធ្វើបរិវិសកម្មយ៉ាងតិចស្មើនឹងចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកដល់ខ្លួន។ ប្រសិនបើវិនិយោគិនដែលទទួលបានជោគជ័យមិនបានចូលរួមក្នុងដំណាក់កាលបរិវិសកម្ម វិនិយោគិនដែលទទួលបានជោគជ័យ នឹងត្រូវបានសន្មតថាបានធ្វើបរិវិសកម្មដោយស្ម័យប្រវត្តិលើចំនួនមូលបត្រដែលទាបជាងគេ។

៣.៦.១.៥. ការផ្ទេរប្រាក់តម្កល់

បន្ទាប់ពីទទួលបានការអនុម័តពី គ.ម.ក. លើលទ្ធផលនៃការធ្វើប៊ុកបៀលឌីង ធនាគារអេស៊ីលីដា នឹងជូនដំណឹងដល់វិនិយោគិន និងផ្ទេរប្រាក់តម្កល់ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីងវិញ ឬរក្សាទុកក្នុងករណីដែលមិនទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីងមានបំណងចូលរួមបន្តក្នុងដំណាក់កាលបរិវិសកម្ម។

៣.៦.២. នីតិវិធីនៃការធ្វើបរិវិសកម្ម

៣.៦.២.១. ព័ត៌មានលម្អិតអំពីការធ្វើបរិវិសកម្ម

រយៈពេលនៃការធ្វើបរិវិសកម្ម	• ថ្ងៃ២៤ ខែមីនា ឆ្នាំ២០២០ ទៅថ្ងៃ២៤ ខែមេសា ឆ្នាំ២០២០ • ០៨:០០ នាទីព្រឹក ដល់ ០៥:០០ ល្ងាច ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ
ចំនួនមូលបត្រកម្មសិទ្ធិដែលលៃបម្រុងទុកសម្រាប់បរិវិសកម្ម	• មូលបត្រកម្មសិទ្ធិថ្មីចំនួន ៤.៣៧៥.៦៩៥ មូលបត្រកម្មសិទ្ធិ • រហូតដល់ ១៣.១២៧.០៨៦ មូលបត្រកម្មសិទ្ធិមានស្រាប់ (អាស្រ័យលើការសម្រេចចិត្តរបស់ភាគហ៊ុនិកផ្អែកតាមលទ្ធផល

	នៃការធ្វើប៊ុកបៀលឌីង និងបរិវិសកម្ម)
ចំនួនមូលបត្រកម្មសិទ្ធិអប្បបរមាសម្រាប់ធ្វើបរិវិសកម្ម	• យ៉ាងតិច ១ ឯកតាមូលបត្រកម្មសិទ្ធិ (កើនម្តង ១ ឯកតាមូលបត្រកម្មសិទ្ធិ)
ថ្លៃលក់	• ១៦.២០០ រៀល

តារាងទី២០៖ ព័ត៌មានលម្អិតអំពីការធ្វើបរិវិសកម្ម

៣.៦.២.២. ការចូលរួមធ្វើបរិវិសកម្ម

ក. វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិន និងគណនីជួញដូរ ដើម្បីចូលរួមក្នុងដំណាក់កាលបរិវិសកម្ម។

ខ. ការដាក់ពាក្យស្នើសុំចូលរួមបរិវិសកម្ម

- វិនិយោគិនត្រូវបំពេញពាក្យស្នើសុំចូលរួមបរិវិសកម្ម ជាមួយភ្នាក់ងារលក់ដែលមានទីតាំងដូចដែលមានបញ្ជាក់ក្នុងឧបសម្ព័ន្ធនៃឯកសារផ្តល់ព័ត៌មាន។
- វិនិយោគិនដែលទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីង៖ វិនិយោគិនដែលទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីង អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិលើសពីចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកដល់ខ្លួនដោយត្រូវធ្វើការតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមតម្លៃសរុបរបស់មូលបត្រកម្មសិទ្ធិដែលមានបំណងធ្វើបរិវិសកម្ម។
- វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីង៖ វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងដំណាក់កាលប៊ុកបៀលឌីង ដែលមានបំណងបន្តធ្វើបរិវិសកម្ម អាចធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិបាន ដោយត្រូវតម្កល់ប្រាក់បន្ថែម ដើម្បីបង្គ្រប់ទៅតាមតម្លៃសរុបនៃមូលបត្រកម្មសិទ្ធិដែលមានបំណងធ្វើបរិវិសកម្ម។
- វិនិយោគិនដែលមិនចូលរួមក្នុងដំណាក់កាលប៊ុកបៀលឌីង៖ វិនិយោគិនដែលមិនបានចូលរួមក្នុងដំណាក់កាលប៊ុកបៀលឌីងអាចចូលរួមធ្វើបរិវិសកម្មបានដោយត្រូវតម្កល់ប្រាក់ ១០០ (មួយរយ) ភាគរយ

នៃតម្លៃសរុបរបស់មូលបត្រកម្មសិទ្ធិដែលមានបំណងធ្វើបរិវិសកម្ម។

គ. ការវិនិយោគត្រូវទទួលស្គាល់ថា ក្រុមហ៊ុនបោះផ្សាយមានសិទ្ធិក្នុងការបដិសេធពាក្យស្នើសុំចូលរួមបរិវិសកម្ម ប្រសិនបើពាក្យស្នើសុំចូលរួមបរិវិសកម្មមិនបានបំពេញតាមលក្ខខណ្ឌនៃការធ្វើបរិវិសកម្ម។

៣.៦.២.៣. ការដាក់ប្រាក់តម្កល់សម្រាប់ធ្វើបរិវិសកម្ម

- វិនិយោគិនត្រូវដាក់ប្រាក់ ១០០% នៃតម្លៃសរុបនៃមូលបត្រកម្មសិទ្ធិ (ចំនួនមូលបត្រកម្មសិទ្ធិ x ថ្លៃលក់) ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមបរិវិសកម្មក្នុងគណនីបរិវិសកម្មដូចខាងក្រោម៖

ឈ្មោះគណនី	ធនាគារអេស៊ីលីដា ភីអិលស៊ី - គណនីបរិវិសកម្ម
លេខគណនី (រៀល)	០០០១០៣៥៧១៧៦៩៣៦
លេខកូដ SWIFT	ACLKHPP

តារាងទី២១៖ គណនីបរិវិសកម្ម

- វិនិយោគិនត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់ពីការដាក់តម្កល់ប្រាក់ (ឧទាហរណ៍ វិក្កយបត្រដាក់/ផ្ទេរប្រាក់ លេខសម្គាល់ការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារជាដើម) ក្នុងពាក្យស្នើសុំចូលរួមបរិវិសកម្ម ហើយដាក់ជូនភ្នាក់ងារលក់។
- គោលបំណងនៃការដាក់/ផ្ទេរប្រាក់ គឺ "សម្រាប់បរិវិសកម្មរបស់ធនាគារ អេស៊ីលីដា"។ ប្រាក់ដែលផ្ទេរពីបរទេសត្រូវមកដល់ធនាគារអេស៊ីលីដា នៅថ្ងៃចុងក្រោយនៃរយៈពេលនៃការធ្វើបរិវិសកម្ម មុនម៉ោង ០៥:០០ ល្ងាច (ម៉ោងនៅកម្ពុជា: UTC + ០៧:០០)។
- ការដាក់ប្រាក់តម្កល់សម្រាប់ចូលរួមធ្វើបរិវិសកម្មនឹងមិនមានការប្រាក់ទេ។

៣.៦.២.៤. ការបែងចែកមូលបត្រកម្មសិទ្ធិ

ក. ដំណាក់កាលទី១

មូលបត្រកម្មសិទ្ធិដែលត្រូវបានលៃបម្រុងទុកក្នុងដំណាក់កាលប៊ុកបៀលឌីង នឹងត្រូវបែងចែកទៅឱ្យវិនិយោគិនដែលទទួលបានជោគជ័យទៅតាមចំនួនដែលបានលៃបម្រុងទុកសម្រាប់វិនិយោគដែលទទួលបានជោគជ័យម្នាក់ៗ។

ខ. ដំណាក់កាលទី២

មូលបត្រកម្មសិទ្ធិសរុបដែលបានលៃបម្រុងទុកសម្រាប់ដំណាក់កាលបរិវិសកម្ម ព្រមទាំងមូលបត្រកម្មសិទ្ធិដែលនៅសល់បន្ទាប់ពីបានបែងចែកទៅឱ្យវិនិយោគិនដែលទទួលបានជោគជ័យ (ប្រសិនបើមាន) ("ចំនួនមូលបត្រកម្មសិទ្ធិសរុបសម្រាប់បរិវិសកម្ម") នឹងត្រូវយកមកបែងចែកទៅឱ្យវិនិយោគិនទាំងអស់ ជាពីរដំណាក់កាលជាបន្តបន្ទាប់ដូចខាងក្រោម៖

(១) ដំណាក់កាលផ្តល់អាទិភាពដល់វិនិយោគិនសញ្ជាតិខ្មែរ

(១.១)មូលបត្រកម្មសិទ្ធិស្មើនឹង ២0% នៃមូលបត្រកម្មសិទ្ធិសរុបសម្រាប់បរិវិសកម្មនឹងត្រូវបែងចែកទៅឱ្យវិនិយោគិនសញ្ជាតិខ្មែរ។

(១.២) វិធានសមាមាត្រកែសម្រួល (Adjusted Pro Rata Method)

- មូលបត្រកម្មសិទ្ធិស្មើនឹង ២0% នៃមូលបត្រកម្មសិទ្ធិសរុបសម្រាប់បរិវិសកម្ម នឹងត្រូវបែងចែកជាដំបូងទៅឱ្យវិនិយោគិនសញ្ជាតិខ្មែរ ត្រឹមកម្រិតអប្បបរមាដែលស្មើនឹង ១.000 ឯកតាមូលបត្រកម្មសិទ្ធិ ("កម្រិតអប្បបរមា") (minimum threshold)) ឬចំនួនដែលស្នើសុំធ្វើបរិវិសកម្ម ដោយយកមួយណាដែលតិចជាងគេ។
- ក្រោយពីបែងចែកមូលបត្រកម្មសិទ្ធិអប្បបរមា ("កម្រិតអប្បបរមា" (minimum threshold)) ដល់វិនិយោគិនសញ្ជាតិខ្មែររួចហើយ ប្រសិនបើចំនួនមូលបត្រកម្មសិទ្ធិដែលបានបែងចែកនោះមានចំនួនតិចជាង ២0% នៃមូលបត្រកម្មសិទ្ធិសរុបសម្រាប់បរិវិសកម្ម ចំណែកមូលបត្រកម្មសិទ្ធិដែលនៅសល់ក្រោយពេលបែងចែកតាមកម្រិតអប្បបរមា ត្រូវបែងចែកទៅឱ្យវិនិយោគិនសញ្ជាតិខ្មែរទាំងអស់ទៅតាមវិធានសមាមាត្រ (Pro Rata)
- ក្រោយពីបែងចែកមូលបត្រកម្មសិទ្ធិអប្បបរមា ("កម្រិតអប្បបរមា" (minimum threshold)) ដល់វិនិយោគិនសញ្ជាតិខ្មែររួចហើយ ប្រសិនបើចំនួនមូលបត្រកម្មសិទ្ធិដែលបានបែងចែកនោះ មានចំនួនច្រើនជាង ២0% នៃមូលបត្រកម្មសិទ្ធិសរុបសម្រាប់បរិវិសកម្ម ការបែងចែកមូលបត្រកម្មសិទ្ធិ ២0% នេះនឹងមិនត្រូវយកវិធានសមាមាត្រកែសម្រួលមកអនុវត្តទេ ដោយត្រូវយកវិធានសមាសមាត្រ (Pro Rata) មកអនុវត្តវិញ។

(២) ដំណាក់កាលបែងចែកចុងក្រោយ

(២.១) មូលបត្រកម្មសិទ្ធិស្មើនឹង ៨0% នៃមូលបត្រកម្មសិទ្ធិសរុបសម្រាប់បរិវិសកម្មនឹងត្រូវបែងចែកទៅឱ្យវិនិយោគិនសញ្ជាតិខ្មែរ និងវិនិយោគិនមិនមែនសញ្ជាតិខ្មែរ។

(២.២) វិធានសមាមាត្របែសម្រួល (Adjusted Pro Rata Method)

- មូលបត្រកម្មសិទ្ធិស្មើនឹង ៨0% នៃមូលបត្រកម្មសិទ្ធិសរុបសម្រាប់បរិវិសកម្ម នឹងត្រូវបែងចែកជាដំបូងទៅឱ្យវិនិយោគសញ្ជាតិខ្មែរ និងវិនិយោគមិនមែនសញ្ជាតិខ្មែរទាំងអស់ ត្រឹមកម្រិតអប្បបរមាដែលស្មើនឹង ១.000 ឯកតាមូលបត្រកម្មសិទ្ធិ ("កម្រិតអប្បបរមា" (minimum threshold)) ឬចំនួនដែលស្នើសុំធ្វើបរិវិសកម្ម ដោយយកមួយណាដែលតិចជាងគេ។
- វិនិយោគិនសញ្ជាតិខ្មែរដែលទទួលបានមូលបត្រកម្មសិទ្ធិតិចជាង កម្រិតអប្បបរមាក្នុងដំណាក់កាលទី១ ខាងលើ នឹងទទួលបានមូលបត្រកម្មសិទ្ធិបន្ថែម ដើម្បីបង្គ្រប់ត្រឹមកម្រិតអប្បបរមាជាមុនសិន។ ចំណែកឯចំនួនមូលបត្រកម្មសិទ្ធិដែលធ្វើបរិវិសកម្មលើសពីចំនួនកម្រិតអប្បបរមា (ប្រសិនបើមាន) ត្រូវបែងចែកទៅឱ្យវិនិយោគិនសញ្ជាតិខ្មែរនោះទៅតាមវិធានសមាសមាត្រ (Pro Rata) ជាមួយវិនិយោគិនទាំងអស់។

(២.៣) ករណីចំនួនមូលបត្រសរុបដែលបានបែងចែកតាមកម្រិតអប្បបរមាក្នុងដំណាក់កាលបែងចែកចុងក្រោយតិចជាងចំនួនមូលបត្រកម្មសិទ្ធិដែលបានស្នើសុំ ចំណែកមូលបត្រកម្មសិទ្ធិដែលនៅសេសសល់ក្រោយពេលបែងចែកតាមកម្រិតអប្បរមានឹងត្រូវបែងចែកឱ្យវិនិយោគិនទាំងអស់ទៅតាមវិធានសមាមាត្រ (Pro Rata)។

ក្រុមហ៊ុនបោះផ្សាយរក្សាសិទ្ធិក្នុងការកែប្រែ កម្រិតអប្បបរមានៃចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបែងចែក (minimum threshold) ដើម្បីធ្វើយ៉ាងណាឱ្យមានចំនួនមូលបត្រកម្មសិទ្ធិគ្រប់គ្រាន់សម្រាប់បែងចែក ដោយប្រើប្រាស់វិធានសមាមាត្រកែសម្រួល (adjusted pro-rata method) ដូចដែលបានរៀបរាប់ខាងលើ។ ក្នុងករណីដែលចំនួនវិនិយោគិនចូលរួមធ្វើបរិវិសកម្មមានចំនួនច្រើនលើសលុប ចំនួនមូលបត្រកម្មសិទ្ធិជាមធ្យមក្នុងវិនិយោគិនម្នាក់ៗ (ចំនួនមូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងទុកសម្រាប់ដំណាក់កាលបរិវិសកម្មចែកនឹងចំនួនវិនិយោគិនចូលរួមក្នុងបរិវិសកម្ម) អាចនឹងតិចជាង ១.000 មូលបត្រកម្មសិទ្ធិ។ ក្នុងករណីនេះដើម្បីជៀសវាងកង្វះខាតមូលបត្រកម្មសិទ្ធិដើម្បីបែងចែកតាមរយៈវិធានសមាមាត្រកែសម្រួល "កម្រិតអប្បបរមានៃចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវបែងចែក (minimum threshold)" ជាចំនួនមូលបត្រកម្មសិទ្ធិជាមធ្យមក្នុងវិនិយោគិនម្នាក់ និងត្រូវបង្គត់ត្រឹមចំនួនគត់ជិតបំផុត។

៣.៦.២.៥. ការផ្ទេរប្រាក់តម្កល់

បន្ទាប់ពីដំណើរការបរិវិសកម្មបានបញ្ចប់ ក្នុងករណីដែលអ្នកធ្វើបរិវិសកម្មមិនទទួលបានមូលបត្រកម្មសិទ្ធិ

ក្នុងការស្នើសុំ ក្រុមហ៊ុនបោះផ្សាយត្រូវធ្វើការផ្ទេរសាច់ប្រាក់ដែលនៅសេសសល់ពីការធ្វើបរិវិសកម្មជូនអ្នកធ្វើបរិវិសកម្មពាក់ព័ន្ធនោះ។

៣.៧. ដំណើរការ និងលទ្ធផលនៃការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្ម

ធនាគារអេស៊ីលីដា ភីអិលស៊ី ដោយមានការគាំទ្រដោយក្រុមហ៊ុនធានាទិញមូលបត្រ យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី បានជូនដំណឹងពីការធ្វើប៊ុកបៀលឌីង ដើម្បីកំណត់ថ្លៃភាគហ៊ុនរបស់ធនាគារដែលគ្រោងនឹងចុះបញ្ជីនៅក្នុងក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ការធ្វើប៊ុកបៀលឌីងនេះ ធ្វើឡើងចាប់ពីថ្ងៃ ០៣ ខែមីនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២០។ (ទម្រង់សុំធ្វើការចូលរួមធ្វើប៊ុកបៀលឌីងមាននៅក្នុងឧបសម្ព័ន្ធទី២)។

៣.៧.១. ការបង្ហាញព័ត៌មានលម្អិត (Roadshow)

ធនាគារអេស៊ីលីដា ភីអិលស៊ី បានរៀបចំកម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) ចំនួន ០២ លើក ដើម្បីធ្វើបទបង្ហាញដល់វិនិយោគិន អំពីទិដ្ឋភាពទូទៅនៃអាជីវកម្មហិរញ្ញវត្ថុរបស់ធនាគារ ពេលវេលារំពឹងទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការរៀបចំខ្លួនរបស់វិនិយោគិន ដើម្បីមានការយល់ដឹងច្រើនជាងមុនពីធនាគារ មុនធ្វើការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិនៅក្នុងដំណាក់កាលប៊ុកបៀលឌីង។ កម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) ត្រូវបានកំណត់ដូចខាងក្រោម៖

- កម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) លើកទី១
  - កាលបរិច្ឆេទ៖ ០៣ មីនា ២០២០ ចាប់ពីម៉ោង ៣:៣០រសៀល ដល់ម៉ោង ៦:០០ល្ងាច
  - ទីតាំង៖ ទីស្នាក់ការកណ្តាលរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី
- កម្មវិធីបង្ហាញព័ត៌មានលម្អិត (Roadshow) លើកទី២
  - កាលបរិច្ឆេទ៖ ១០ មីនា ២០២០ ចាប់ពីម៉ោង ២:០០រសៀល ដល់ម៉ោង ៤:៣០រសៀល
  - ទីតាំង៖ ទីស្នាក់ការកណ្តាលរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី

៣.៧.២. កាលបរិច្ឆេទប៊ុកបៀលឌីង និងទីតាំង

កាលបរិច្ឆេទ៖ កាលបរិច្ឆេទ៖ ០៣ មីនា ដល់ ១៤ មីនា ២០២០ (ចាប់ពីម៉ោង ៨:០០ព្រឹក ដល់ម៉ោង ៥:០០ល្ងាច ពីថ្ងៃចន្ទ ដល់ ថ្ងៃសៅរ៍)

ទីតាំង៖ ទីស្នាក់ការភ្នាក់ងារចែកចាយលក់

- អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី (ACS) និងបញ្ជានៅតាមសាខារបស់ធនាគារអេស៊ីលីដា ក្នុងរាជធានីភ្នំពេញ សាខាទីរួមខេត្តសៀមរាប ក្រុងព្រះសីហនុ សាខាទីរួមខត្តបាត់ដំបង សាខាទីរួមខេត្តកំពង់ចាម សាខាទីរួមខេត្តស្វាយរៀង និងសាខាទីរួមខេត្តបន្ទាយមានជ័យ។
- យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី
- អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី (SBI)
- អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យូរីធី ម.ក (RHBS)
- កម្ពុ ស៊ីឃ្យូរីធី ភីអិលស៊ី (CAMPUSEC)
- ភ្នំពេញ ស៊ីឃ្យូរីធី ភីអិលស៊ី (PPS)
- កាណា ស៊ីឃ្យូរីធី អិលធីឌី (CNS)[34]

៣.៧.៣. លទ្ធផលនៃការធ្វើប៊ុកបៀលឌីង

រាជធានីភ្នំពេញ ថ្ងៃសុក្រ ១២រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០២០ ធនាគារអេស៊ីលីដា ភីអិលស៊ី គាំទ្រពីក្រុមហ៊ុនធានាទិញមូលបត្រ យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី (ក្រុមហ៊ុនយាន់តា) មានកិត្តិយសូមជម្រាបជូនសាធារណៈជនមេត្តាជ្រាបថា បន្ទាប់ពីបញ្ចប់ដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកបៀលឌីង) របស់ធនាគារកាលពីថ្ងៃសៅរ៍ ទី ១៤ ខែមីនា ឆ្នាំ ២០២០ កន្លងទៅនេះ មានវិនិយោគិនចូលរួមចំនួន ២.១៨០ នាក់ ដែលក្នុងនោះមានវិនិយោគិនក្នុងស្រុកចំនួន ៩៥.៥៥% និងវិនិយោគិនបរទេសចំនួន ៤.៤៥%។

តម្រូវការចូលរួមដាក់សំណើទិញ និងកំណត់ថ្លៃ (ប៊ុកបៀលឌីង) មានចំនួនគួរឱ្យកត់សម្គាល់ ដោយតម្រូវការសរុបមានចំនួន ៣ដង លើសពីចំនួនភាគហ៊ុនដែលបានលៃបម្រុងទុកក្នុងដំណាក់កាលប៊ុកបៀលឌីង។

តម្លៃភាគហ៊ុនចុងក្រោយដែលបានកំណត់ដោយអនុលោមតាមនីតិវិធីស្តីពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មដែលបានអនុម័តដោយគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក) គឺ ១៦.២០០រៀល។

[34] https://www.acledabank.com.kh/kh/khm/listing-subscription (ចូលទស្សនាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២២)

៣.៧.៤. ដំណើរការ និងលទ្ធផលធ្វើបរិវិសកម្ម (Subscription)

ដំណើរការធ្វើបរិវិសកម្ម ជាដំណើការសុំចុះឈ្មោះទិញមូលបត្រនៅក្រុមហ៊ុនធ្វើសំណើលក់ជាសាធារណៈ។ វិនិយោគិនដែលទទួលបានជោគជ័យក្នុងការធ្វើប៊ុកបៀលឌីង អាចដាក់ពាក់ស្នើសុំធ្វើបរិវិសកម្មលើសពីចំនួនដែលបានធ្វើប៊ុកបៀលឌីង ឯវិនិយោគិនដែលមិនទទួលបានជោគជ័យ ឬមិនបានចូលរួមក្នុងដំណើរការប៊ុកបៀលឌីងនៅតែអាចដាក់ពាក្យស្នើសុំធ្វើបរិវិសកម្មបាន។

ធនាគារអេស៊ីលីដា ភីអិលស៊ី បានបញ្ចប់ដំណើរការបរិវិសកម្ម កាលពីថ្ងៃសុក្រ ទី២៤ ខែមេសា ឆ្នាំ ២០២០។ ធនាគារបានទទួលការអនុម័តពីគណៈកម្មការមូលបត្រកម្ពុជា លើលទ្ធផលនៃការធ្វើបរិវិសកម្ម នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០។ (ទម្រង់លិខិតសូមចូលរួមធ្វើបរិវិសកម្មមានឧបសម្ព័ន្ធ ៣)។

បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ ធនាគារអេស៊ីលីដា ភីអិលស៊ី មានប្រសាសន៍ថា "ទោះបីជាមានផលប៉ះពាល់យ៉ាងខ្លាំង ពីការរីករាយដាលនៃវីរុសកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏វិនិយោគិនប្រមាណ ២,៤៩៧នាក់ បានចូលរួមក្នុងដំណើរការបរិវិសកម្ម ដោយចំណាយពេលវេលាយ៉ាងមានតម្លៃ និងថវិកាដើម្បីវិនិយោគនៅក្នុងធនាគារអេស៊ីលីដា ភីអិលស៊ី។ ការចូលរួមយ៉ាងសកម្មនេះស្តែងចេញពីការជឿទុកចិត្តរបស់សាធារណៈជន ចំពោះលទ្ធផលប្រតិបត្តិការនិងស្ថានភាពដ៏រឹងមាំ ក៏ដូចជាការឈានមុខគេរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅក្នុងវិស័យធនាគារនៅកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រនេះ និងថ្លែងអំណរគុណដល់អតិថិជន និងវិនិយោគិនទាំងអស់ដែលបានវិនិយោគក្នុងការបោះ ផ្សាយលក់មូលបត្រសិទ្ធិរបស់ធនាគារ។

លោក Han Kyung Tae អគ្គនាយកក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី បានមានប្រសាសន៍ថា "ទោះបីជាស្ថិតនៅក្នុងអំឡុងពេលនៃការរីករាយដាលនៃវីរុសកូវីដ-១៩ យ៉ាងណាក៏ដោយ ក៏ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ទទួលបានលទ្ធផលល្អ។ ធនាគារអេស៊ីលីដា ភីអិលស៊ី និងគណៈគ្រប់គ្រងធនាគារ បានបង្ហាញនូវការប្តេជ្ញាចិត្តខ្ពស់ក្នុងការជំរុញការចុះបញ្ជីទៅតាមផែនការដែលបានគ្រោងទុក ហើយការប្តេជ្ញាចិត្តនេះហាក់ដូចជាការសម្រេចចិត្តដ៏ប្រយ័ត្នប្រយែងមួយ។ ក្នុងនាមជាក្រុមហ៊ុនធនាគារទិញមូលបត្រដែលដឹកនាំគម្រោងដ៏សំខាន់នេះ ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) នឹងបន្តធ្វើឱ្យអស់ពីសមត្ថភាព ដើម្បីជួយទាំងក្រុមហ៊ុនបោះផ្សាយ និងទាំងវិនិយោគិនយ៉ាងច្រើនដែលបានចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រដែលដឹកនាំគម្រោងដ៏សំខាន់នេះ ក្រុមហ៊ុន យាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) នឹងបន្តធ្វើឱ្យអស់ពីសមត្ថភាព ដើម្បីជួយទាំងក្រុមហ៊ុនបោះផ្សាយ និងទាំងវិនិយោគិន យ៉ាងច្រើនដែលបានចូលរួមក្នុងដំណើរការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈនេះ ដោយផ្តោតលើការបង្កើតសន្ទនីយ

ភាពដល់ភាគហ៊ុនរបស់ធនាគារនៅក្នុងទីផ្សារបន្ទាប់។ យើងខ្ញុំជឿជាក់ថាការជួយក្រុមហ៊ុនបោះផ្សាយក្នុងការធ្វើការបោះផ្សាយភាគហ៊ុនបន្តមកទៀត និងការរៀបចំវិធីសាស្ត្រជួញដូរតាមការចរាចរនាពេលអនាគត និងជួយបង្កើនសន្ទនីយភាព និងទាក់ទាញវិនិយោគិនបរទេសកាន់តែច្រើនមិនត្រឹមតែសម្រាប់ភាគហ៊ុនរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ប៉ុណ្ណោះទេ ថែមទាំងសម្រាប់ទីផ្សារមូលធននៅកម្ពុជាផងដែរ[35]។

៣.៨. ឥទ្ធិពលភាគហ៊ុនអេស៊ីលីដាក្នុងផ្សារមូលបត្រកម្ពុជា

៣.៨.១. ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅ ផ.ម.ក

ខាងក្រោមនេះគឺជាព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅ ផ.ម.ក

ឈ្មោះក្រុមហ៊ុន	ធនាគារ អេស៊ីលីដា ភីអិលស៊ី
ឆ្នាំបង្កើត	១៩៩៣
ចំណាត់ថ្នាក់វិស័យ	ហិរញ្ញវត្ថុ
ចំនួនភាគហ៊ុនចុះបញ្ជី	៤៣៣,១៦៣,០១៩
និមិត្តសញ្ញា	ធមក (ខ្មែរ) ABC (អង់គ្លេស)
គេហទំព័រ	www.acledabank.com.kh
ប្រភេទភាគហ៊ុន	ភាគហ៊ុនមានសិទ្ធិបោះឆ្នោត
លេខកូដស្តង់ដារ	KH1000100003
កាលបរិច្ឆេទចុះបញ្ជី	២៥ ឧសភា ២០២០
ចំនួនបុគ្គលិក	១២,០៨១ នាក់

តារាងទី២២៖ ព័ត៌មានទូទៅរបស់មូលបត្រកម្មសិទ្ធិអេស៊ីលីដានៅផ.ម.ក.

៣.៨.២. ការជួញដូរមូលបត្រកម្មសិទ្ធិ ABC នៅ ផ.ម.ក

ខាងក្រោមនេះគឺជាការជួញដូរមូលបត្រកម្មសិទ្ធិ ABC របស់ធនាគារអេស៊ីលីដា ក្នុងខែមិថុនា ឆ្នាំ២០២២[36]៖

[35] ធនាគារអេស៊ីលីដា,លទ្ធភាពដ៏គាប់ប្រសើរនៃដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកប៊ៀលឌីង) របស់ធនាគារអេស៊ីលីដា ភីអិលស៊ី https://www.acledabank.com.kh/kh/khm/md_ln20200317 (ចូលទស្សនាថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២២)

[36] http://csx.com.kh/data/allboard/listPosts.do?MNCD=60201(ចូលទស្សនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០២២)

សប្តាហ៍ទី១

តារាងទី២៣៖ ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី១

កាលបរិច្ឆេទ	**ថ្លៃបិទ (រៀល)**	**ទំហំជួញដូរហ៊ុន**	**តម្លៃជួញដូរ ABC (រៀល)**	**តម្លៃជួញដូរសរុបនៅ ផ.ម.ក**
០១ មិថុនា ឆ្នាំ ២០២២	១១.៣០០	៨១.៦៨៩	៩២០.៣០១.៤៨០	១.១៣០.៨៥៧.៣០០
០២ មិថុនា ឆ្នាំ ២០២២	១១.៣០០	៦៣.០៨១	៧១២.៣០៨.២៦០	៨៥១.៨១២.១៥០
០៣ មិថុនា ឆ្នាំ ២០២២	១១.៣០០	៨១.២២២	៩១៦.៣៦៩.៧០០	១.០១៩.៩៣៩.៧០០

*សន្នត ១ ដុល្លារ = ៤.០០០ រៀល

ការជួញដូរភាគហ៊ុនរបស់ធនាគារអេស៊ីលីដា នៅក្នុងទីផ្សារមូលបត្រកម្ពុជាក្នុងសប្តាហ៍ទី១ គឺពុំមានការកើនឡើងថ្លៃបិទទេ។ បើធៀបជាមួយតម្លៃនៃការធ្វើ IPO ដំបូងរបស់ ABC ស្មើនឹង ១៦.២០០ រៀល ធៀបនឹងថ្លៃក្នុងសប្តាហ៍ទី១ តម្លៃ ១១.៣០០ រៀល គឺមានការធ្លាក់ចុះរហូតដល់ ៤.៩០០ រៀល ពោលគឺមានការធ្លាក់ចុះប្រមាណជា ៣១%។ ប៉ុន្តែទំហំនៃការជួញដូរនៃភាគហ៊ុននេះមានកំណើនធំជាងភាគហ៊ុនដទៃ បើធៀបជាមួយតម្លៃជួញដូរសរុបនៅ ផ.ម.ក។

សប្តាហ៍ទី២

តារាងទី២៤៖ ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី២

កាលបរិច្ឆេទ	**ថ្លៃបិទ (រៀល)**	**ទំហំជួញដូរហ៊ុន**	**តម្លៃជួញដូរ ABC (រៀល)**	**តម្លៃជួញដូរសរុបនៅ ផ.ម.ក**
០៦ មិថុនា ឆ្នាំ ២០២២	បោះឆ្នោតឃុំសង្កាត់ឆ្នាំ ២០២២			
០៧ មិថុនា ឆ្នាំ ២០២២	១១.២៨០	៦១.១៤៩	៦៨៨.៨៦៥.៦៤០	៩៥២.៨០១.៥៤០
០៨ មិថុនា ឆ្នាំ ២០២២	១១.៣០០	៧៧.៩៤២	៨៧៨.៨១១.៧៨០	១.១១០.២៤៨.៧១០
០៩ មិថុនា ឆ្នាំ ២០២២	១១.៣៤០	៦៦.២៩៨	៧៥២.៣៤៤.៦៨០	១.០៣០.៣៨០.៤២០
១០ មិថុនា ឆ្នាំ ២០២២	១១.៣៤០	៦៧.០៥១	៧៥៩.១២២.៦២០	១.០៥៣.៥៥២.៩០០

*សន្នត ១ ដុល្លារ = ៤.០០០ រៀល

តាមរយៈតារាងសប្តាហ៍ទី២ នៃការធ្វើចរាចរជួញដូរភាគហ៊ុន ABC គឺថ្លៃមានការកើនឡើងបន្តិចបន្តួច ដោយធ្វើការធៀបជាមួយថ្លៃបិទនីមួយៗនៃសប្តាហ៍ទី១។ ចំណែកឯទំហំជួញដូរហ៊ុនវិញឃើញថានៅសប្តាហ៍ទី២ ទំហំជួញដូរហ៊ុនមធ្យមគឺ ១០.៨៩៨ ភាគហ៊ុន ធៀបជាមួយទំហំជួញដូរហ៊ុនមធ្យមសប្តាហ៍ទី១ ៧៥.៣៣០ ភាគហ៊ុន ពោលគឺសប្តាហ៍ទី២ មានការកើនឡើងប្រមាណជា ៦៤.៤៣២ ភាគហ៊ុន ព្រោះនៅសប្តាហ៍ទី១ មានរយៈពេលនៃការជួញដូរតែ ៣ថ្ងៃប៉ុណ្ណោះ។

សប្តាហ៍ទី៣

តារាងទី២៥៖ ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី៣

កាលបរិច្ឆេទ	ថ្លៃបិទ (រៀល)	ទំហំជួញដូរ ហ៊ុន	តម្លៃជួញដូរ ABC (រៀល)	តម្លៃជួញដូរសរុបនៅ ផ.ម.ក
១៣ មិថុនា ឆ្នាំ ២០២២	១១.៣០០	១២៩.២៤៧	១.៤៥៩.៦៨៩.៦៦០	១.៧៨១.៥៨៦.៤២០
១៤ មិថុនា ឆ្នាំ ២០២២	១១.២០០	១៦៧.២១២	១.៨៧២.៤១៣.០០០	២.៣៩៥.៧៩៨.០៦០
១៥ មិថុនា ឆ្នាំ ២០២២	១១.១០០	៣១២.៦០៤	៣.៤៥៨.៤១៥.៤៨០	៣.៧៩៨.២៦១.៤៥០
១៦ មិថុនា ឆ្នាំ ២០២២	១១.០២០	១២៥.៦៤៤	១.៣៨២.៧០៨.១៦០	១.៤៥៨.៧៩៥.៦៣០
១៧ មិថុនា ឆ្នាំ ២០២២	១១.០៦០	២១០.៤៩២	២.៣១៦.៦៦៣.០៦០	២.៤២១.២១៣.៥៦០

*សន្មត ១ ដុល្លារ = ៤.០០០ រៀល

តាមរយៈតារាងសប្តាហ៍ទី៣ នៃការធ្វើចរាចរជួញដូរភាគហ៊ុន ABC គឺថ្លៃមានការធ្លាក់ចុះបន្តិចបន្តួច ដោយធ្វើការធៀបជាមួយថ្លៃបិទនីមួយៗនៃសប្តាហ៍ទី២។ ចំណែកឯទំហំជួញដូរហ៊ុនវិញឃើញថានៅសប្តាហ៍ទី៣ ទំហំជួញដូរហ៊ុនមធ្យមគឺ ១៨៩.០៤០ ភាគហ៊ុន ធៀបជាមួយទំហំជួញដូរហ៊ុនមធ្យមសប្តាហ៍ទី២ ១០.៨៩៨ ភាគហ៊ុន ពោលគឺសប្តាហ៍ទី៣ មានការកើនឡើងប្រមាណជា ១៧៨.១៤១ ភាគហ៊ុន ពោលគឺទំហំជួញដូរហ៊ុននៅតែបន្តការកើនឡើង។

សប្តាហ៍ទី៤

តារាងទី២៦៖ ទិន្នន័យការជួញដូរមូលបត្រ ABC សប្តាហ៍ទី៤

កាលបរិច្ឆេទ	ថ្លៃបិទ (រៀល)	ទំហំជួញដូរ ហ៊ុន	តម្លៃជួញដូរ ABC (រៀល)	តម្លៃជួញដូរសរុបនៅ ផ.ម.ក
២០ មិថុនា ឆ្នាំ ២០២២	១០.៩០០	២១១.៣១៥	២.៣១១.៤៤៨.៥២០	២.៣៧៦.៩១០.១១០
២១ មិថុនា ឆ្នាំ ២០២២	១០.៧៤០	២៤៥.២០៦	២.៦៤៩.៤៥៩.៥០០	២.៨២១.១៤២.១៧០
២២ មិថុនា ឆ្នាំ ២០២២	១០.៨០០	៣៦០.៦៩៧	៣.៨៣៧.៩៧៣.៩៦០	៤.១៨៣.៤៦២.៧៦០
២៣ មិថុនា ឆ្នាំ ២០២២	១០.៨៨០	៦៣.៨០៦	៦៨៧.១៤៨.៦៤០	៧៦៧.៨៤៧.០៧០
២៤ មិថុនា ឆ្នាំ ២០២២	១០.៩២០	១២០.៤៣៧	១.៣១២.៧៧៥.៤៦០	១.៦៨៦.០០២.៤០០

*សន្មត ១ ដុល្លារ = ៤.០០០ រៀល

តាមរយៈតារាងសប្តាហ៍ទី៤ នៃការធ្វើចរាចរជួញដូរភាគហ៊ុន ABC គឺនៅតែបន្តការធ្លាក់ចុះបន្តិចបន្តួច ដោយធ្វើការធៀបជាមួយថ្លៃបិទនីមួយៗនៃសប្តាហ៍ទី៣។ ប៉ុន្តែទំហំជួញដូរហ៊ុនវិញឃើញថានៅ សប្តាហ៍ទី៤ ទំហំជួញដូរហ៊ុនមធ្យមគឺ ២០០.២៩២ភាគហ៊ុន ធៀបជាមួយទំហំជួញដូរហ៊ុនមធ្យមសប្តាហ៍ទី៣ ១៨៩.០៤០ភាគហ៊ុន ពោលគឺសប្តាហ៍ទី៤ នៅតែបន្តការកើនឡើងប្រមាណជា ១១.២៥២ ភាគហ៊ុន ពោលគឺទំហំជួញដូរហ៊ុននៅតែបន្តការកើនឡើងដដែល។

ជារួមយើងសង្កេតឃើញថា ថ្លៃបិទនៅក្នុងខែមិថុនា ឆ្នាំ ២០២២ នៅតែបន្តការធ្លាក់ចុះពីមួយសប្តាហ៍ទៅមួយសប្តាហ៍។ ប៉ុន្តែទំហំនៃការជួញដូរហ៊ុនកាន់តែមានការកើនឡើងជាបន្តបន្ទាប់។ នេះបញ្ជាក់ឱ្យឃើញថាការចរាចរជួញដូរមូលបត្រកម្មសិទ្ធិ ABC នៅក្នុងផ្សារមូលបត្រកម្ពុជានៅតែមានសន្ទុះកើនឡើងគួរឱ្យកត់សម្គាល់។

សេចក្តីសន្និដ្ឋាន
និងការផ្តល់អនុសាសន៍

សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១.សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវដែលទាក់ទងទៅនឹងប្រធានបទ ដំណើរការនៃការបោះផ្សាយមូលកម្មសិទ្ធិរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅផ្សារមូលបត្រកម្ពុជា យើងសង្កេតឃើញថាធនាគារអេស៊ីលីដា ភីអិលស៊ី គឺជាធនាគារដែលបានចុះបញ្ជីអស់រយៈពេលប្រហែលជិតពីរឆ្នាំមកហើយគិតតាំងពីឆ្នាំ ២០២០ រហូតមកដល់សព្វថ្ងៃ ដោយទទួលបាននូវលទ្ធិផលល្អប្រសើរ។ ជាក់ស្តែងឃើញថា ដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធជាលើកដំបូងរបស់ធនាគារ អេស៊ីលីដា គឺទទួលបានការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា ចំនួន ៤.៣៤៤.៨៦៥ ភាគហ៊ុន ដោយទទួលបានជោគជ័យនៃចំនួនភាគហ៊ុនដែលស្នើសុំសរុប។ ចំណែកឯប្រតិបត្តិការជួញដូរមូលបត្រកម្មសិទ្ធិ ABC របស់ធនាគារអេស៊ីលីដា ប្រចាំខែមិថុនា ឆ្នាំ២០២២ វិញគឺទំហំជួញដូរនៃមូលបត្រនេះនូវតែបន្តការកើនឡើងជាលំដាប់ពីមួយសប្តាហ៍ទៅមួយសប្តាហ៍នៅក្នុងទីផ្សារមូលបត្រកម្ពុជា ដែលជាលទ្ធិផលដ៏ល្អមួយសម្រាប់ធនាគារអេស៊ីលីដា ភីអិលស៊ី នៅក្នុងដំណើរការនៃការជួញដូរមូលបត្រកម្មសិទ្ធិ។ ម្យ៉ាងវិញទៀតឃើញថាធនាគារអេស៊ីលីដា ភីអិលស៊ី គឺមានភាពលេចធ្លោយ៉ាងខ្លាំងផងដែរនៅក្នុងផ្សារមូលបត្រកម្ពុជា ដែលជាកត្តាជំរុញឱ្យកាន់តែសាធារណៈជន និងវិនិយោគិនមកវិនិយោគជាមួយធនាគារអេស៊ីលីដា ភីអិលស៊ី។

ទន្ទឹមទៅនឹងភាពរីកចម្រើន ធនាគារអេស៊ីលីដា ភីអិលស៊ី ក៏មាននូវចំណុចដែលគួរយកចិត្តទុកដាក់បន្ថែមទៀតផងដែរ ដែលទាក់ទងទៅនឹងដំណើរការនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូងរបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ទាក់ទងទៅនឹងដំណាក់កាលនីមួយៗនៃការបោះផ្សាយមូលបត្រកម្មសិទ្ធិ ដូចជាការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មជាដើម ព្រមទាំងបង្កើនការទាក់ទាញលើការជួញដូរមូលបត្រកម្មសិទ្ធិទៅកាន់វិនិយោគិនបន្ថែមទៀត ដើម្បីឱ្យមូលបត្រ ABC របស់ធនាគារ អេស៊ីលីដា កាន់តែមានភាពទូលំទូលាយ និងមានភាពរីកចម្រើនកាន់តែខ្លាំង។

សរុបមកធនាគារអេស៊ីលីដា ភីអិលស៊ី កំពុងតែមានភាពរីកចម្រើនជាលំដាប់ និងបន្តគោលដៅរបស់ខ្លួនជាបន្តបន្ទាប់នៅក្នុងដំណើរការជួញដូរមូលបត្រកម្មសិទ្ធិនេះនៅក្នុងផ្សារមូលបត្រកម្ពុជា ក៏ដូចជាធនាគារអេស៊ីលីដា ភីអិលស៊ី ទាំងមូលផងដែរ។

២.ការផ្តល់អនុសាសន៍

យោងទៅតាមការសិក្សាស្រាវជ្រាវកន្លងមកនេះឃើញថាស្របទៅនឹងភាពរីកចម្រើននៃវិស័យមូលបត្ររបស់ធនាគារអេស៊ីលីដា ភីអិលស៊ី ក៏នៅតែមានកត្តាផ្សេងៗដែលគួរយកចិត្តទុកដាក់ និងអភិវឌ្ឍន៍បន្ថែមទៀតផងដែរចំពោះការបោះផ្សាយមូលបត្រកម្មសិទ្ធិនៅលើកបន្ទាប់ផងដែរ ដែលកត្តាទាំងនោះរួមមាន៖

- ដើម្បីកៀងគរវិនិយោគិនឱ្យចូលរួមកាន់តែច្រើន និងទូលំទូលាយ ការធ្វើប៊ុកបៀលឌីងគួរតែបន្ថែមចំនួនថ្ងៃឱ្យកាន់តែច្រើនជាងមុន ជាក់ស្តែងការធ្វើប៊ុកបៀលឌីងរបស់ធនាគារអេស៊ីលីដា មានចំនួនតែ ១១ថ្ងៃប៉ុណ្ណោះ។ ចំណែកឯការធ្វើបរិវិសកម្មរបស់ធនាគារអេស៊ីលីដា គួរតែកាត់បន្ថយចំនួនថ្ងៃនៃការធ្វើបរិវិសកម្ម ដើម្បីកុំឱ្យវិនិយោគិនមានការទន្ទឹមរងចាំយូរនៅក្នុងការចុះឈ្មោះទិញភាគហ៊ុន ជាក់ស្តែងការធ្វើបរិវិសកម្មរបស់ធនាគារមានរយៈពេលរហូតដល់ ១ខែឯណោះ។
- ធនាគារអេស៊ីលីដា ភីអិលស៊ី គួរតែពង្រីកប្រតិបត្តិការជួញដូរមូលបត្រ ដើម្បីបង្កើនការលក់មូលបត្រនៅបណ្តាប្រទេសផ្សេងៗទៀតឱ្យទូលំទូលាយ ជាក់ស្តែងបច្ចុប្បន្ន ធនាគារអេស៊ីលីដា មានទីតាំងនៅក្រៅប្រទេសចំនួនពីរតែប៉ុណ្ណោះគឺ សាធារណរដ្ឋប្រជាធិតេយ្យមានិតឡាវ និងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។
- បន្តផ្សព្វផ្សាយ និងពង្រីកពាក់ព័ន្ធការបោះផ្សាយមូលបត្រទៅកាន់វិនិយោគិនទូលំទូលាយជាងនេះ ដូចជាការធ្វើសិក្ខាសាលាឱ្យកាន់តែច្រើនក្នុងមួយឆ្នាំៗ ដើម្បីបញ្ជ្រាបព័ត៌មានដល់វិនាយោគិនមានចំណេះដឹងអំពីផ្នែកមូលបត្រកាន់តែទូលំទូលាយ។

ឯកសារយោង

ឯកសារយោង

ច្បាប់ ប្រកាស និងគោលការណ៍ណែនាំ

- គោលការណ៍ណែនាំស្តីពីយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង លេខ ០០១ ថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ២០១១
- ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, លេខនស/រកម/០១០៧/០២៨, ២៣ តុលា ២០០៧
- មាត្រាទី១០ នៃច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

សៀវភៅ

- ឈាង ម៉ែងហៀក, មូលដ្ឋានគ្រឹះនៃវិនិយោគ
- ញាន វណ្ណៈ, ២០១៥, នីតិទីផ្សារមូលបត្រកម្ពុជា
- បៀន សាំង, ២០១១, មូលដ្ឋានគ្រឹះនៃទីផ្សារមូលបត្រ
- ហេង ច័ន្ទបូលីន, ទីផ្សារមូលបត្រកម្ពុជា

គេហទំព័រ

- http://csx.com.kh/kh/about/profile.jsp?MNCD=10301 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)
- http://csx.com.kh/news/faq/listPosts.do?MNCD=7060 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)
- http://csx.com.kh/data/lstcom/listPosts.do?MNCD=50101 (ចូលទស្សនាថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២)
- https://www.serc.gov.kh/khmer/m46.php?pn=2 No8 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)
- http://www.secc.gov.kh/khmer/faq.php?pn=2 (ចូលទស្សនាថ្ងៃទី ០១ ខែមិថុនា ឆ្នាំ ២០២២)
- https://www.linkedin.com (ចូលទស្សនាថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/khm/ff_overview (ចូលទស្សនា ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/khm/ff_history.founder (ចូលទស្សនា ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh (ចូលទស្សនា ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)
- _https://www.acledabank.com.kh/kh/khm/md_logo (ចូលទស្សនា ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/khm/md_logo (ចូលទស្សនា ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/khm/ff_vision_mission (ចូលទស្សនា ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/khm/ff_bod (ចូលទស្សនា ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/eng/bp_annualreportធនាគារអេស៊ីលីដា,របាយការណ៍ប្រចាំឆ្នាំ ២០២១ ទំព័រទី០១ (ចូលទស្សនា ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២)

- https://www.serc.gov.kh/khmer/m53.php?pn=6 (ចូលទស្សនាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២)
- https://www.serc.gov.kh/khmer/m58.php?pn=6 (ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/assets/pdf_zip/disclosure (ចូលទស្សនាថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២២)
- ធនាគារអេស៊ីលីដា, ឯកសារផ្តល់ព័ត៌មាន https://www.acledabank.com.kh/kh/assets/pdf_zip/disclosure-documents-khm.pdf (ចូលទស្សនាទី ១០ ខែកក្កដា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/khm/listing-subscription (ចូលទស្សនាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២២)
- ធនាគារអេស៊ីលីដា,លទ្ធភាពដ៏គាប់ប្រសើរនៃដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកប៊ៀលឌីង) របស់ធនាគារអេស៊ីលីដា ភីអិលស៊ី https://www.acledabank.com.kh/kh/khm/md_ln20200317 (ចូលទស្សនា ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២២)
- http://csx.com.kh/data/allboard/listPosts.do?MNCD=60201 (ចូលទស្សនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០២២)

- https://www.serc.gov.kh/khmer/m53.php?pn=6 (ចូលទស្សនាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២២)
- https://www.serc.gov.kh/khmer/m58.php?pn=6 (ចូលទស្សនាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/assets/pdf_zip/disclosure (ចូលទស្សនាថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០២២)
- ធនាគារអេស៊ីលីដា, ឯកសារផ្តល់ព័ត៌មាន https://www.acledabank.com.kh/kh/assets/pdf_zip/disclosure-documents-khm.pdf (ចូលទស្សនាទី ១០ ខែកក្កដា ឆ្នាំ២០២២)
- https://www.acledabank.com.kh/kh/khm/listing-subscription (ចូលទស្សនាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០២២)
- ធនាគារអេស៊ីលីដា,លទ្ធភាពដ៏គាប់ប្រសើរនៃដំណើរការកំណត់ថ្លៃភាគហ៊ុន (ប៊ុកប៊ៀលឌីង) របស់ធនាគារអេស៊ីលីដា ភីអិលស៊ី https://www.acledabank.com.kh/kh/khm/md_ln20200317 (ចូលទស្សនា ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០២២)
- http://csx.com.kh/data/allboard/listPosts.do?MNCD=60201 (ចូលទស្សនាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០២២)

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១
គោលការណ៍ណែនាំស្តីពីយន្តការ
នៃការចោះផ្សាយមូលបត្រកម្មសិទ្ធិ
ជាសាធារណៈលើកដំបូង

គណៈកម្មការមូលបត្រកម្ពុជា
លេខ:.....០០៦.....គ.ម.ក/ អ.ណ.ន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១

គោលការណ៍ណែនាំ
ស្តីពី
យន្តការនៃការចោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី ១៨ ខែតុលា ឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងប្រកាសលេខ ០០១ គ.ម.ក.ប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ព្រមទាំងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធដទៃទៀត និងដើម្បីសម្រួលដល់ការយល់ដឹង ធានាឱ្យបានការអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង គណៈកម្មការមូលបត្រកម្ពុជា **(គ.ម.ក.)** សូមធ្វើការណែនាំនូវយន្តការនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមាន ដូចខាងក្រោម÷

១- *ការដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ*

បុគ្គលដែលមានបំណងបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ អាចដាក់លិខិតសម្តែងឆន្ទៈបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈជូនមក **គ.ម.ក.** ដែលលិខិតមានខ្លឹមសារ ០៣ ចំណុច ដូចខាងក្រោម:

១- គោលបំណងនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Purpose of IPO)

២- គម្រោងពេលវេលាទុកនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (Expected Timetable)

៣- ក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរំពឹងទុក (Expected IPO Team) រួមមាន ក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃជាដើម។

អាសយដ្ឋានបណ្តោះអាសន្ន អគារ ៩៩ ផ្លូវ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ-កម្ពុជា
Temporary Address: # 99, Street 598, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh, Cambodia. www.secc.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៨៨៥-៦១១ Phone : 855-23-885-611 E-mail : info@secc.gov.kh
ទូរសារ : ៨៥៥-២៣-៨៨៥-៦២២ Fax : 855-23-885-622

២- *ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ*

ការតែងតាំងក្រុមហ៊ុនធានាទិញមូលបត្រ គឺជាដំណាក់កាលដ៏សំខាន់ ព្រោះថាក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវផ្តល់សេវាដល់ក្រុមហ៊ុនបោះផ្សាយនៅគ្រប់ដំណាក់កាលនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការជ្រើសរើសក្រុមហ៊ុនធានាទិញមូលបត្រក្នុងចំណោមក្រុមហ៊ុនធានាទិញមូលបត្រ ដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.**។

៣- *ការបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO Team)*

ក្រៅពីក្រុមហ៊ុនធានាទិញមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ត្រូវធ្វើការតែងតាំង បុគ្គលសំខាន់ៗពាក់ព័ន្ធដោយផ្ទាល់មួយចំនួនទៀត ដូចជាក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលទទួលបានការទទួលស្គាល់ពី **គ.ម.ក.** ដើម្បីចូលរួមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ស្របតាមបទប្បញ្ញត្តិជាធរមាន។ ក្រុមហ៊ុនធានាទិញមូលបត្រ អាចផ្តល់យោបល់ដល់ក្រុមហ៊ុនបោះផ្សាយលើការជ្រើសរើសក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ។ ក្រោយពីជ្រើសរើសបានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ក្រុមហ៊ុនបោះផ្សាយ ត្រូវបង្កើតក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង។

៤- *ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence)*

ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់ ជាដំណាក់កាលដ៏សំខាន់ និងចាំបាច់បំផុត។ ក្រុមហ៊ុនបោះផ្សាយចាំបាច់ត្រូវឆ្លងកាត់ការត្រួតពិនិត្យការបំពេញកាតព្វកិច្ចតាមច្បាប់។ ការងារនេះ ត្រូវធ្វើដោយក្រុមការងារបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង ដែលរួមមានក្រុមហ៊ុនគណនេយ្យជំនាញ មេធាវី ឬក្រុមមេធាវី ឬក្រុមហ៊ុនមេធាវី និងក្រុមហ៊ុនផ្តល់សេវាវាយតម្លៃ ដែលដឹកនាំដោយក្រុមហ៊ុនធានាទិញមូលបត្រ ។

៥- *ការដាក់ពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រ និងការទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារ ស្របតាមវិធានចុះបញ្ជីរបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ។

៦- *ការដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី គ.ម.ក.*

ក្រោយពីទទួលបានការបញ្ជាក់ពីលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំឯកសារដាក់ពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈមក **គ.ម.ក.**។ **គ.ម.ក.** ធ្វើការវាយតម្លៃពាក្យស្នើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ជាពិសេសឯកសារផ្តល់ព័តិមាន មុននឹងផ្តល់ការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈ ជូនក្រុមហ៊ុនបោះផ្សាយ។

៧- *ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង (Book Building)*

ក្រោយពីទទួលបានការអនុញ្ញាតជាគោលការណ៍លើសំណើសុំបោះផ្សាយលក់មូលបត្រជាសាធារណៈពី **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំធ្វើការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីង ពោលគឺការស្ទាបស្ទង់តម្លៃលក់មូលបត្រជាមួយអ្នកវិនិយោគសក្តានុពល មុននឹងឈានដល់ការកំណត់ថ្លៃលក់មូលបត្រ។

៨- *ការស្នើសុំបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំស្នើសុំការបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា។ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ត្រូវបញ្ជាក់ថាថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងអាចដាក់លក់នៅលើផ្សារមូលបត្របាន ដោយឈរលើមូលដ្ឋានវិធានប្រតិបត្តិការ ដោយរាប់បញ្ចូលវិធានចុះបញ្ជីលក់មូលបត្រ មានន័យថាថ្លៃត្រូវអាចបញ្ចូលទៅក្នុងប្រព័ន្ធជួញដូររបស់ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា និងស្ថិតនៅក្នុងកម្រិតនៃប្រព័ន្ធជួញដូរដែលបានកំណត់នៅក្នុងវិធានប្រតិបត្តិការ។

៩- *ការស្នើសុំការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ (Term of Offer) និងការទទួលបានការអនុញ្ញាត និងការចុះបញ្ជីឯកសារផ្តល់ព័តិមានពី គ.ម.ក.*

ក្រោយពីបានបញ្ចប់ការកំណត់ថ្លៃលក់មូលបត្រតាមរយៈប៊ុកបៀលឌីងរួចហើយ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំលក្ខខណ្ឌនៃសំណើលក់ ដោយត្រូវធ្វើបច្ចុប្បន្នកម្មឯកសារផ្តល់ព័តិមាន និងត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ការដាក់តម្លៃមូលបត្រពីក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា រួចដាក់ជូន**គ.ម.ក.** ដើម្បីទទួលបានការអនុញ្ញាត និងធ្វើការចុះបញ្ជី។

១០- *ការធ្វើបរិវិសកម្មមូលបត្រ (Subscription)*

ក្រោយពីទទួលបានការអនុញ្ញាតលើលក្ខខណ្ឌនៃសំណើលក់ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី **គ.ម.ក.** ក្រុមហ៊ុនបោះផ្សាយដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវចាប់ផ្តើមដំណើរការធ្វើបរិវិសកម្មមូលបត្រ ដោយអនុវត្តតាមលក្ខខណ្ឌ ដូចមានចែងក្នុងជំពូកទី ៣ និង ជំពូកទី ៤ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ។

១១- *ការរាយការណ៍ពីលទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវរៀបចំរបាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រ ហើយត្រូវដាក់របាយការណ៍លទ្ធផលនៃការធ្វើបរិវិសកម្មមូលបត្រនេះ ភ្ជាមជូន **គ.ម.ក.**។

១២- *ការចុះបញ្ជីលក់មូលបត្រជាផ្លូវការនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា*

ក្រោយពីបានបញ្ចប់ការធ្វើបរិវិសកម្មមូលបត្រ និងការបញ្ជូនមូលបត្រកម្មសិទ្ធិ ទៅឱ្យអ្នកធ្វើបរិវិសកម្មដែលទទួលបានជោគជ័យ ក្រុមហ៊ុនបោះផ្សាយ ដោយមានជំនួយពីក្រុមហ៊ុនធានាទិញមូលបត្រ ត្រូវបំពេញបែបបទនៅក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា ដើម្បីចុះបញ្ជីជួញដូរមូលបត្រជាផ្លូវការ ដោយអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

គណៈកម្មការមូលបត្រកម្ពុជា

ឧបសម្ព័ន្ធទី២៖
ពាក្យស្នើសុំចូលរួមធ្វើបុកប៉ៀលឌីច
របស់ធនាគារអេស៊ីលីដាតីអិលស៊ី

យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី
Yuanta Securities (Cambodia) Plc

លេខប៊ុកប៊ៀលឌីង:
Book Building No.:

កាលបរិច្ឆេទ:
Date: dd / mm / yyyy

ពាក្យស្នើសុំចូលរួមប៊ុកប៊្រៀលឌីង
BOOK BUILDING FORM

ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ / EQUITY SECURITIES INFORMATION

ក្រុមហ៊ុនចេញផ្សាយ : ធនាគារ អេស៊ីលីដា ភីអិលស៊ី Issuer: ACLEDA Bank Plc.	ក្រុមហ៊ុនធានាទិញមូលបត្រ: យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី Underwriter: Yuanta Securities (Cambodia) Plc.

មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងទុកសម្រាប់ប៊ុកប៊្រៀលឌីងមានចំនួន **៤.៣៧៥.៦៩៦** ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងទុកសម្រាប់បរិវិសកម្មមានចំនួនចាប់ពី **៤.៣៧៥.៦៩៥** ឯកតាមូលបត្រកម្មសិទ្ធិ ដល់ **១៧.៥០២.៧៨១** ឯកតាមូលបត្រកម្មសិទ្ធិ។
ធនាគារ អេស៊ីលីដា ភីអិលស៊ី បានកំណត់ថ្លៃលក់ចន្លោះពី **១៥.០០០ រៀល** ដល់ **១៧.៤០០ រៀល** ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ។
វិនិយោគិនដែលចូលរួមក្នុងការស្នាបស្នង់ថ្លៃលក់មូលបត្រ (Book-Building) ត្រូវជ្រើសរើសថ្លៃណាមួយក្នុងចំណោមចន្លោះថ្លៃដែលក្រុមហ៊ុនបានកំណត់ ដោយមានឯកតាគម្លាតថ្លៃស្មើនឹង **១០០ រៀល** និងបំពេញចំនួនមូលបត្រកម្មសិទ្ធិ ដែលមានបំណងធ្វើបរិវិសកម្មបន្ទាប់ពីបញ្ចប់ដំណាក់កាលនៃការធ្វើប៊ុកប៊្រៀលឌីង ដោយមានចំនួនអប្បបរមាចាប់ពី **១០០** ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីបរិមាណមូលបត្រដែលមានបំណងធ្វើបរិវិសកម្មមានចំនួនច្រើនជាងចំនួនអប្បបរមា ចំនួនមូលបត្រកម្មសិទ្ធិដែលបានស្នើត្រូវស្មើនឹងចំនួនអប្បបរមាបូកនឹងចំនួនដងនៃ១០ឯកតាមូលបត្រកម្មសិទ្ធិ។ វិនិយោគិនដែលចូលរួមក្នុងការស្នាបស្នង់ថ្លៃលក់មូលបត្រកម្មសិទ្ធិត្រូវតម្កល់ប្រាក់ស្មើនឹងដប់ភាគរយ (១០%) នៃថ្លៃមូលបត្រកម្មសិទ្ធិសរុបដែលមានបំណងនឹងធ្វើបរិវិសកម្ម។

The total number of equity securities reserved for Book Building are **4,375,696** units of equity securities. The total number of equity securities reserved forSubscription are from **4,375,695** to **17,502,781** units of equity securities.
ACLEDA Bank Plc. determined a price range from **KHR 15,000** to **KHR 17,400** per unit of equity securities.
Investors who participate in the Book Building shall select one price from the price range set by **ACLEDA Bank Plc.** along with tick price of **KHR 100** and fill out the quantity of shares intended to subscribe after the Book Building with the minimum size of **100 shares**. In case, the quantity of securities intended to subscribe is excess of the minimum size, the quoted number of share shall be the minimum plus a multiple of 10 units of equity securities. The investors, who participate in the Book Building, shall deposit ten percent (10%) of total amount of equity securities intended to subscribe.

ព័ត៌មានរបស់វិនិយោគិន / INVESTOR INFORMATION

ក. វិនិយោគិនជាបុគ្គល: ☐ សញ្ជាតិខ្មែរ Cambodian Citizen ☐ មិនមែនសញ្ជាតិខ្មែរ Non-Cambodian Citizen _____
A. For individual

ឈ្មោះជាអក្សរខ្មែរ _____ ឈ្មោះជាអក្សរឡាតាំង _____ ភេទ Gender ☐ ប្រុស Male ☐ ស្រី Female
Name in Khmer / Name in Latin

លេខអត្តសញ្ញាណវិនិយោគិន _____ លេខគណនីជួញដូរ _____ ឈ្មោះក្រុមហ៊ុនមូលបត្រ _____
Investor ID No. / Trading Account No. / Securities Firm Name

លេខកូដប្រទេស និង ទូរស័ព្ទដៃ [ ] [ ] អ៊ីមែល _____
Country Code & Mobile Phone / Email

ខ. វិនិយោគិនជានីតិបុគ្គល: ☐ សញ្ជាតិខ្មែរ Cambodian Citizen ☐ មិនមែនសញ្ជាតិខ្មែរ Non-Cambodian Citizen _____
B. For Legal Entity

១. ឈ្មោះក្រុមហ៊ុន (អក្សរខ្មែរ) _____ ឈ្មោះក្រុមហ៊ុន (អក្សរឡាតាំង) _____
Company Name (Khmer) / Company Name (Latin)

លេខអត្តសញ្ញាណវិនិយោគិន _____ លេខគណនីជួញដូរ _____ ឈ្មោះក្រុមហ៊ុនមូលបត្រ _____
Investor ID No. / Trading Account No. / Securities Firm Name

លេខកូដប្រទេស និង ទូរស័ព្ទដៃ [ ] [ ] អ៊ីមែល _____
Country Code & Mobile Phone / Email

២. ឈ្មោះអ្នកតំណាង (អក្សរខ្មែរ) _____ ឈ្មោះអ្នកតំណាង (អក្សរឡាតាំង) _____
Name of Representative (Khmer) / Name of Representative (Latin)

លេខកូដប្រទេស និង ទូរស័ព្ទដៃ [ ] [ ] អ៊ីមែល _____
Country Code & Mobile Phone / Email

ធនាគារ អេស៊ីលីដា ភីអិលស៊ី អេស៊ីលីដា ACLEDA ការិយាល័យកណ្តាល ACLEDA Bank Plc.

ព័ត៌មានពាក់ព័ន្ធនឹងការស្នើបស្នង់ថ្លៃលក់មូលបត្រកម្មសិទ្ធិ / INFORMATION RELATED TO THE BOOK BUILDING OF EQUITY SECURITIES

➢ វិនិយោគិនត្រូវកំណត់ថ្លៃមូលបត្រកម្មសិទ្ធិដោយជ្រើសរើសថ្លៃណាមួយក្នុងចំណោមថ្លៃដូចខាងក្រោម៖
Investor shall quote the price by selecting one among the price below:

☐ KHR 15,000	☐ KHR 15,100	☐ KHR 15,200	☐ KHR 15,300	☐ KHR 15,400	☐ KHR 15,500	☐ KHR 15,600
☐ KHR 15,700	☐ KHR 15,800	☐ KHR 15,900	☐ KHR 16,000	☐ KHR 16,100	☐ KHR 16,200	☐ KHR 16,300
☐ KHR 16,400	☐ KHR 16,500	☐ KHR 16,600	☐ KHR 16,700	☐ KHR 16,800	☐ KHR 16,900	☐ KHR 17,000
☐ KHR 17,100	☐ KHR 17,200	☐ KHR 17,300	☐ KHR 17,400			

➢ ចំនួនមូលបត្រកម្មសិទ្ធិអប្បបរមាដែលធ្វើបរិវិសកម្មត្រូវស្មើនឹង ១០០ឯកតាមូលបត្រកម្មសិទ្ធិ។ ការធ្វើបរិវិសកម្មលើសចំនួនអប្បបរមាត្រូវស្មើនឹងចំនួនអប្បបរមាបូកនឹងចំនួនដងនៃ១០ឯកតាមូលបត្រកម្មសិទ្ធិ។
Minimum subscribing quantity shall be 100 shares. Subscription more than the minimum shall be the minimum plus a multiple of 10 units of equity securities.

ចំនួនមូលបត្រកម្មសិទ្ធិ Total Number of Equity Securities [A]	ថ្លៃមូលបត្រកម្មសិទ្ធិដែលកំណត់ Quoted Price [B]	ចំនួនទឹកប្រាក់សរុប Total Amount [C] [C = A x B]	ចំនួនទឹកប្រាក់តម្កល់១០% 10% Deposit [D = C x 10%]	ចំនួនទឹកប្រាក់តម្កល់ជាក់ស្តែង Actual Deposit
Shares	KHR	KHR	KHR	KHR

មធ្យោបាយទូទាត់ប្រាក់តម្កល់១០%សម្រាប់ប៊ុកបៀលឌីង៖
Method of settlement of 10% deposit for Book Building:

☐ ប្រាក់សុទ្ធ
Cash

☐ មូលប្បទានបត្រ៖ មូលប្បទានបត្រលេខ _____ កាលបរិច្ឆេទ _____ ធនាគារ _____
Cheque: Cheque No. Date Bank

☐ ផ្ទេរតាមធនាគារ៖ ឈ្មោះគណនី _____ លេខគណនី _____ ធនាគារ _____
Bank Transfer: Account Name Account No. Bank

☐ គណនីជួញដូរ៖ ក្រុមហ៊ុនមូលបត្រ _____
Trading Account: Securities Firm

ព័ត៌មានពាក់ព័ន្ធនឹងការផ្ទេរប្រាក់កក់ / REFUND INFORMATION

☐ ករណីខ្ញុំមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង សូមរក្សាទុកប្រាក់កក់ប៊ុកបៀលឌីងសម្រាប់ដំណើរការធ្វើបរិវិសកម្ម។
In case I am not successful in Book Building, please keep the Book Building deposit for the subscription process.

☐ ករណីខ្ញុំមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង ខ្ញុំមានបំណងទទួលប្រាក់កក់ប៊ុកបៀលឌីង (ដកចេញនូវគ្រប់ការចំណាយ ប្រសិនបើមាន) តាមរយៈមធ្យោបាយណាមួយខាងក្រោម៖
In case I am not successful in Book Building, I would like to receive the Book Building Deposit (subtract all the expenses, if any) through any one of the below methods:

☐ ផ្ទេរប្រាក់កក់ត្រឡប់ទៅគណនីជួញដូរវិញ / Refund to Trading Account

☐ ផ្ទេរប្រាក់កក់ទៅគណនីធនាគារ / Refund to Bank Account

ឈ្មោះធនាគារ _____ ឈ្មោះសាខាធនាគារ _____
Bank Name Branch Name

ឈ្មោះគណនី _____ លេខគណនី _____
Account Name Account No.

លេខកូដ SWIFT _____
Swift Code

* សម្គាល់៖ ម្ចាស់គណនី និងវិនិយោគិនដែលមិនទទួលបានជោគជ័យ ត្រូវតែជាបុគ្គលតែមួយ។ គណនីរួម មិនត្រូវបានអនុញ្ញាត។
* Note: The bank account owner and Unsuccessful Investor must be the same person. Joint Accounts are not allowed.

☐ ដកជាសាច់ប្រាក់ (នៅទីស្នាក់ការកណ្តាលនៃធនាគារ អេស៊ីលីដា) / Refund in Cash (at ACLEDA Bank Head Quarter)

ឯកសារភ្ជាប់ / ATTACHED DOCUMENTS

☐ វិក្កយបត្រតម្កល់ប្រាក់
Proof of Deposit

សេចក្តីថ្លែងរបស់អ្នកធ្វើបរិវិសកម្ម / SUBSCRIBER STATEMENT

វិនិយោគិន និង ក្រុមហ៊ុនធានាទិញមូលបត្រ បានអាន យល់ច្បាស់ និងយល់ព្រមលើលក្ខខណ្ឌដែលបានចែងក្នុងសេវាប៊ុកបៀលឌីងដូចដែលមានភ្ជាប់មកជាមួយ។
The Investor and the Underwriter named herein have understood and agreed on the terms and conditions of the Book Building Service attached hereto.

ហត្ថលេខា-ត្រា និងឈ្មោះវិនិយោគិន Signature-Seal and Name of Investor	ហត្ថលេខា និងឈ្មោះរបស់តំណាងភ្នាក់ងារចែកចាយលក់ Signature and Name of Representative of Selling Agent	ហត្ថលេខា ត្រា និងឈ្មោះប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬនាយកប្រតិបត្តិ Signature-Seal and Name of Head of Securities Representatives or CEO
_____	_____	_____

ធនាគារ អេស៊ីលីដា ភីអិលស៊ី
អេស៊ីលីដា
ACLEDA
ACLEDA Bank Plc.

យ៉ាន់តា ស៊ិនហ្សឺរីធី (ខេមបូឌា) ភីអិលស៊ី
Yuanta Securities (Cambodia) Plc

សេវាប៊ុកបៀលឌីង
BOOK BUILDING SERVICE

វិនិយោគិន និងក្រុមហ៊ុនធានាទិញមូលបត្របានអាន និងយល់ព្រមលើលក្ខខណ្ឌនៃសេវាប៊ុកបៀលឌីងដូចខាងក្រោម៖
The Investor and the Underwriter have hereby reviewed and agreed on the following terms and conditions of this Book Building Service.

១. គោលបំណង / PURPOSE

គោលបំណងចម្បងនៃសេវាប៊ុកបៀលឌីងនេះ (តទៅនេះហៅកាត់ថា «**សេវាប៊ុកបៀលឌីង**») គឺដើម្បីកំណត់លក្ខខណ្ឌនៃសេវាប៊ុកបៀលឌីងដែលត្រូវផ្តល់ជូនដោយក្រុមហ៊ុនធានាទិញមូលបត្រ អនុលោមទៅតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជនលេខ នស/រកម/ ១០០៧/០២៨ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ អនុក្រឹត្យស្តីពីការអនុវត្តន៍ច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន លេខ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ និងប្រកាសលេខ ០០៥/១៥ គ.ម.ក./ប្រ.ក. ស្តីពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជា សាធារណៈ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងទៀត។
The main purpose of this Book Building Service (hereinafter referred to as the "**Book Building Service**") is to set forth the terms and conditions for the Book Building Service to be provided by the Underwriter in accordance with the Law on Issuance and Trading of Non-government Securities No. NS/RKM/1007/028 dated on 19 October 2007, Anukret on the Implementation of the Law on Issuance and Trading of Non-government Securities No. 54 ANKR BK dated on 8 April 2009, and Prakas No. 005/15 SECC/PrK on Public Issuance of Equity Securities dated on 10 September 2015 and other relevant regulations in force.

២. និយមន័យ / DEFINITIONS

២.១ ចំនួនមូលបត្រកម្មសិទ្ធិដែលលៃបម្រុងទុក មានន័យថា ចំនួនមូលបត្រកម្មសិទ្ធិបោះផ្សាយលក់ជាសាធារណៈ ដែលត្រូវបានកំណត់ជាបណ្តោះអាសន្ន សម្រាប់បែងចែកឲ្យវិនិយោគិនដែលទទួលបានជោគជ័យស្របតាមលទ្ធផលនៃដំណើរការប៊ុកបៀលឌីង។
Pre-Allotted Equity Securities means an amount of publicly offered shares that have been tentatively determined for the relevant Successful Investors, in light of the outcome of the Book Building Process.

២.២ វិនិយោគិនដែលទទួលបានជោគជ័យ មានន័យថា វិនិយោគិនដែលចូលរួមក្នុងប៊ុកបៀលឌីង ហើយដាក់ថ្លៃស្នើ ឬខ្ពស់ជាងថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ ហើយចំនួនមូលបត្រកម្មសិទ្ធិដែលលៃបម្រុងទុកនឹងត្រូវបែងចែកជូនស្របតាមលទ្ធផលនៃដំណើរការប៊ុកបៀលឌីង។
Successful Investor(s) means investor(s) who participates in the Book Building by quoting the price that is equal to or higher than the final offering price and is granted with the Pre-Allotted Equity Securities as a result of the Book Building Process.

២.៣ វិនិយោគិនដែលមិនទទួលបានជោគជ័យ មានន័យថា វិនិយោគិនដែលចូលរួមក្នុងប៊ុកបៀលឌីង ហើយដាក់ថ្លៃទាបជាងថ្លៃមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើសំណើលក់ ហើយចំនួនមូលបត្រកម្មសិទ្ធិដែលលៃបម្រុងទុកនឹងមិនត្រូវបានបែងចែកជូនស្របតាមលទ្ធផលនៃដំណើរការប៊ុកបៀលឌីង។
Unsuccessful Investor(s) means investor(s) who participates in the Book Building Process by quoting the price that is lower than the final offering price and the Pre-Allotted Equity Securities is not granted as a result of the Book Building Process.

៣. ការចូលរួមក្នុងដំណើរការប៊ុកបៀលឌីង / PARTICIPATION IN THE BOOK BUILDING PROCESS

វិនិយោគិនសញ្ជាតិខ្មែរ ឬសញ្ជាតិបរទេស ត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុងដំណើរការប៊ុកបៀលឌីងតែមួយដងគត់។ ក្នុងករណីដែលវិនិយោគិនមានសញ្ជាតិលើសពីមួយ វិនិយោគិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់តែសញ្ជាតិមួយប៉ុណ្ណោះសម្រាប់ចូលរួមក្នុងដំណើរការប៊ុកបៀលឌីង។
An Investor, whether a Cambodian Investor or a Non-Cambodian Investor, shall not be permitted to participate more than once in the Book Building Process that is contemplated hereunder. In the event that an Investor has more than one nationality, such Investor shall only be allowed to use one nationality for the purpose of participating in the Book Building Process.

៤. សេវាប៊ុកបៀលឌីង / BOOK BUILDING SERVICE

៤.១ ការតម្កល់ប្រាក់សម្រាប់ប៊ុកបៀលឌីង៖ វិនិយោគិនដែលចូលរួមក្នុងដំណើរការប៊ុកបៀលឌីងត្រូវដាក់តម្កល់ប្រាក់ ១០% នៃតម្លៃសរុប (ចំនួនមូលបត្រកម្មសិទ្ធិ x ថ្លៃស្នើសុំ) (**«ប្រាក់កក់ប៊ុកបៀលឌីង»**) ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមប៊ុកបៀលឌីង ទៅក្នុងគណនីប៊ុកបៀលឌីងរបស់ក្រុមហ៊ុនបោះផ្សាយ តាមរយៈវិធីណាមួយដែលបានកំណត់ខាងក្រោម យ៉ាងយូរត្រឹមថ្ងៃបញ្ចប់ដំណើរការប៊ុកបៀលឌីង (**«ថ្ងៃបញ្ចប់ដំណើរការប៊ុកបៀលឌីង»**) ហើយវិនិយោគិនត្រូវដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាក់កក់មកក្រុមហ៊ុនធានាទិញមូលបត្រដើម្បីផ្ទៀងផ្ទាត់។

Book Building Deposit: The investor participating in the Book Building Process shall deposit 10% of the total value of equity securities (quantity x bid price) that the investor has bid on the Book Building Application Form (the "**Book Building Deposit**") to the Issuer's Book Building Account by any one or more of the permissible methods set forth below by the closing date of the Book Building Process (the "**Book Building Closing Date**"), and the Investor shall submit a documentary evidence to the Underwriter verifying the Book Building Deposit.

ក. ដាក់ជាសាច់ប្រាក់
Cash deposit

ខ. ដាក់មូលប្បទានបត្រ
Cheque deposit

គ. ផ្ទេរប្រាក់ក្នុង និង ពីក្រៅប្រទេសតាមរយៈធនាគារ
Local and overseas bank transfer

ឃ. ផ្ទេរប្រាក់ពីគណនីជួញដូរ ឬ
Transfer from Trading Account or

ង. វិធីណាមួយផ្សេងទៀតដែលអាចបញ្ជាក់ថាប្រាក់កក់ប៊ុកបៀលឌីងត្រូវបានដាក់ក្នុងគណនីរបស់ក្រុមហ៊ុនបោះផ្សាយ។
Any other legitimate method that results in the funds being transferred to the Issuer's Account.

៤.២ ទឹកប្រាក់ដែលដាក់តម្កល់នឹងមិនមានការប្រាក់ទេ។
No interest shall be accrued on the Book Building Deposit.

៤.៣ ប្រាក់កក់ប៊ុកបៀលឌីងត្រូវផ្ទេរឲ្យបានគ្រប់ចំនួនតាមការណែនាំរបស់ក្រុមហ៊ុនធានាទិញមូលបត្រ។ ក្រុមហ៊ុនធានាទិញមូលបត្រមិនទទួលខុសត្រូវលើការកាន់ច្រឡំ ឬយឺតយ៉ាវណាមួយដែលកើតឡើងក្នុងអំឡុងពេលផ្ទេរប្រាក់ដែលបណ្តាលមកពីការមិនគោរពតាមការណែនាំខាងលើឡើយ។
Book Building Deposit must be transferred or remitted in full in accordance with the Underwriter's instructions. The Underwriter assumes no responsibility for any error or delay in the transfer or remittance as a result of a failure to follow the aforementioned instructions.

៥. វិនិយោគិនដែលទទួលបានជោគជ័យ / SUCCESSFUL INVESTOR

វិនិយោគិនដែលទទួលបានជោគជ័យត្រូវចូលរួមក្នុងដំណាក់កាលបរិវិសកម្ម និងត្រូវធ្វើបរិវិសកម្មយ៉ាងតិចស្មើនឹងចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុកដល់ខ្លួន។ ប្រសិនបើវិនិយោគិនដែលទទួលបានជោគជ័យមិនបានចូលរួមក្នុងដំណាក់កាលបរិវិសកម្ម វិនិយោគិនដែលទទួលបានជោគជ័យនឹងត្រូវបានសន្មត់ថាបានធ្វើបរិវិសកម្មដោយស្វ័យប្រវត្តិលើចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុក ឬចំនួនស្មើនឹង ១០% នៃប្រាក់តម្កល់ ដោយយកមួយណាដែលទាបជាងគេ។
Successful Investors shall participate in Subscription process and subscribe at least equal to the reserved equity securities. In case Successful Investors do not participate in Subscription process, Successful Investors shall be deemed as automatically subscribed the reserved equity securities or equal to 10% deposit whichever is lower.

៦. ការផ្ទេរប្រាក់កក់ / REFUND

៦.១ បន្ទាប់ពីទទួលបានការអនុម័តពី គ.ម.ក. លើលទ្ធផលនៃការធ្វើប៊ុកបៀលឌីង ក្រុមហ៊ុនបោះផ្សាយនឹងជូនដំណឹងដល់វិនិយោគិន និងផ្ទេរប្រាក់កក់ជូនវិនិយោគិនដែលមិនទទួលបានជោគជ័យវិញ ឬរក្សាទុកក្នុងករណីដែលវិនិយោគិនដែលមិនទទួលបានជោគជ័យមានបំណងចូលរួមបន្តក្នុងដំណាក់កាលបរិវិសកម្ម។
Immediately after the approval from the SECC on the Book Building result, the Issuer will announce the Book Building result and refund the 10% deposit to Unsuccessful Investors or keep it in the case where any one of such Unsuccessful Investors have indicated, in Book Building Application Form, to continue to participate in the Subscription process.

៦.២ **រូបិយប័ណ្ណនៃការផ្ទេរប្រាក់កក់៖** ការផ្ទេរប្រាក់កក់ត្រូវធ្វើឡើងជាមួយនឹងរូបិយប័ណ្ណប្រាក់រៀល។
Currency for the Refund: Any refund hereof shall be made in KHR.

៦.៣ **តម្លៃនៃការផ្ទេរប្រាក់កក់៖** វិនិយោគិនយល់ និងព្រមព្រៀងថា ក្នុងករណីដែលមានហេតុការណ៍ដូចដែលបានចែងខាងក្រោម វិនិយោគិនត្រូវទទួលប្រាក់កក់ប៊ុកបៀលឌីងវិញ បន្ទាប់ពីកាត់កងការចំណាយ និងកម្រៃមួយចំនួន និងចាំបាច់ទាំងឡាយ រួមទាំងកម្រៃនៃការផ្ទេរតាមរយៈ ធនាគារ)៖
Refund Cost: The Investor understands and agrees that upon occurrence of any of the following events, the Investor shall be entitled to a refund of the amount of its Book Building Deposit after deducting any and all necessary expenses, fees and costs (including, without limitation, bank transfer fees):

ឧបសម្ព័ន្ធទី៣៖
ពាក្យស្នើសុំចូលរួមធ្វើបរិវិសកម្ម
របស់ធនាគារអេស៊ីលីដាតីអិលស៊ី

យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី
Yuanta Securities (Cambodia) Plc

លេខបរិវិសកម្ម:
Subscription No.:

កាលបរិច្ឆេទ:
Date: dd / mm / yyyy

ពាក្យស្នើសុំធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ

SUBSCRIPTION APPLICATION FORM

ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ / EQUITY SECURITIES INFORMATION

ក្រុមហ៊ុនបោះផ្សាយ : ធនាគារ អេស៊ីលីដា ភីអិលស៊ី Issuer: ACLEDA Bank Plc.	ក្រុមហ៊ុនធានាទិញមូលបត្រ: យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី Underwriter: Yuanta Securities (Cambodia) Plc.

មូលបត្រកម្មសិទ្ធិសរុបដែលត្រូវបោះផ្សាយលក់ជាសាធារណៈ:មានមូលបត្រកម្មសិទ្ធិថ្មីចំនួន ៨.៧៥១.៣៩១ ឯកតាមូលបត្រកម្មសិទ្ធិ និង មូលបត្រកម្មសិទ្ធិបច្ចុប្បន្នរហូតដល់ ១៣.១២៧.០៨៦ ឯកតាមូលបត្រកម្មសិទ្ធិ ដែលតម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ៤,០០០ រៀល ហើយថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិស្មើនឹង ១៦.២០០ រៀល។
មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងទុកសម្រាប់ប៊ុកបៀលឌីងមានចំនួន ៤.៣៧៥.៦៩៦ ឯកតាមូលបត្រកម្មសិទ្ធិ។ មូលបត្រកម្មសិទ្ធិសរុបដែលលៃបម្រុងទុកសម្រាប់បរិវិសកម្មមានចំនួនចាប់ពី ៤.៣៧៥.៦៩៥ ឯកតាមូលបត្រកម្មសិទ្ធិ ដល់ ១៧.៥០២.៧៨១ ឯកតាមូលបត្រកម្មសិទ្ធិ។
សម្រាប់វិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិត្រូវមានចំនួនអប្បបរមាចាប់ពី ១ ឯកតាមូលបត្រកម្មសិទ្ធិឡើងទៅ។ ករណីវិនិយោគិនដែលមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ធ្វើបរិវិសកម្មច្រើនជាងចំនួនអប្បបរមា ចំនួនមូលបត្រកម្មសិទ្ធិដែលត្រូវធ្វើបរិវិសកម្មគឺត្រូវស្មើនឹងចំនួនអប្បបរមាបូកនឹងចំនួនដងនៃ១ឯកតាមូលបត្រកម្មសិទ្ធិ។

The total number of equity securities for public offering of new shares are 8,751,391 units of equity securities and existing shares are up to 13,127,086 units of equity securities with par value per unit of equity securities 4,000 riels and the offering price per unit of equity securities **16,200** riels.
The total number of equity securities reserved for Book Building are 4,375,696 units of equity securities. The total number of equity securities reserved forSubscription are from 4,375,695 to 17,502,781 units of equity securities.
For unsuccessful Book Building Investors and non-Book Building investors, the minimum of equity securities to be subscribed is 1 unit of equity securities. If unsuccessful Book Building investors and non-Book Building investors subscribe more than the minimum of equity securities as mentioned above, the subscription shall be the minimum plus a multiple of 1 unit of equity securities.

ព័ត៌មានរបស់វិនិយោគិន / INVESTOR INFORMATION

ក. វិនិយោគិនជារូបវន្តបុគ្គល: ☐ សញ្ជាតិខ្មែរ Cambodian Citizen ☐ មិនមែនសញ្ជាតិខ្មែរ Non-Cambodian Citizen _____

A. For individual

ឈ្មោះ (អក្សរខ្មែរ) _____ Name in Khmer
ឈ្មោះ (អក្សរឡាតាំង) _____ Name in Latin
ភេទ Gender ☐ ប្រុស Male ☐ ស្រី Female
លេខអត្តសញ្ញាណវិនិយោគិន _____ Investor ID No.
លេខគណនីជួញដូរ _____ Trading Account No.
ឈ្មោះក្រុមហ៊ុនមូលបត្រ _____ Securities Firm Name
លេខកូដប្រទេស និង ទូរស័ព្ទដៃ [ ] [ ] Country Code & Mobile Phone
អ៊ីមែល _____ Email

ខ. វិនិយោគិនជានីតិបុគ្គល: ☐ សញ្ជាតិខ្មែរ Cambodian Citizen ☐ មិនមែនសញ្ជាតិខ្មែរ Non-Cambodian Citizen _____

B. For Legal Entity

១. ឈ្មោះក្រុមហ៊ុន (អក្សរខ្មែរ) _____ Company Name (Khmer)
ឈ្មោះក្រុមហ៊ុន (អក្សរឡាតាំង) _____ Company Name (Latin)
លេខអត្តសញ្ញាណវិនិយោគិន _____ Investor ID No.
លេខគណនីជួញដូរ _____ Trading Account No.
ឈ្មោះក្រុមហ៊ុនមូលបត្រ _____ Securities Firm Name
លេខកូដប្រទេស និង ទូរស័ព្ទដៃ [ ] [ ] Country Code & Mobile Phone
អ៊ីមែល _____ Email

២. ឈ្មោះអ្នកតំណាង (អក្សរខ្មែរ) _____ Name of Representative (Khmer)
ឈ្មោះអ្នកតំណាង (អក្សរឡាតាំង) _____ Name of Representative (Latin)
លេខកូដប្រទេស និង ទូរស័ព្ទដៃ [ ] [ ] Country Code & Mobile Phone
អ៊ីមែល _____ Email

ព័ត៌មានពាក់ព័ន្ធនឹងការចូលរួមប៊ុកបៀលឌីង/ BOOK BUILDING INFORMATION

ប្រភេទវិនិយោគិន៖
Type of Investor

☐ វិនិយោគិនមិនបានចូលរួមក្នុងប៊ុកបៀលឌីង
Non-Book Building Investor

☐ វិនិយោគិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង៖ Successful Book Building Investor
លេខប៊ុកបៀលឌីង _____ Book Building No.
ចំនួនមូលបត្រកម្មសិទ្ធិដែលបានលៃបម្រុងទុក _____ Pre-Allotted Equity Securities

☐ វិនិយោគិនមិនទទួលបានជោគជ័យក្នុងប៊ុកបៀលឌីង៖ Unsuccessful Book Building Investor
លេខប៊ុកបៀលឌីង _____ Book Building No.
ប្រាក់កក់ប៊ុកបៀលឌីង Book Building Deposit ☐ បានផ្ទេរត្រឡប់ទៅវិញ Refunded ☐ មិនបានផ្ទេរត្រឡប់ទៅវិញ No Refund

ព័ត៌មានពាក់ព័ន្ធនឹងការស្នើសុំធ្វើបរិវិសកម្ម/ SUBSCRIPTION INFORMATION

ចំនួនមូលបត្រកម្មសិទ្ធិ Total Number of Equity Securities [A]	ថ្លៃលក់ក្នុងមួយឯកតា Offering Price [B]	ចំនួនទឹកប្រាក់សរុប Total Amount [C] [C = A x B]	ចំនួនទឹកប្រាក់តម្កល់ក្នុងប៊ុកប៊ៀលឌីង Book Building Deposit [D]	ចំនួនទឹកប្រាក់ត្រូវតម្កល់ក្នុងបរិវិសកម្ម Subscription Deposit [E] [E = C – D]
Shares	**KHR 16,200**	KHR	KHR	KHR

ទឹកប្រាក់ដែលបានតម្កល់ជាក់ស្តែងក្នុងបរិវិសកម្ម
Actual Subscription Deposit: KHR

មធ្យោបាយទូទាត់ប្រាក់តម្កល់សម្រាប់បរិវិសកម្ម:
Method of settlement of deposit for subscription:

☐ ប្រាក់សុទ្ធ
Cash

☐ មូលប្បទានបត្រ: Cheque: មូលប្បទានបត្រលេខ Cheque No. _____ កាលបរិច្ឆេទ Date _____ ធនាគារ Bank _____

☐ ផ្ទេរតាមធនាគារ: Bank Transfer: ឈ្មោះគណនី Account Name _____ លេខគណនី Account No. _____ ធនាគារ Bank _____

☐ ផ្ទេរតាមទាន់ចិត្ត: ToanChet: ឈ្មោះគណនី Account Name _____ លេខគណនី Account No. _____ លេខយោង Reference No. _____

☐ គណនីជួញដូរ: Trading Account: ក្រុមហ៊ុនមូលបត្រ Securities Firm _____

ព័ត៌មានពាក់ព័ន្ធនឹងការផ្ទេរប្រាក់កក់ / REFUND INFORMATION

ករណីខ្ញុំមិនទទួលបានមូលបត្រកម្មសិទ្ធិទៅតាមការស្នើសុំធ្វើបរិវិសកម្ម ខ្ញុំមានបំណងទទួលប្រាក់កក់បរិវិសកម្ម (ដកចេញនូវាល់ការចំណាយ ប្រសិនបើមាន) តាមរយៈមធ្យោបាយណាមួយខាងក្រោម:
In case I did not receive the number of equity securities as I subscribed, I would like to receive the Subscription Deposit (subtract all the expenses, if any) through any one of the below methods:

☐ ផ្ទេរប្រាក់កក់ត្រឡប់ទៅគណនីជួញដូរវិញ / Refund to Trading Account

☐ ផ្ទេរប្រាក់កក់ទៅគណនីធនាគារ / Refund to Bank Account

ឈ្មោះធនាគារ Bank Name _____ ឈ្មោះសាខាធនាគារ Branch Name _____

ឈ្មោះគណនី Account Name _____ លេខគណនី Account No. _____

លេខកូដ SWIFT Swift Code _____

* សម្គាល់: ម្ចាស់គណនី និង វិនិយោគិនដែលមិនទទួលបានជោគជ័យ ត្រូវតែជាបុគ្គលតែមួយ។ គណនីរួម មិនត្រូវបានអនុញ្ញាត។
* Note: The bank account owner and Unsuccessful Investor must be the same person. Joint Accounts are not allowed.

☐ ដកជាសាច់ប្រាក់ (នៅទីស្នាក់ការកណ្តាលនៃធនាគារ អេស៊ីលីដា) / Refund in Cash (at ACLEDA Bank Head Quarter)

ឯកសារភ្ជាប់ / ATTACHED DOCUMENTS

☐ វិក្កយបត្រតម្កល់ប្រាក់
Proof of Deposit

សេចក្តីថ្លែងរបស់អ្នកធ្វើបរិវិសកម្ម / SUBSCRIBER STATEMENT

នៅក្នុងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិនេះ ខ្ញុំបានទទួលឯកសារផ្តល់ព័ត៌មានក្នុងទម្រង់ជា:
In subscribing to the equity securities, I recieved the disclosure document in the form of:

☐ ច្បាប់ចម្លង Hard copy ☐ ឧបករណ៍ផ្ទុក Storage device ☐ អ៊ីមែលផ្ទុក Email storage ☐ តាមរយៈគេហទំព័ររបស់ធនាគារ អេស៊ីលីដា ACLEDA Bank's Website ឬ or ☐ ផ្សេងពីនេះ Other _____

ការធ្វើបរិវិសកម្ម និងការទូទាត់ ដែលធ្វើឡើងដោយអ្នកធ្វើបរិវិសកម្មត្រូវតែស្របទៅតាមលក្ខខណ្ឌដែលមានចែងក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំយល់ព្រម និងទទួលស្គាល់ថាក្រុមហ៊ុនបោះផ្សាយមានសិទ្ធិបដិសេធ ក្នុងករណីការស្នើសុំធ្វើបរិវិសកម្មណាមួយដែលមិនគោរពតាមលក្ខខណ្ឌ។ ខ្ញុំយល់ព្រមទិញមូលបត្រកម្មសិទ្ធិក្នុងចំនួនដូចបានកំណត់ខាងលើ ឬចំនួនមូលបត្រកម្មសិទ្ធិដែលក្រុមហ៊ុនបានបែងចែកមកឲ្យខ្ញុំ។ ខ្ញុំសូមសន្យាថាមិនលុបចោលការធ្វើបរិវិសកម្មរបស់ខ្ញុំទេ និងយល់ព្រមទទួលប្រាក់សងត្រឡប់មកវិញ ក្នុងករណីការធ្វើបរិវិសកម្មត្រូវបានបដិសេធ ឬការធ្វើបរិវិសកម្មរបស់ខ្ញុំមិនសម្រេចបានតាមការស្នើសុំទាំងអស់របស់ខ្ញុំ។ ខ្ញុំយល់ស្របតាមលក្ខខណ្ឌនៃសំណើបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូងដូចមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។ ខ្ញុំទទួលស្គាល់ផងដែរថា ការវិនិយោគលើមូលបត្រកម្មសិទ្ធិមានហានិភ័យពាក់ព័ន្ធ។
The subscription and payment made by subscriber shall be in accordance with the conditions specified in the disclosure document. I agree and acknowledge that issuer shall be entitled to refuse if any subscription does not comply with the said conditions. I undertake to purchase the number of equity securities as stated above or the number of equity securities allotted to me. I shall not cancel my subscription, and accept a return amount if the subscription is refused. I agree with the condition of initial public offering as specified in the Disclosure Document. I also acknowledge that the investment in equity securities is risk associated.

ខ្ញុំបានអានឯកសារផ្តល់ព័ត៌មានដោយម៉ត់ចត់មុនពេលធ្វើបរិវិសកម្ម និងមិនមានការបញ្ចុះបញ្ចូលដោយភាគីណាមួយទេ។
I thoroughly read the disclosure document before subscribing.

វិនិយោគិន និង ក្រុមហ៊ុនធានាទិញមូលបត្របានអាន និងយល់ព្រមលើលក្ខខណ្ឌនៃសៀវភៅបរិវិសកម្មដូចដែលមានភ្ជាប់មកជាមួយ។
The Investor and the Underwriter have hereby reviewed and agreed on the following terms and conditions of the Subscription Service as attached hereto.

ហត្ថលេខា-ត្រា និងឈ្មោះវិនិយោគិន Signature-Seal and Name of Investor	ហត្ថលេខា និងឈ្មោះរបស់តំណាងភ្នាក់ងារចែកចាយលក់ Signature and Name of Representative of Selling Agent	ហត្ថលេខា ត្រា និងឈ្មោះប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រ ឬនាយកប្រតិបត្តិ Signature-Seal and Name of Head of Securities Representatives or CEO
		Park Sung Bae

សេវាបរិវិសកម្ម
SUBSCRIPTION SERVICE

វិនិយោគិន និងក្រុមហ៊ុនធានាក្រុមហ៊ុនមូលបត្របានអាន និងយល់ព្រមលើលក្ខខណ្ឌនៃសេវាបរិវិសកម្មដូចខាងក្រោម៖
The Investor and the Underwriter have hereby reviewed and agreed on the following terms and conditions of this Subscription Service.

១. លក្ខខណ្ឌទូទៅ / GENERAL

១.១ ការដាក់ពាក្យស្នើសុំត្រូវធ្វើលើពាក្យស្នើសុំដែលបានរៀបចំដោយក្រុមហ៊ុន យ៉ាន់តា ស៊ីឃ្យូរីធី (ខេមបូឌា) ភីអិលស៊ី («**ក្រុមហ៊ុន យ៉ាន់តា**»)។
Application must be made on the application form that has been prepared by Yuanta Securities (Cambodia) Plc. ("YSC").

១.២ ពាក្យស្នើសុំត្រូវធ្វើឡើងដោយនីតិបុគ្គលដែលបានចុះបញ្ជី ឬរូបវន្តបុគ្គលដែលមានសមត្ថភាពតាមផ្លូវច្បាប់។ អនីតិជន ឬបុគ្គលដែលមានសតិមិនគ្រប់គ្រាន់មិនត្រូវបានចាត់ទុកថាមានសមត្ថភាពតាមផ្លូវច្បាប់ក្នុងគោលបំណងនៃការដាក់ពាក្យស្នើសុំនេះទេ។
Application must be made by a registered legal entity or an existing individual with legal capacity. For avoidance of any doubt, a minor or a person with unsound mind shall not be considered as having legal capacity for the purpose of this Application.

១.៣ ពាក្យស្នើសុំត្រូវបំពេញឲ្យបានពេញលេញ និងគោរពតាមលក្ខខណ្ឌតម្រូវដែលមាន។
Application must be complete and satisfy the requirements contained herein.

១.៤ វិនិយោគិនត្រូវផ្តល់នូវ (១) ព័ត៌មានលម្អិតអំពីគណនីជួញដូរមូលបត្រដែលមាននៅក្រុមហ៊ុនមូលបត្រណាមួយដែលទទួលបានអាជ្ញាបណ្ណពី គ.ម.ក. និង (២) ឯកសារផ្សេងទៀតដែលស្នើសុំដោយក្រុមហ៊ុន យ៉ាន់តា ឬភ្នាក់ងារចែកចាយលក់របស់ក្រុមហ៊ុន យ៉ាន់តា នាពេលដាក់ពាក្យស្នើសុំ។
The investor shall provide its (1) Details of the Trading Account at one of the securities firms licensed by the SECC and (2) Any other documents requested by YSC or any one of its authorized selling agents at the time of submission of the application.

១.៥ ពាក្យស្នើសុំដែលមានព័ត៌មានមិនពិត ឬមិនត្រឹមត្រូវនឹងត្រូវបានបដិសេធ ហើយវិនិយោគិនអាចនឹងត្រូវពិន័យ ឬផ្តន្ទាទោសតាមច្បាប់ ដែលក្នុងករណីនេះ ក្រុមហ៊ុន យ៉ាន់តា មិនទទួលខុសត្រូវឡើយ។
Application containing false statement or incorrect information shall be rejected and the investor may be subject to penalties or prosecution under the applicable law for which YSC assumes or undertakes no responsibility.

១.៦ វិនិយោគិនមិនអាចដាក់ពាក្យស្នើសុំលើសពីមួយបានទេ ហើយក្រុមហ៊ុន យ៉ាន់តា សូមរក្សាសិទ្ធិបដិសេធពាក្យស្នើសុំដែលដាក់ច្រើនដង ឬពាក្យស្នើសុំដែលសង្ស័យថាត្រូវបានដាក់ច្រើនដង។ ក្នុងករណីដែលវិនិយោគិនមានសញ្ជាតិលើសពីមួយ វិនិយោគិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់តែសញ្ជាតិមួយប៉ុណ្ណោះសម្រាប់ចូលរួមក្នុងដំណើរការបរិវិសកម្ម។
An applicant cannot submit more than one application and YSC reserves the right to reject all multiple applications or those that are suspected as multiple applications in the opinion of YSC. In the event that an investor has more than one nationality, such investor shall only be allowed to use one nationality for the purpose of participating in the Subscription Process.

២. ការធ្វើបរិវិសកម្ម / SUBSCRIPTION

២.១ សម្រាប់វិនិយោគិនមិនទទួលបានជោគជ័យ និងវិនិយោគិនដែលមិនបានចូលរួមក្នុងប៊ុកបៀលឌីង ការធ្វើបរិវិសកម្មត្រូវមានចំនួនអប្បបរមាចាប់ពី ១ ឯកតាមូលបត្រកម្មសិទ្ធិ និងត្រូវស្មើនឹងចំនួនដងនៃ ១ ឯកតាមូលបត្រកម្មសិទ្ធិ ប្រសិនបើការធ្វើបរិវិសកម្មលើសពីចំនួនអប្បបរមា។
For the Unsuccessful Investors and Non-Participating Investors in the Book Building, the minimum subscription shall be from 1 unit of equity securities and the subscription more than a minimum shall be a multiple of 1 equity securities.

២.២ **ការតម្កល់ប្រាក់សម្រាប់បរិវិសកម្ម៖** វិនិយោគិនដែលចូលរួមក្នុងដំណើរការបរិវិសកម្មត្រូវដាក់តម្កល់ប្រាក់ ១០០% នៃតម្លៃសរុប (ចំនួនមូលបត្រកម្មសិទ្ធិ x ថ្លៃមូលបត្រកម្មសិទ្ធិ) (**«ប្រាក់កក់បរិវិសកម្ម»**) ដែលបានបំពេញក្នុងពាក្យស្នើសុំចូលរួមបរិវិសកម្ម ក្នុងគណនីបរិវិសកម្ម របស់ក្រុមហ៊ុនបោះផ្សាយ តាមរយៈវិធីណាមួយដែលបានកំណត់ខាងក្រោម យ៉ាងយូរត្រឹមថ្ងៃបញ្ចប់ដំណើរការបរិវិសកម្ម (**«ថ្ងៃបញ្ចប់ដំណើរការបរិវិសកម្ម»**) ហើយវិនិយោគិនត្រូវដាក់លិខិតបញ្ជាក់អំពីការដាក់ប្រាក់កក់មកក្រុមហ៊ុន យ៉ាន់តា ដើម្បីផ្ទៀងផ្ទាត់។
Subscription Deposit: The investor participating in the Subscription Process shall deposit 100% of the total value of equity securities (quantity x offering price) that the investor has put on the Subscription Application Form (the **"Subscription Deposit"**) to the Issuer's Subscription Account by any one or more of the permissible methods set forth below by the closing date of the Subscription Process (the **"Subscription Closing Date"**), and the Investor shall submit a documentary evidence to the Underwriter verifying the Subscription Deposit.

ក. ដាក់ជាសាច់ប្រាក់
Cash deposit

ខ. ដាក់មូលប្បទានបត្រ
Cheque deposit

គ. ផ្ទេរប្រាក់ក្នុង និង ពីក្រៅប្រទេសតាមរយៈធនាគារ
Local and overseas bank transfer

ឃ. ផ្ទេរប្រាក់ពីគណនីជួញដូរ ឬ
Transfer from Trading Account or

ង. វិធីណាមួយផ្សេងទៀតដែលអាចបញ្ជាក់ថាប្រាក់កក់ប៊ុកបៀលឌីងត្រូវបានដាក់ក្នុងគណនីរបស់ក្រុមហ៊ុនបោះផ្សាយ។
Any other legitimate method that results in the funds being transferred to the Issuer's Account.

២.៣ ទឹកប្រាក់ដែលដាក់តម្កល់នឹងមិនមានការប្រាក់ទេ។
No interest shall be accrued on the Subscription Deposit.

២.៤ ក្នុងករណីមានភាពខុសគ្នារវាងចំនួនមូលបត្រកម្មសិទ្ធិសរុបដែលបានធ្វើបរិវិសកម្ម និងចំនួនមូលបត្រកម្មសិទ្ធិដែលអាចធ្វើបរិវិសកម្មបានជាមួយនឹងប្រាក់កក់បរិវិសកម្ម វិនិយោគិនត្រូវសន្មត់ថាបានធ្វើបរិវិសកម្មលើចំនួនទឹកប្រាក់កក់បរិវិសកម្ម។
In the event of any discrepancy between the subscribed amount and the amount that can be subscribed with the Subscription Deposit, the Investor shall be deemed to have subscribed for the amount corresponding to the Subscription Deposit.

២.៥ ប្រាក់កក់បរិវិសកម្មត្រូវផ្ទេរឲ្យបានគ្រប់ចំនួនតាមការណែនាំរបស់ក្រុមហ៊ុន យ៉ាន់តា។ ក្រុមហ៊ុន យ៉ាន់តា មិនទទួលខុសត្រូវលើការភាន់ច្រឡំ ឬយឺតយ៉ាវណាមួយដែលកើតឡើងក្នុងអំឡុងពេលផ្ទេរប្រាក់ ដែលបណ្តាលមកពីការមិនគោរពតាមការណែនាំខាងលើឡើយ។
Subscription Deposit must be transferred or remitted in full, in accordance with YSC's instructions. YSC assumes no responsibility for any error or delay in the transfer or remittance as a result of a failure to follow the aforementioned instructions.

៣. ការបែងចែកមូលបត្រកម្មសិទ្ធិ / ALLOTMENT

ការបែងចែកមូលបត្រកម្មសិទ្ធិត្រូវធ្វើស្របទៅតាមនីតិវិធីដូចដែលមានចែងនៅក្នុងឯកសារផ្តល់ព័ត៌មាន។
The equity securities shall be allotted in accordance with the allocation method included in the disclosure document.

៤. ការផ្ទេរប្រាក់កក់ / REFUND

៤.១ ទឹកប្រាក់ដែលនៅសល់ពីប្រាក់កក់បរិវិសកម្មបន្ទាប់ពីដំណាក់កាលបរិវិសកម្ម ត្រូវផ្ទេរត្រឡប់ទៅបុគ្គលដាក់ពាក្យស្នើសុំវិញតាមរយៈមធ្យោបាយដែលបានបញ្ជាក់ក្នុងពាក្យស្នើសុំ ឬតាមវិធីដែលសមស្របផ្សេងទៀត។
Any remainder of the Subscription Deposit after the Subscription Period shall be refunded to the corresponding Applicants through the method stipulated in their Application or via any other reasonable methods.

៤.២ រូបិយប័ណ្ណនៃការផ្ទេរប្រាក់កក់៖ ការផ្ទេរប្រាក់កក់ត្រូវធ្វើឡើងជាមួយនឹងរូបិយប័ណ្ណប្រាក់រៀល។
Currency for the Refund: Any refund hereof shall be made in KHR.

៤.៣ តម្លៃនៃការផ្ទេរប្រាក់កក់៖ វិនិយោគិនយល់ និងព្រមព្រៀងថា ក្នុងករណីដែលមានហេតុការណ៍ដូចដែលបានចែងខាងក្រោម វិនិយោគិនត្រូវទទួលប្រាក់កក់បរិវិសកម្មវិញ បន្ទាប់ពីកាត់កងការចំណាយ និងកម្រៃមួយចំនួន និងចាំបាច់ទាំងឡាយ (រួមទាំងកម្រៃនៃការផ្ទេរតាមរយៈធនាគារ)៖
Refund Cost: The Investor understands and agrees that upon occurrence of any of the following events, the Investor shall be entitled to a refund of the amount of its Subscription Deposit after deducting any and all necessary expenses, fees and costs (including, without limitation, bank transfer fees):

ក. ក្នុងករណីដែលការផ្ទេរប្រាក់មានភាពចាំបាច់ អាស្រ័យទៅតាមលទ្ធផលនៃដំណើរការបរិវិសកម្មតាមយោបល់របស់ក្រុមហ៊ុន យ៉ាន់តា
In the event that the refund is necessary in light of the outcome of the Subscription Process in the opinion of YSC;

ខ. ក្នុងករណីដែលប្រាក់កក់បរិវិសកម្មមិនបានតម្កល់ក្នុងគណនីក្រុមហ៊ុនបោះផ្សាយនៅថ្ងៃបញ្ចប់ដំណើរការបរិវិសកម្ម និង
In the event that the Subscription Deposit is not deposited into the Issuer's Account by the Subscription Closing Date; and

គ. ករណីផ្សេងទៀតដែលការផ្ទេរប្រាក់កក់បរិវិសកម្មមិនអាចជៀសវាងបាន យោងតាមយោបល់របស់ក្រុមហ៊ុន យ៉ាន់តា។
Any other event where refund of the Subscription Deposit is inevitable in the opinion of YSC.

៤.៤ ក្រុមហ៊ុន យ៉ាន់តា មិនទទួលខុសត្រូវលើការកាន់ច្រឡំណាមួយដែលកើតឡើងក្នុងអំឡុងពេលផ្ទេរប្រាក់ត្រឡប់ទៅវិញ ដែលបណ្តាលមកពីព័ត៌មានគណនីធនាគារនៅក្នុងពាក្យស្នើសុំមិនត្រឹមត្រូវនោះឡើយ។
YSC assumes no responsibility for any error in the refund due to inaccurate bank account details in the Application.

៥. អំណាចនៃត្រារបស់ក្រុមហ៊ុនធានាមិញមូលបត្រ និងទម្រង់ហត្ថលេខារបស់ប្រធានភ្នាក់ងារក្រុមហ៊ុនធានាមិញមូលបត្រ
POWER OF SEAL OF THE UNDERWRITER AND SIGNATURE IMAGE OF THE UNDERWRITER'S HEAD OF SECURITIES REPRESENTATIVES

ត្រារបស់ក្រុមហ៊ុន យ៉ាន់តា និងទម្រង់ហត្ថលេខារបស់ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រនៃក្រុមហ៊ុន យ៉ាន់តា ដែលមាននៅលើពាក្យស្នើសុំបរិវិសកម្មត្រូវចាត់ទុកជាត្រាដើមរបស់ក្រុមហ៊ុន យ៉ាន់តា និងហត្ថលេខាដើមរបស់ប្រធានភ្នាក់ងារក្រុមហ៊ុនមូលបត្រនៃក្រុមហ៊ុន យ៉ាន់តា និងមានឥទ្ធិពលតាមផ្លូវច្បាប់ដូចត្រាដើម និងហត្ថលេខាដើមតទៅ។
YSC's seal hereunder and the signature image of YSC's Head of Securities Representatives as they appear on the Subscription Application Form shall be deemed as the original of the seal of YSC and the original signatures of YSC's Head of Securities Representatives and be construed as having the same legal effect as to the true originals thereof.

៦. ផ្សេងៗ / MISCELLANEOUS

៦.១ វិនិយោគិនយល់ និងព្រមព្រៀងថា គ្រប់ព័ត៌មានដែលបានផ្តល់ឲ្យដោយវិនិយោគិនមកក្រុមហ៊ុន យ៉ាន់តា ទាក់ទងនឹងដំណើរការបរិវិសកម្មពិតជាត្រឹមត្រូវ។ ប្រសិនបើ ១) ព័ត៌មានណាមួយដែលបានផ្តល់ឲ្យដោយវិនិយោគិនមកក្រុមហ៊ុន យ៉ាន់តា ខុស មិនត្រឹមត្រូវ ឬធ្វើឲ្យមានការភាន់ច្រឡំ ឬ ២) ព័ត៌មានរបស់គណនីធនាគារសម្រាប់ផ្ទេរប្រាក់កក់បរិវិសកម្មមិនត្រឹមត្រូវ ដំណើរការបរិវិសកម្មរបស់វិនិយោគិននឹងត្រូវលុបចោលដោយស្វ័យប្រវត្តិ។ ក្នុងករណីនេះ វិនិយោគិនត្រូវទទួលខុសត្រូវលើការចំណាយ ឬកម្រៃផ្សេងៗដែលបណ្តាលមកពីការលុបចោលនេះ។
The Investor understands and agrees that any and all information provided by the Investor to the Underwriter relating to the Subscription Process is true and accurate in all material respects. If (i) any information provided by the Investor to the Underwriter is false, inaccurate or misleading or (ii) the information on the bank transfer is different, then the Subscription Process for the Investor will be automatically cancelled. In such case, the Investor shall be liable for any amount of fee, cost or expense incurred due to such cancellation.

៦.២ វិនិយោគិនយល់ និងព្រមព្រៀងទៀតថា លទ្ធផលនៃដំណើរការបរិវិសកម្មនឹងមានផ្សព្វផ្សាយក្នុងសារព័ត៌មាន ឬគេហទំព័រផ្លូវការរបស់ក្រុមហ៊ុនចេញផ្សាយ ឬភ្នាក់ងារចែកចាយលក់របស់ក្រុមហ៊ុន យ៉ាន់តា ហើយវិនិយោគិននឹងត្រូវទទួលខុសត្រូវក្នុងការពិនិត្យលទ្ធផលនៃដំណើរការបរិវិសកម្មដែលបានផ្សព្វផ្សាយក្នុងសារព័ត៌មាន ឬគេហទំព័រនោះ។
The Investor further understands and agrees that the result of the Subscription Process will be made available on newspaper or websites of the Issuer or Underwriter's authorized selling agent(s) and the responsibility will be on the Investor to check the result of the Subscription Process from such newspaper or websites.

៦.៣ ក្រុមហ៊ុន យ៉ាន់តា រក្សាសិទ្ធិកែប្រែលក្ខខណ្ឌដែលមានចែងក្នុងសេវាបរិវិសកម្មនេះ។៕
YSC reserves the right to amend the terms and conditions contained herein.

ACLEDA Bank Plc